ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ



# វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ កម្ពុជា

## ២០២០

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

**ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
គេហទំព័រ៖ https://www.misti.gov.kh

ការបោះពុម្ពជាសៀវភៅអេឡិចត្រូនិកលើកទី ១៖ ២០២១
លេខចុះបញ្ជីរបស់បណ្ណាល័យជាតិ
ISBN: 978-9924-9556-4-1 (ភាសាខ្មែរ)
ISBN: 978-9924-9556-3-4 (ភាសាអង់គ្លេស)

© ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ២០២១

របាយការណ៍នេះជាកម្មសិទ្ធិរបស់អ្នកនិពន្ធ និងរក្សាសិទ្ធិគ្រប់យ៉ាងដោយ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ គ្មានផ្នែកណាមួយនៃរបាយការណ៍នេះអាចត្រូវបានផលិតឡើងវិញ ចែកចាយ ឬបញ្ជូនតាមទម្រង់ ឬមធ្យោបាយណាមួយ ឬរក្សាទុកនៅក្នុងប្រព័ន្ធទិន្នន័យ ឬប្រព័ន្ធដែលអាចទាញយកបានដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុនពីម្ចាស់កម្មសិទ្ធិបញ្ញាឡើយ។ អ្នកបោះពុម្ពផ្សាយ អ្នករៀបរៀង និងនិពន្ធនាយក សន្មតថាអនុសាសន៍ និងព័ត៌មាននៅក្នុងរបាយការណ៍នេះមានភាពជាក់លាក់និងត្រឹមត្រូវនៅថ្ងៃនៃការបោះពុម្ពផ្សាយ។ ទាំងអ្នកបោះពុម្ពផ្សាយ អ្នករៀបរៀង ឬនិពន្ធនាយក ពុំធានានូវការបង្ហាញឬការបញ្ជាក់ទាក់ទងនឹងព័ត៌មាននិងទិន្នន័យយោងដែលមាននៅក្នុងរបាយការណ៍នេះ ឬកំហុសឆ្គងឬការលុបណាមួយដែលអាចកើតឡើងដោយប្រការណាមួយនោះទេ។

អាសយដ្ឋានរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍៖ អគារលេខ ៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ១២០២០៣ ព្រះរាជាណាចក្រកម្ពុជា

# អារម្ភកថា

វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (វ.ប.ន.) មានសារៈសំខាន់ដើម្បីសម្រេចបាននូវគោលបំណង ដែលរាជរដ្ឋាភិបាលកម្ពុជាបានកំណត់សម្រាប់គោលដៅអភិវឌ្ឍន៍ជាតិរបស់ខ្លួននៅឆ្នាំ២០៣០ និង២០៥០។ ក្នុងនាមខ្ញុំជាទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខ្ញុំបានឃើញ និង យល់ច្បាស់ថាប្រទេសអភិវឌ្ឍន៍ទាំងឡាយតែងតែមានមូលដ្ឋានគ្រឹះ វ.ប.ន. ដ៏រឹងមាំសម្រាប់ការអភិវឌ្ឍ ប្រកបដោយប្រសិទ្ធភាព និងចីរភាព។ វិស័យនេះ គួរជាមូលដ្ឋានគ្រឹះដែលមិនអាចខ្វះបានសម្រាប់ប្រទេស កម្ពុជាក្នុងការដោះស្រាយបញ្ហាប្រឈមនានានៅកម្រិតជាតិ តំបន់ និងអន្តរជាតិ។ ក្រោមការដឹកនាំដ៏ឈ្លាសវៃ ប្រកបដោយគតិបណ្ឌិត និងចក្ខុវិស័យយូរអង្វែងរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវបានពង្រីកបេសកកម្ម និងបានកែប្រែទៅជា ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៅខែមីនា ឆ្នាំ២០២០។ ជាងនេះទៅទៀត ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានដំណើរការក្រោមការដឹកនាំដ៏ ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ជាប្រធានកិត្តិយស។ ដើម្បីបន្តពង្រឹងបេសកកម្ម និងរៀបចំ គោលនយោបាយក្នុងគោលដៅបង្កើតប្រព័ន្ធអេកូឡូស៊ីជាតិរឹងមាំលើវិស័យ វ.ប.ន. គណៈប្រឹក្សាយោបល់ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវបានបង្កើតឡើងដើម្បីជួយការងារ និងផ្តល់យោបល់លើជំនាញ វិទ្យាសាស្ត្រ និងបច្ចេកទេសចាំបាច់នានា ដល់ក្រុមប្រឹក្សាជាតិនេះ។ អាទិភាពចម្បងគឺការជ្រើសរើសអ្នកមាន ទេពកោសល្យដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ និងជំនាញផ្សេងៗក្នុងវិស័យ វ.ប.ន. ដើម្បីបម្រើការងារនៅអគ្គ នាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងវិទ្យាស្ថានជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ការចងក្រងឱ្យមានសេចក្តីព្រាងរបាយការណ៍ប្រកបដោយគុណភាពនេះ ជាតឹកតាងដ៏គួរឱ្យកត់សម្គាល់មួយ របស់មន្ត្រីដែលទើបចូលមកបំពេញការងារថ្មីទាំងនេះ។

របាយការណ៍នេះមានព័ត៌មានស៊ីជម្រៅទាក់ទងនឹងប្រព័ន្ធ វ.ប.ន. កម្ពុជា ដែលអាចផ្តល់ព័ត៌មាន ដល់អ្នករៀបចំគោលនយោបាយ ស្ថាប័នអប់រំ វិស័យឯកជន និងដៃគូអភិវឌ្ឍន៍អំពីសារៈសំខាន់នៃវិស័យ វ.ប.ន. ដែលជាសសរទ្រូងសម្រាប់ការអភិវឌ្ឍគោលនយោបាយឧស្សាហកម្មនាពេលអនាគត។ ការគិតគូរពិចារណាលើ ស្ថានភាពបច្ចុប្បន្ននៃវិស័យ វ.ប.ន. នៅកម្ពុជា ធនធានមនុស្ស ហេដ្ឋារចនាសម្ព័ន្ធ និងការផ្តល់មូលនិធិ គួរត្រូវ បានបង្កើតឡើង។ ខ្ញុំសូមលើកទឹកចិត្តឱ្យអ្នកពាក់ព័ន្ធទាំងអស់ អាននិងប្រើប្រាស់ឱ្យបានពេញលេញនូវព័ត៌មាន ដែលមាននៅក្នុងរបាយការណ៍នេះ។ ការវិភាគដោយផ្អែកលើបរិបទចង្អុលបង្ហាញពីអនុសាសន៍ និងជំហានបន្ទាប់ ដើម្បីជំរុញប្រព័ន្ធអេកូឡូស៊ីជាតិឱ្យរឹងមាំ និងដោះស្រាយបញ្ហាប្រឈមជាច្រើននៅក្នុងវិមាត្រទាំងឡាយនៃវិស័យ វ.ប.ន.។ ការស្វែងយល់យ៉ាងស៊ីជម្រៅពីប្រព័ន្ធអេកូឡូស៊ីជាតិ វ.ប.ន. នាពេលបច្ចុប្បន្ន គឺជាការចាំបាច់សម្រាប់ ការប្រែក្លាយទស្សនវិស័យរបស់យើងទៅជាផែនទីបង្ហាញផ្លូវមួយឆ្ពោះទៅការអភិវឌ្ឍសេដ្ឋកិច្ចឆ្នាំ២០៣០ និង ឆ្នាំ២០៥០ ក្នុងន័យរក្សាឱ្យបាននូវការអភិវឌ្ឍប្រកបដោយសុខុមាលភាពដល់ឧស្សាហកម្ម និងសហគ្រាសធុន តូចនិងមធ្យមរបស់យើង ក្នុងបរិបទបរិវត្តកម្មនៃយុគសម័យឧស្សាហកម្មជំនាន់ទី៤។

ខ្ញុំសូមឆ្លៀតយកឱកាសនេះថ្លែងអំណរគុណ និងអបអរសាទរដល់មន្ត្រីថ្មីនៃអគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងវិទ្យាស្ថានជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ចំពោះការរួមចំណែកយ៉ាងអស្ចារ្យលើកិច្ចការនេះ។ របាយការណ៍ដ៏មានតម្លៃនេះ ពិតជាត្រីវិស័យសម្រាប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងការអនុវត្តគោលនយោបាយដែលពាក់ព័ន្ធ នឹងវិស័យ វ.ប.ន. ឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ព្រោះថាការអនុវត្តគោលនយោបាយប្រកបដោយប្រសិទ្ធភាពក្នុងប្រព័ន្ធអេកូឡូស៊ីជាតិ វ.ប.ន. ឱ្យរឹងមាំ នឹងបង្កឱ្យកម្ពុជាប្រែក្លាយខ្លួនទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងមានចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០។

ថ្ងៃ អង្គារ ១០ រោច ខែ ទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០២១

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

*កិត្តិសេដ្ឋាបណ្ឌិត* **ចម ប្រសិទ្ធ**

## អ្នករៀបរៀង

ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ឆែម គាតរិទ្ធី** ប្រធាន
ឯកឧត្តមបណ្ឌិត **ហ៊ីល សៀងហេង** អនុប្រធាន
ឯកឧត្តមបណ្ឌិត **គួក ហ្វីដេរ៉ូ** អនុប្រធាន
លោកបណ្ឌិត **ទ្រី សុផល** សមាជិក
លោកស្រីបណ្ឌិត **ត្រី ណាល់លីស** សមាជិក
លោកបណ្ឌិត **កែវ សុជាតិ** សមាជិក
លោកបណ្ឌិត **ចោង អង្គារ៉ា** សមាជិក
លោក **ខៀវ វិជ្ជានន្ទ** សមាជិក
លោកបណ្ឌិត **ស្រ៊ុន បញ្ញារិទ្ធិ** សមាជិក
លោក **កែ ប៊ុនធឿន** សមាជិក
លោកស្រី **សេង ម៉ូលិកា** សមាជិក
លោកស្រីបណ្ឌិត **លី សុខនី** សមាជិក
លោកបណ្ឌិត **ជាតិ សុផល** សមាជិក
លោកបណ្ឌិត **លីវ ឃី** សមាជិក
លោកបណ្ឌិត **អ៊ឹង ប៉ោស្រ៊ី** សមាជិក
លោកបណ្ឌិត **តូ តារា** សមាជិក
កញ្ញាបណ្ឌិត **យក់ សុគន្ធស្រីរតន៍** សមាជិក
លោក **ឆាយ រាវ័ន្ត** សមាជិក

## ក្រុមនិពន្ធនាយក

លោកបណ្ឌិត **សៀវ សុខលី** ប្រធាននិពន្ធនាយក
លោក **ម៉ិ សំណាង** អនុប្រធាននិពន្ធនាយក
ឯកឧត្តមបណ្ឌិត **ហ៊ីល សៀងហេង** និពន្ធនាយក
លោក **ខៀវ វិជ្ជានន្ទ** និពន្ធនាយក


**បោះពុម្ពផ្សាយ**

**ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

# មាតិកា


**អារម្ភកថា** ... ២

**បញ្ជីអក្សរកាត់ និងពាក្យគន្លឹះ** ... ៦

**បញ្ជីតារាង** ... ៨

**បញ្ជីរូបភាព** ... ៨

**១. សេចក្ដីផ្ដើម** ... ៩

១.១. សាវតារ ... ៩

១.២. គោលបំណង ... ១៤

១.៣. វិធីសាស្ត្រ ... ១៥

**២. ប្រព័ន្ធអេកូឡូស៊ី វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍** ... ១៧

២.១. មូលនិធិ និងហិរញ្ញវត្ថុ ... ១៧

២.២. ហេដ្ឋារចនាសម្ព័ន្ធ ... ២១

២.៣. ក្របខ័ណ្ឌច្បាប់ ... ២៣

២.៤. គុណសម្បទា និងបំណិន ... ២៨

២.៥. បច្ចេកវិទ្យា ... ៣៣

**៣. កាលានុវត្តភាព និងបញ្ហាប្រឈមរបស់វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**. ៣៤

៣.១. កាលានុវត្តភាព ... ៣៤

៣.២. បញ្ហាប្រឈម ... ៣៧

**៤. ទិសដៅយុទ្ធសាស្ត្រ និងអនុសាសន៍** ... ៣៩

៤.១. ការវិនិយោគលើវិស័យ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ... ៣៩

៤.២. អភិបាលកិច្ចស្ថាប័ន ... ៤៣

៤.៣. ការត្រួតពិនិត្យ និងវាយតម្លៃវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ... ៤៦

**ឯកសារយោង** ... ៥០

ឧបសម្ព័ន្ធ ១៖ លំដាប់នៃកិច្ចប្រជុំក្រុមការងាររៀបចំរបាយការណ៍ វ.ប.ន. ... ៥៣

ឧបសម្ព័ន្ធ ២៖ ចំណាយសរុបលើការស្រាវជ្រាវនិងអភិវឌ្ឍន៍ គិតជាភាគរយនៃផលិតផលក្នុងស្រុកសរុប ... ៥៤

## បញ្ជីអក្សរកាត់ និងពាក្យគន្លឹះ

| | | |
|---|---|---|
| ADB | : | ធនាគារអភិវឌ្ឍន៍អាស៊ី |
| AFD | : | ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង |
| AI | : | បញ្ញាសិប្បនិម្មិត |
| AMMST | : | កិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា |
| APASTI | : | ផែនការសកម្មភាពអាស៊ានលើវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| APO | : | អង្គការផលិតភាពអាស៊ី |
| AR | : | បច្ចេកវិទ្យាបន្ថែមទិន្នន័យលើរូបភាព |
| ASEAN (អាស៊ាន) | : | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| AVI | : | វិទ្យាស្ថានចក្ខុវិស័យអាស៊ី |
| CamDX | : | ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា |
| CBRDF | : | មូលនិធិកសាងសមត្ថភាពស្រាវជ្រាវ និងអភិវឌ្ឍន៍ |
| CDC | : | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| CDRI | : | វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា |
| COSTI | : | គណៈកម្មាធិការផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| CSDGs | : | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា |
| EDF | : | មូលនិធិអភិវឌ្ឍន៍សហគ្រិនភាព |
| FDI | : | ការវិនិយោគដោយផ្ទាល់ពីបរទេស |
| GDP | : | ផលិតផលក្នុងស្រុកសរុប |
| GDSTI | : | អគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| GDSMEH | : | អគ្គនាយកដ្ឋានសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម |
| HEIP | : | គម្រោងកែលម្អការអប់រំឧត្តមសិក្សា |
| GERD | : | ចំណាយសរុបលើការស្រាវជ្រាវនិងអភិវឌ្ឍន៍ |
| ICT | : | បច្ចេកវិទ្យាទំនាក់ទំនង និងព័ត៌មាន |
| IDP | : | គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម |
| INSEAD | : | វិទ្យាស្ថានអឺរ៉ុបសម្រាប់ការគ្រប់គ្រងធុរកិច្ច |
| KAS | : | ថ្នាលឌីជីថលកសិកម្មខ្មែរ |
| KE | : | សហគ្រិនខ្មែរ |
| MAFF | : | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MCFA | : | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ |
| MEF | : | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MISTI | : | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| MNCs | : | ក្រុមហ៊ុនពហុជាតិ |

| | | |
|---|---|---|
| MoLVT | : | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| MOC | : | ក្រសួងពាណិជ្ជកម្ម |
| MoEYS | : | ក្រសួងអប់រំ យុវជន និងកីឡា |
| MoH | : | ក្រសួងសុខាភិបាល |
| MoI | : | ក្រសួងមហាផ្ទៃ |
| MPTC | : | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| NCSTI | : | ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| NSTC | : | ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា |
| NEA | : | ទីភ្នាក់ងារជាតិមុខរបរ និងការងារ |
| NiDA | : | អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍បច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា |
| NISTI | : | វិទ្យាស្ថានជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| OECD | : | អង្គការសម្រាប់កិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច |
| PDR | : | សាធារណរដ្ឋប្រជាធិបតេយ្យ |
| PPPs | : | ភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន |
| R&D | : | ការស្រាវជ្រាវ និងអភិវឌ្ឍន៍ |
| RGC | : | រាជរដ្ឋាភិបាលកម្ពុជា |
| SAAMBAT | : | គម្រោងនិរន្តរភាពទ្រព្យសកម្មសម្រាប់ទីផ្សារ ធុរកិច្ច និងពាណិជ្ជកម្មកសិកម្ម |
| SDGs | : | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
| SDF | : | មូលនិធិអភិវឌ្ឍន៍ជំនាញ |
| SMEs | : | សហគ្រាសធុនតូច និងមធ្យម |
| SPM | : | សម្តេចនាយករដ្ឋមន្ត្រី |
| STEM (ស្ទែម) | : | វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា |
| STI | : | វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| TSC | : | មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" |
| TVET (ធីវេត) | : | ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ |
| UILs | : | ទំនាក់ទំនងរវាងសាកលវិទ្យាល័យ និងសហគ្រាស |
| UN | : | អង្គការសហប្រជាជាតិ |
| UNDP | : | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| UNESCO (យូណេស្កូ) | : | អង្គការសហប្រជាជាតិសម្រាប់ការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ |
| VR | : | បច្ចេកវិទ្យារូបភាពប្រត្យក្សនិម្មិត |
| WIPO | : | អង្គការកម្មសិទ្ធិបញ្ញាពិភពលោក |

## បញ្ជីតារាង

តារាងទី ១៖ ហេដ្ឋារចនាសម្ព័ន្ធវិស័យ វ.ប.ន. នៅក្នុងប្រទេសកម្ពុជា ........................................................ ២២
តារាងទី ២៖ សមិទ្ធកម្មនវានុវត្តន៍នៅកម្រិតចំណូលខុសៗគ្នា ឆ្នាំ ២០២០ ................................................ ៤១

## បញ្ជីរូបភាព

រូបភាពទី ១៖ ព្រឹត្តិការណ៍ជាសារតារ នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍.......... ១៦
រូបភាពទី ២៖ ការចំណាយលើការស្រាវជ្រាវនិងអភិវឌ្ឍន៍របស់ប្រទេសជាសមាជិកអាស៊ាននៅឆ្នាំ២០១៥។ ពុំមានទិន្នន័យទទួលបានពីប្រទេសព្រុយណេ ឥណ្ឌូណេស៊ី ឡាវ និងមីយ៉ាន់ម៉ានោះទេ។ (ប្រភព៖ វិទ្យាស្ថានស្ថិតិនៃអង្គការយូណេស្កូ) ........................................................................................................ ១៩
រូបភាពទី ៣៖ ការបញ្ចប់ការសិក្សាគិតជាភាគរយនៃកម្លាំងពលកម្មដែលមានអាយុចាប់ពី១៥ ដល់៦៤ឆ្នាំ នៅឆ្នាំ២០១៥ ........................................................................................................ ២០
រូបភាពទី ៤៖ គុណសម្បទានៅសតវត្សរ៍ទី ២១ (Chu, S. et al., ២០១៦) ........................................ ៣១
រូបភាពទី ៥៖ គុណសម្បទារៀនសម្រាប់សតវត្សរ៍ទី ២១ ........................................................ ៣១
រូបភាពទី ៦៖ គុណសម្បទាអក្ខរកម្មសម្រាប់សតវត្សរ៍ទី ២១ .................................................. ៣២
រូបភាពទី ៧៖ គុណសម្បទាបំណិនជីវិតសម្រាប់សតវត្សរ៍ទី ២១ ................................................ ៣២
រូបភាពទី ៨៖ ការវាស់វែងបរិវត្តកម្មឌីជីថលប្រកបដោយបរិយាបន្ន.............................................. ៣៤
រូបភាពទី ៩៖ គោលនយោបាយឧស្សាហកម្ម និងអន្ទាក់នៃសេដ្ឋកិច្ចកម្រិតចំណូលមធ្យម (Yülek, ២០១៨) ........................................................................................................ ៣៧
រូបភាពទី ១០៖ គំរូម៉ូដែលប្រព័ន្ធនវានុវត្តន៍ជាតិ (Kuhlmann and Arnold, ២០០១) ...................... ៣៩
រូបភាពទី ១១៖ និរន្តរភាពលើប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃដែលផ្អែកលើលទ្ធផល (កែសម្រួលពី Zall & Rist (២០០៤) និង Yulek (២០១៨)) ........................................................ ៤៩

# ១. សេចក្តីផ្តើម

## ១.១. សាវតារ

រាជរដ្ឋាភិបាលកម្ពុជាបានកំណត់យកនូវរបៀបវារៈឆ្នាំ២០៣០ របស់អង្គការសហប្រជាជាតិសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) ចំនួន១៧ ដោយមានការប្តេជ្ញាចិត្តខ្ពស់ដើម្បីសម្រេចបានគោលដៅទាំងនោះ។ ដំណើរការនៃការអភិវឌ្ឍជាផ្លូវការសម្រាប់ក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (CSDGs) ត្រូវបានរៀបចំឡើងដោយមានការពិគ្រោះយោបល់ជាច្រើនលើក ជាមួយភាគីពាក់ព័ន្ធ រួមមាន៖ អ្នកធ្វើគោលនយោបាយ បណ្តាក្រសួង-ស្ថាប័ន ភ្នាក់ងារដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល។ សំណើដើម្បីបញ្ចូលគោលដៅទាំងនោះទៅក្នុងគោលនយោបាយ និងប្រព័ន្ធចែកចាយរបស់ប្រទេសកម្ពុជាត្រូវបានយកមកគិតគូរពិចារណា។ បន្ទាប់មក ក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ឆ្នាំ ២០១៦- ២០៣០ បានអនុម័តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទាំង ១៧ និងបន្ថែមគោលដៅមួយទៀតដែលទាក់ទងនឹងការបោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម។ ជាលទ្ធផល គោលដៅទាំងអស់រួមមាន៖ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជាចំនួន ១៨ គោលដៅពាក់ព័ន្ធថ្នាក់ជាតិចំនួន ៨៨ និងសូចនាករ (កំណត់ជាសកល និងក្នុងស្រុក) ចំនួន ១៤៨ រួមទាំងសូចនាករថ្នាក់ជាតិចំនួន ៩៦។ ជាទូទៅ មាគ៌ាអភិវឌ្ឍន៍របស់ប្រទេសអភិវឌ្ឍន៍ភាគច្រើនគឺមានសមាហរណកម្មយ៉ាងសកម្មនៃវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (**វ.ប.ន.**)។ ឧទាហរណ៍ វិទ្យាសាស្ត្រគឺជាតម្រូវការចាំបាច់សម្រាប់បង្កើតបច្ចេកវិទ្យាទឹកដើម្បីសម្អាតទឹក ការបង្កើតបច្ចេកវិទ្យាថាមពលដែលមិនបំពុលបរិស្ថាននិងគាំទ្រឧស្សាហកម្មប្រកបដោយចីរភាព និងជាមូលដ្ឋានគ្រឹះក្នុងការស្រាវជ្រាវលើការសិក្សាវិទ្យាសាស្ត្រ និងនវានុវត្តន៍។ គណៈកម្មាធិការអភិវឌ្ឍន៍អង្គការសហប្រជាជាតិបញ្ជាក់ថាការកសាងសមត្ថភាពលើ **វ.ប.ន.** គឺជាវិធានការដែលមិនអាចខ្វះបាន ដើម្បីសម្រេចគោលដៅឆ្នាំ ២០៣០ ការលុបបំបាត់ភាពក្រីក្រ និងការអភិវឌ្ឍប្រកបដោយចីរភាព។ ដោយហេតុផលនេះ ធនាគារបច្ចេកវិទ្យារបស់អង្គការសហប្រជាជាតិសម្រាប់ប្រទេសដែលមានការអភិវឌ្ឍតិចតួចត្រូវបានបង្កើតឡើងដើម្បីជាភ័ស្តុតាងក្នុងការបង្ហាញពីសារៈសំខាន់នៃតួនាទី **វ.ប.ន.** ឈានទៅសម្រេចបាននូវការអភិវឌ្ឍប្រកបដោយចីរភាព។ កិច្ចខំប្រឹងប្រែងជាសកម្មភាពនៃកំណែទម្រង់ជាទូទៅរបស់រាជរដ្ឋាភិបាលក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះបានធ្វើឱ្យមានកំណើនសេដ្ឋកិច្ចរឹងមាំដោយរក្សាបាននូវកំណើននៃផលិតផលក្នុងស្រុកសរុបប្រចាំឆ្នាំជាមធ្យមប្រមាណ ៧ភាគរយ ដោយកំណត់បានអត្រាស្ថិរភាពនិងអត្រាទាបនៃអតិផរណាតម្លៃរបស់អ្នកប្រើប្រាស់ (APO, ២០១៨)។ ទោះបីជាយ៉ាងណា នៅក្នុងប្រទេសកម្ពុជា ការពង្រីកកំណើនការវិនិយោគដោយផ្ទាល់ពីបរទេស (FDI) លើឧស្សាហកម្មដែលពឹងផ្អែកលើកម្លាំងពលកម្មអាចនឹងមិនគួរជាការរំពឹងទុកសម្រាប់រយៈពេលយូរទៀតទេ (Ehst et al., ២០១៨)។ ដូចគ្នានេះផងដែរ រាជរដ្ឋាភិបាលទទួលស្គាល់ថាកំណើននេះនឹងមិនមានចីរភាពទេ ដរាបណាប្រទេសកម្ពុជាពុំមានការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ចរបស់ខ្លួនពីកម្លាំងពលកម្មទាប ឬគ្មានជំនាញ ទៅជាសេដ្ឋកិច្ចដែលមានផលិតភាពការងារល្អប្រសើរ ជាមួយនឹងកម្លាំងពលកម្មជំនាញ និងចំណេះដឹងសម្រាប់ជាកម្លាំងចលករដែលរឹងមាំទនោះ (RGC, ២០១៨)។ គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ ត្រូវបានដាក់ចេញក្នុងឆ្នាំតែមួយបន្ទាប់ពីមានការផ្តួចផ្តើមគំនិតនេះ។ ជាក់ស្តែងមូលដ្ឋានគ្រឹះនៃគោលនយោបាយគឺពឹងផ្អែកទៅលើធនធានមនុស្សដែលមានជំនាញខ្ពស់ ជាពិសេសអ្នកជំនាញវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។ នេះគឺជាការចូលរួមចម្បងដល់ការសម្រេច

ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលដើម្បីក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ ២០៥០។

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍គោលនយោបាយរបស់ប្រទេសត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជានីតិកាលទី ៦ នៃរដ្ឋសភា ជារបៀបវារៈគោលនយោបាយសេដ្ឋកិច្ច-សង្គម។ គោលដៅជាយុទ្ធសាស្ត្រមានចំនួនបួន៖ (១) រក្សាកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពប្រមាណ ៧ភាគរយក្នុងមួយឆ្នាំ (២) បង្កើតការងារកាន់តែច្រើន និងសមរម្យ (៣) កាត់បន្ថយអត្រានៃភាពក្រីក្រឱ្យនៅក្រោម ១០ភាគរយ និង (៤) ពង្រឹងសមត្ថភាព និងអភិបាលកិច្ចនៃស្ថាប័នសាធារណៈ (RGC, ២០១៨)។ ការកំណត់គោលដៅបញ្ជាក់ឱ្យឃើញយ៉ាងច្បាស់ថា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ជាអាទិ៍ ឧស្សាហកម្មជំនាន់ទី ៤ និងសេដ្ឋកិច្ចឌីជីថលគឺជាកម្លាំងចលករគន្លឹះបន្ថែមលើការអភិវឌ្ឍធនធានមនុស្ស និងការធ្វើពិពិធកម្មសេដ្ឋកិច្ចដើម្បីសម្រេចបាននូវចក្ខុវិស័យឆ្នាំ ២០៣០ និង ២០៥០។ ជាលទ្ធផល ឯកសារយុទ្ធសាស្ត្រជាច្រើនត្រូវបានរួមបញ្ចូលវិស័យ **វ.ប.ន.** នៅក្នុងផែនការសកម្មភាព។ ឯកសារផ្លូវការមួយចំនួនគឺមានសារៈសំខាន់ក្នុងការយកមកពិចារណា រួមមាន៖ គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ គោលនយោបាយស្តីពីការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា(ស្ទែម) ឆ្នាំ ២០១៦ គោលនយោបាយអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម (SMEs) ឆ្នាំ ២០១៧-២០២១[1] គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ(TVET) ឆ្នាំ២០១៧-២០២៥ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៩-២០២៣ ផែនការយុទ្ធសាស្ត្រអប់រំ ឆ្នាំ ២០១៩-២០២៣ ផែនទីបង្ហាញផ្លូវឧត្តមសិក្សាកម្ពុជា ឆ្នាំ ២០៣០ គោលនយោបាយជាតិស្តីពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឆ្នាំ២០២០-២០៣០ និងក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ឆ្នាំ ២០២១-២០៣៥។ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាត្រូវបានមើលឃើញថាជាគោលការណ៍មូលដ្ឋានគ្រឹះដើម្បីធានាបាននូវសមិទ្ធផលនៃគោលបំណងក្នុងគោលនយោបាយនីមួយៗ។ គោលការណ៍លើកទឹកចិត្តនៃគោលនយោបាយសំខាន់ៗមួយចំនួន និងការឆ្លុះបញ្ចាំងលើទស្សនវិស័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាត្រូវបានបង្ហាញដូចខាងក្រោម។

គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ ២០១៥-២០២៥ មានចក្ខុវិស័យក្នុងការផ្លាស់ប្តូររចនាសម្ព័ន្ធឧស្សាហកម្មរបស់ប្រទេសកម្ពុជាឱ្យកាន់តែមានពិពិធកម្មជំនាញ ដែលជាក្បាលម៉ាស៊ីនក្នុងឧស្សាហកម្ម។ គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មមានគោលបំណងដើម្បីសម្រេចបាននូវគោលដៅចំនួនបី៖ (១) ការបង្កើនអត្រាចូលរួមចំណែកពីវិស័យឧស្សាហកម្មទៅក្នុងផលិតផលក្នុងស្រុកសរុបឱ្យបាន ៣០ភាគរយ នៅឆ្នាំ ២០២៥ ក្នុងនោះអត្រាចូលរួមពីវិស័យកម្មន្តសាលចំនួន ២០ភាគរយ (២) ការធ្វើពិពិធកម្មទំនិញនាំចេញដោយបង្កើនការនាំចេញទំនិញដែលមិនមែនវាយនភ័ណ្ឌរហូតដល់ ១៥ភាគរយ នៃការនាំចេញសរុបនៅឆ្នាំ ២០២៥ ខណៈពេលដែលការនាំចេញផលិតផលកសិកម្មកែច្នៃនៅតែជំរុញឱ្យសម្រេចបាន ១២ភាគរយ នៃការនាំចេញសរុបនៅឆ្នាំ ២០២៥ និង (៣) ការកែលម្អការចុះឈ្មោះជាផ្លូវការរបស់សហគ្រាសធុនតូច និងមធ្យមឱ្យបាន ៨០ភាគរយ ទៅ ៩០ភាគរយ ក្នុងឆ្នាំ ២០២៥ (RGC, ២០១៥)។ ក្នុងន័យនេះ គោលនយោបាយនេះត្រូវបានបង្កើតឡើងដើម្បីបង្កើនតម្លៃបន្ថែមនៃការងារអាទិភាពមួយចំនួនរួមមាន៖ ផលិតផលកសិផលកែច្នៃ វាយនភ័ណ្ឌ ឱសថនិងឧបករណ៍វេជ្ជសាស្ត្រ សម្ភារសំណង់ សម្ភារវេចខ្ចប់សម្រាប់នាំចេញ គ្រឿងសង្ហារិម និងសម្ភារឧស្សាហកម្ម។ គោលនយោបាយនេះបង្ហាញពីតួនាទី និងសកម្មភាពដែលត្រូវ

[1] គោលនយោបាយនេះមិនទាន់មានលក្ខណៈផ្លូវការនៅឡើយទេ។

អនុវត្តដោយស្ថាប័នរដ្ឋក្នុងរយៈពេលមធ្យម។ ជាឧទាហរណ៍ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម[2] មានបេសកកម្មដើម្បីធ្វើការជាមួយក្រសួងពាក់ព័ន្ធដទៃទៀតក្នុងការជំរុញ និងលើកទឹកចិត្តដល់ការសិក្សាស្រាវជ្រាវលើវិស័យ **វ.ប.ន.** ក៏ដូចជាការវាយតម្លៃពីលទ្ធភាពរបស់រាជរដ្ឋាភិបាលក្នុងការវិនិយោគលើវិស័យ **វ.ប.ន.** ដែលជាវិស័យអាទិភាពនៃការអភិវឌ្ឍដោយភ្ជាប់ជាមួយការស្រាវជ្រាវប្រកបដោយទេពកោសល្យ។

គោលនយោបាយអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម ឆ្នាំ ២០១៧-២០២១ ដែលបានគូសបង្ហាញក្នុងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ ត្រូវបានរៀបចំដោយមានផែនការអនុវត្តរយៈពេល ៥ ឆ្នាំសម្រាប់អគ្គនាយកដ្ឋានសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម (GDSMEH)។ ទិសដៅយុទ្ធសាស្ត្រ ពីរក្នុងចំណោមទិសដៅទាំងប្រាំ ដែលទាក់ទងនឹង **វ.ប.ន.** គឺដើម្បីលើកកម្ពស់ផលិតភាព បច្ចេកវិទ្យា និងនវានុវត្តន៍ ក៏ដូចជាលើកកម្ពស់សហគ្រិនភាព និងការអភិវឌ្ឍមូលធនមនុស្សសម្រាប់សហគ្រាសធុនធំ តូច និងមធ្យម ក្នុងវិស័យជាក់លាក់មួយចំនួនដូចជាអ្នកផ្តល់សេវាបច្ចេកវិទ្យាទំនាក់ទំនង និងព័ត៌មាន កសិឧស្សាហកម្ម ខ្សែច្រវាក់ផ្គត់ផ្គង់ស្បៀងអាហារ និងសុវត្ថិភាពចំណីអាហារនៅក្នុងបណ្តាញផ្គត់ផ្គង់ (ADB, ២០១៧) ។

លើសពីនេះទៀតគោលនយោបាយជាតិស្តីពីជីវេត ឆ្នាំ២០១៧-២០២៥ ដែលត្រូវបានអនុម័តជាផ្លូវការដោយរាជរដ្ឋាភិបាលក្នុងខែមិថុនាឆ្នាំ ២០១៧ មានគោលបំណងជួយលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន និងលើកស្ទួយធនធានមនុស្សរបស់ប្រទេសឱ្យមានសមត្ថភាពនិងជំនាញ ឥរិយាបទក្នុងការងារ ផលិតភាព និងឱកាសការងារ (RGC, ២០១៧)។ ជារួម គោលនយោបាយនេះមានគោលដៅជាយុទ្ធសាស្ត្រចំនួនបួន៖ (១) លើកកម្ពស់គុណភាពជីវេត ដែលអាចឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារជាតិ និងអន្តរជាតិ (២) ដើម្បីជំរុញការទទួលបានជីវេតប្រកបដោយសមធម៌ (៣) លើកទឹកចិត្តដល់ភាពជាដៃគូ រវាងវិស័យសាធារណៈ និងឯកជន (PPPs) ដោយកៀរគរធនធានដើម្បីទ្រទ្រង់និរន្តរភាពហិរញ្ញវត្ថុនៃប្រព័ន្ធជីវេត និង (៤) ដើម្បីលើកកម្ពស់អភិបាលកិច្ចល្អនៃប្រព័ន្ធជីវេត។ គោលនយោបាយនេះផ្តោតសំខាន់ក្នុងការអភិវឌ្ឍជំនាញដល់ពលករទៅតាមការវិវត្តបច្ចេកវិទ្យា ដូចបានបង្ហាញក្នុងផែនការសកម្មភាពយុទ្ធសាស្ត្រសង្ខេបឆ្នាំ២០១៩។

ផែនទីបង្ហាញផ្លូវឧត្តមសិក្សាកម្ពុជា ២០៣០ ផ្តល់នូវទិសដៅសម្រាប់ការអប់រំឆ្នាំ២០៣០ ដែលជាកិច្ចគាំទ្រដើម្បីជំរុញឱ្យសម្រេចបាននូវចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា ជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ ២០៥០។ ជាពិសេស ផែនទីបង្ហាញផ្លូវនេះជាជំនួយដល់ការអភិវឌ្ឍប្រកបដោយចីរភាព តាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច ការធ្វើឱ្យប្រសើរឡើងនូវការប្រកួតប្រជែង និងផលិតកម្មដោយផ្តោតលើគុណភាពសេវាកម្ម និងសេវាអប់រំ ដូចជា ជីវេត និងការសិក្សារយៈពេលយូរដែលរំពឹងទុកក្នុងការផ្តល់ឱកាសដ៏ល្អប្រសើរសម្រាប់យុវជនកម្ពុជា(MoEYS, ២០១៩)។ ការលើកកម្ពស់ ស្តែមសម្រាប់កម្មវិធីសិក្សាថ្មី និងស្ថាប័នអប់រំនៅឧត្តមសិក្សា កំណែទម្រង់កម្មវិធីសិក្សាសម្រាប់ការអប់រំចំណេះទូទៅ និងកំណែទម្រង់លើការបណ្តុះបណ្តាលគ្រូ គឺជារបៀបវារៈដ៏សំខាន់នៃផែនការអភិវឌ្ឍលើវិស័យអប់រំ។ ស្របពេលដូចគ្នានេះ ក្រសួងអប់រំ យុវជន និងកីឡា ក៏ទទួលបានគម្រោងកែលម្អការអប់រំឧត្តមសិក្សារយៈ ៥ ឆ្នាំ ចាប់ពីឆ្នាំ២០១៩ ដោយមានថវិកាសរុប ៩២,៥ លានដុល្លារ។ គម្រោងនេះផ្តោតលើការកែលម្អប្រព័ន្ធអប់រំស្តែម និងការស្រាវជ្រាវនៅក្នុងឧត្តមសិក្សា។ សកម្មភាពសំខាន់ចំនួនបួន ដែលត្រូវបានដាក់នៅក្នុងគម្រោងនេះរួមមាន៖ (១) ការបង្កើនសមត្ថភាពលើការសិក្សានិងការបង្រៀន (២) ការធ្វើឱ្យប្រសើរឡើងលើការស្រាវជ្រាវក្នុង

[2] ឈ្មោះបច្ចុប្បន្នគឺក្រសួងឧស្សាហកម្មវិទ្យាសាស្ត្រ បច្ចេកវិទ្យានិងនវានុវត្តន៍ (MISTI)

វិស័យស្ទែម និងកសិកម្ម (៣) ការពង្រឹងអភិបាលកិច្ចលើវិស័យផ្សេងៗ និងការគ្រប់គ្រងគម្រោង និង (៤) ការឆ្លើយតបទៅស្ថានភាពអាសន្នដែលមិនបានរំពឹងទុកផ្សេងៗ។

កាលពីខែធ្នូ ឆ្នាំ២០១៩កន្លងទៅនេះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា បានអនុម័ត និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវគោលនយោបាយជាតិស្តីពី **វ.ប.ន.** ឆ្នាំ ២០២០-២០៣០។ គោលនយោបាយរយៈពេលវែងនេះ ជាជំនួយដល់ការពង្រឹងមូលដ្ឋានគ្រឹះ និងធ្វើឱ្យប្រសើរឡើងនូវបរិយាកាសសម្រាប់វិស័យ **វ.ប.ន.** ដើម្បីឆ្ពោះទៅកាន់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ដូចបានចែងក្នុងចក្ខុវិស័យរបស់ប្រទេសកម្ពុជាឆ្នាំ ២០៥០។ គោលដៅយុទ្ធសាស្ត្រចម្បងនៃគោលនយោបាយនេះមានបញ្ចូលនូវការអភិវឌ្ឍធនធានមនុស្សនៅក្នុងក្របខ័ណ្ឌ **វ.ប.ន.** និងការពង្រឹងប្រព័ន្ធអេកូឡូស៊ី **វ.ប.ន.** ដើម្បីឱ្យមានភាពប្រសើរឡើងក្នុងការប្រកួតប្រជែងនៅក្នុងប្រទេសលើវិស័យឧស្សាហកម្ម និងសេវាកម្ម (RGC, ២០១៩a)។ ទន្ទឹមនឹងនេះ ការអនុវត្តគោលនយោបាយរយៈពេលវែងនេះ ទាមទារឱ្យមានការចូលរួមជាប្រព័ន្ធពីបណ្តាស្ថាប័នរដ្ឋ ស្ថាប័នឯកជន ក៏ដូចជាស្ថាប័នជាដៃគូផ្សេងៗទៀត។

នៅក្នុងដំណើរនៃការចាប់យកឱកាស ក៏ដូចជាការជំនះរាល់ឧបសគ្គផ្សេងៗដែលកើតចេញពីបរិបទឧស្សាហកម្មជំនាន់ទី៤ រាជរដ្ឋាភិបាលបានរៀបចំក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជាដែលជាក្របខ័ណ្ឌគោលនយោបាយដ៏យូរអង្វែងមួយរបស់ប្រទេសកម្ពុជា។ គោលដៅចម្បងនៃការបង្កើតគោលនយោបាយនេះ គឺធ្វើឡើងដើម្បីជំរុញបច្ចេកវិទ្យាក្នុងស្វ័យប្រវត្តិកម្ម មនុស្សយន្ត និងបញ្ញាសិប្បនិម្មិតដែលត្រូវបានរំពឹងទុកថានឹងផ្តល់ការងារ និងបម្រើឱ្យវិស័យផ្សេងៗ ចាប់ពីវិស័យផលិតកម្ម រហូតដល់សេវាកម្ម (RGC, ២០១៩a)។ ភ្ជាប់ជាមួយផែនការនេះផងដែរ ធាតុសំខាន់ៗមួយចំនួនដែលត្រូវមានជាចាំបាច់នៅក្នុងគោលនយោបាយនេះ មានដូចជាប្រព័ន្ធអប់រំដែលមានប្រសិទ្ធភាពខ្ពស់ ការបណ្តុះបណ្តាលជំនាញការងារ ផែនការអភិវឌ្ឍន៍ធនធានមនុស្ស និងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត(UNDP, ២០១៩)។

ដើម្បីទទួលបាននូវលទ្ធផលពីគោលនយោបាយ និងយុទ្ធសាស្ត្រដែលបានរៀបរាប់ខាងលើ រាជរដ្ឋាភិបាលបានធ្វើការអន្តរាគមន៍ផ្សេងៗដើម្បីជំរុញទៅលើវិស័យ **វ.ប.ន.**។ អន្តរាគមន៍ទាំងនោះរួមមាន ការសហការពិគ្រោះយោបល់ ការផ្តល់ជំនួយបច្ចេកទេស កម្មវិធីបណ្តុះបណ្តាលផ្សេងៗ ការផ្តល់ហិរញ្ញប្បទាន បរិវត្តកម្មឌីជីថល និងការជំរុញលើសកម្មភាពផ្សេងៗដែលពាក់ព័ន្ធទៅនឹងវិស័យ **វ.ប.ន.** ទៅឱ្យសហគ្រាសធុនតូច និងមធ្យម។ ខាងក្រោមនេះ គឺជាអន្តរាគមន៍ចម្បងរបស់រាជរដ្ឋាភិបាល ដើម្បីជាការជ្រោមជ្រែងឱ្យមានប្រព័ន្ធអេកូឡូស៊ី **វ.ប.ន.** នៅកម្ពុជា។

ដោយយោងទៅលើអនុក្រឹត្យលេខ ៩៦ មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" (TSC) ត្រូវបានផ្លាស់ប្តូរទៅជាស្ថាប័នសាធារណៈរដ្ឋបាលនៅថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០២០ ដោយមានបេសកកម្មជួយជ្រោមជ្រែងធុរកិច្ចថ្មីផ្សេងៗលើការពង្រឹងទេពកោសល្យ សហគ្រិនភាព និងសមត្ថភាពនវានុវត្តន៍ ក្នុងគោលបំណងដើម្បីសម្រេចបានជោគជ័យលើអាជីវកម្ម។ ភារកិច្ចនេះជាការបំពេញបន្ថែមដោយផ្ទាល់ទៅលើយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការជួយណែនាំបច្ចេកទេស ជំនួយបច្ចេកទេស ផ្សារភ្ជាប់ការវិនិយោគ ផ្សារភ្ជាប់ជាមួយជំនាញ និងកម្មវិធីបណ្តុះបណ្តាលជំនាញជាក់លាក់ (RGC, ២០២០)។ ដើម្បីសម្រេចបានបេសកកម្មនេះ មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" បានចូលរួមសកម្មភាពផ្សេងៗជាច្រើនដូចជា ការស្រាវជ្រាវពីគោលនយោបាយដើម្បីគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថលនៅកម្ពុជាផងដែរ។ រហូតមកដល់ពេលនេះ មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" បានធ្វើការសិក្សាអំពីទិដ្ឋភាពរួមនៃបច្ចេកវិទ្យាហិរញ្ញវត្ថុ (FinTech) នៅប្រទេសកម្ពុជា ហើយ

មជ្ឈមណ្ឌលនេះក៏នឹងធ្វើការសិក្សាគោលនយោបាយដែលទាក់ទងទៅនឹងប្រព័ន្ធអេកូឡូស៊ីធុរកិច្ចថ្មី និងព័ស្តុការកម្មនៅកម្ពុជាក្នុងពេលឆាប់ៗនេះ។ ក្រៅពីនេះ ដើម្បីគាំទ្រដល់ប្រព័ន្ធអេកូឡូស៊ីធុរកិច្ចថ្មីនៅកម្ពុជា មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" ក៏កំពុងដំណើរការកម្មវិធីពន្លឿនធុរកិច្ចថ្មីនៅកម្ពុជាដែលមានឈ្មោះថា "នវានុវត្តន៍បញ្ច្រាស( Reverse Innovation)" ដើម្បីលើកកម្ពស់ភាពជាដៃគូរវាងវិស័យសាធារណៈនិងឯកជន (សហប្រតិបត្តិការ និងធុរកិច្ចថ្មី)។ នៅក្នុងវិស័យកសិកម្ម មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" កំពុងធ្វើការលើ បច្ចេកវិទ្យាឌីជីថលនិងសហគ្រាសសម្រាប់ខ្សែច្រវាក់តម្លៃផលិតកម្មកសិកម្ម ក្រោមគម្រោងនិរន្តរភាពទ្រព្យសកម្មសម្រាប់ទីផ្សារ ធុរកិច្ច និងពាណិជ្ជកម្មកសិកម្ម (SAAMBAT) ដើម្បីបង្កើតថ្នាលឌីជីថលកសិកម្មខ្មែរ(KAS)។ ថ្នាលឌីជីថលកសិកម្មខ្មែរនឹងជួយកែលម្អសហគ្រាសធុនតូចនិងមធ្យម និងផលិតភាពធុរកិច្ចថ្មី ព្រមទាំងដើរតួជាថ្នាលមួយដើម្បីភ្ជាប់អ្នកពាក់ព័ន្ធទាំងអស់នៅក្នុងព័ស្តុការកម្មកសិកម្ម ដើម្បីផ្តល់ព័ត៌មានអំពីផលិតផលកសិកម្មដល់អ្នកទិញ និងតម្រូវការទីផ្សារដល់អ្នកផ្គត់ផ្គង់។ ដើម្បីកាត់បន្ថយរយៈពេល និងសម្រួលដំណើរការនៃការចុះឈ្មោះធុរកិច្ចថ្មីពីច្រើនខែមកត្រឹមតែ៨ថ្ងៃ មជ្ឈមណ្ឌល បណ្តុះធុរកិច្ចថ្មី "តេជោ" បានបង្កើតការចុះឈ្មោះធុរកិច្ចថ្មីអនឡាញ តាមរយៈថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX) ដែលជាថ្នាលផ្លាស់ប្តូរប្រមូលផ្តុំវិមជ្ឈការទិន្នន័យមួយរវាងប្រព័ន្ធព័ត៌មានប្រកបដោយស្តង់ដារ និងសុវត្ថិភាពក្នុងការផ្តល់ និងប្រើប្រាស់សេវាកម្ម។

ដើម្បីលើកកម្ពស់សហគ្រាសធុនតូច និងមធ្យមឱ្យទទួលបានហិរញ្ញវត្ថុ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ៦៨ ក្នុងឆ្នាំ២០១៩ ដើម្បីបង្កើតធនាគារធុនតូចនិងមធ្យម(SME Bank) ដែលមានដើមទុនវិនិយោគប្រមាណ១០០លានដុល្លារអាមេរិក( RGC, ២០១៩b)។ គំនិតផ្តួចផ្តើមនេះមានគោលបំណងជួយដល់សហគ្រាសក្នុងការដំណើរការកសិ-ឧស្សាហកម្ម និងសហគ្រាសធុនតូចនិងមធ្យម ដែលមានទំនាក់ទំនងជាមួយនឹងការវិនិយោគដោយផ្ទាល់ពីបរទេស វិស័យទេសចរណ៍ និងធុរកិច្ចថ្មីលើវិស័យបច្ចេកវិទ្យា តាមរយៈគម្រោងជានាឥណទាន និងប្រាក់កម្ចីសម្បទានដល់សហគ្រាសធុនតូច និងមធ្យមដែលមានគុណវុឌ្ឍិ(RGC, ២០១៩b)។ ទោះបីជា សេវាកម្មធនាគារមិនមានកំណត់ក៏ដោយ ក៏ធនាគារនោះមានបំណងបង្កើនការទទួលបានឥណទានក្នុងចំណោមសហគ្រាសធុនតូចនិងមធ្យម ដែលមានការលំបាកក្នុងការទទួលបានប្រាក់កម្ចីសម្រាប់អាជីវកម្មរបស់ពួកគេពីធនាគារពាណិជ្ជ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ (MFIs)។ ឧស្សាហកម្មថ្មីដែលមាននវានុវត្តន៍ ឬការបណ្តាក់ទុនលើវិស័យកម្មន្តសាល ដែលមានតម្លៃបន្ថែមខ្ពស់ និងមាតិកាបច្ចេកទេសខ្ពស់ គឺស្ថិតក្នុងចំណោមអាទិភាពកំពូលរបស់ធនាគារ។

សហគ្រិនខ្មែរ(KE) ត្រូវបានបង្កើតឡើងជាអង្គភាពអនុវត្តនៃមូលនិធិអភិវឌ្ឍន៍សហគ្រិនភាពដើម្បីគាំទ្រកម្មវិធី និងធ្វើការដោយផ្ទាល់ជាមួយម្ចាស់ធុរកិច្ច និងសហគមន៍សហគ្រិន។ សហគ្រិនខ្មែរមានគោលបំណងកៀរគរ វិនិយោគ និងគ្រប់គ្រងធនធាន ពីប្រភពស្របច្បាប់ និងផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងធនធានមិនមែនហិរញ្ញវត្ថុដល់តួអង្គពាក់ព័ន្ធនឹងប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាពដែលមានភាពរស់រវើក។ បេសកកម្មសហគ្រិនខ្មែរគឺ៖ (១) គាំទ្រដល់ការកសាងប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាព (២) ផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងធនធានមិនមែនហិរញ្ញវត្ថុដល់ធុរកិច្ចថ្មី និងសហគ្រាសធុនតូចនិងមធ្យម (៣) លើកទឹកចិត្តវិនិយោគិនក្នុងស្រុក និងក្រៅស្រុកឱ្យវិនិយោគក្នុងប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាពនៅកម្ពុជា (៤) លើកទឹកចិត្ត និងជំរុញកំណើននៅក្នុងវិស័យអាទិភាពជាពិសេសបច្ចេកវិទ្យាទំនាក់ទំនងនិងព័ត៌មាន។

ក្រៅពីប្រព័ន្ធអេកូឡូស៊ីអភិវឌ្ឍន៍ **វ.ប.ន.** ក្នុងក្របខ័ណ្ឌជាតិ វេទិកា **វ.ប.ន.** ក្នុងតំបន់ក៏ជាកត្តាជំរុញយ៉ាងសំខាន់សម្រាប់ការផ្លាស់ប្តូរក្នុងស្រុក។ ជាឧទាហរណ៍ នៅក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ាន ស្តីពីវិទ្យាសាស្ត្រ និង

បច្ចេកវិទ្យាអាស៊ាន(AMMST-16)លើកទី១៦ នៅទីក្រុងវៀងចន្ទន៍ ប្រទេសឡាវនៅថ្ងៃទី ៦ ខែវិច្ឆិកាឆ្នាំ ២០១៥ រដ្ឋមន្ត្រីវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាទាំងអស់ដែលជាសមាជិកបានឯកភាពគ្នាលើផែនការសកម្មភាពអាស៊ានលើវិស័យ **វ.ប.ន.** (APASTI) ២០១៦-២០២៥ គួរតែភ្ជាប់មកជាមួយនូវផែនការអនុវត្តន៍។ ផែនការនោះរួមមានវិស័យអាទិភាព គោលដៅឬលទ្ធផលរំពឹងទុក សកម្មភាពជាក់លាក់ រយៈពេលកំណត់សូចនាករដែលបានពីផែនការការងាររបស់អនុគណៈកម្មាធិការនានានៃគណៈកម្មាធិការអាស៊ានផ្នែក **វ.ប.ន.** (COSTI)។ គោលដៅរបស់ ផែនការសកម្មភាពអាស៊ានលើវិស័យ **វ.ប.ន.** គឺប្រើប្រាស់ **វ.ប.ន.** អាស៊ាន ដើម្បីដោះស្រាយបញ្ហាប្រឈមធំៗ នៃសហស្សវត្សរ៍ថ្មីដូចជា៖ សមាហរណកម្មសេដ្ឋកិច្ចអាស៊ាន ភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន ការចល័តអ្នកមានទេពកោសល្យ ការបង្កើនការយល់ដឹងអំពី **វ.ប.ន.** ផលជះនៃ **វ.ប.ន.** កិច្ចសហការស្រាវជ្រាវនិងអភិវឌ្ឍន៍ ការធ្វើពាណិជ្ជកម្មបច្ចេកវិទ្យា ការអភិវឌ្ឍសហគ្រិនភាព និងបណ្តាញមជ្ឈមណ្ឌលឧត្តមភាព។

ទោះជាយ៉ាងណា គោលនយោបាយ និងកម្មវិធីដែលបានរៀបរាប់ខាងលើសម្រាប់វិស័យ **វ.ប.ន.** មានលក្ខណៈជាបំណែក ឬអសង្គតិភាព។ ដោយយល់ដឹងកាន់តែច្បាស់ពីសារៈសំខាន់នៃ **វ.ប.ន.** រាជរដ្ឋាភិបាលបានសម្រេចបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍(MISTI) ដែលត្រូវបានផ្លាស់ប្តូរពីអតីតក្រសួងឧស្សាហកម្ម និងសិប្បកម្ម (MIH) នៅថ្ងៃទី ០៦ ខែមេសាឆ្នាំ ២០២០ តាមរយៈអនុក្រឹត្យលេខ ៤៨ (RGC, ២០២០b)។ ព័ត៌មានលម្អិតអំពីដំណើរការនៃការបង្កើត ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវបានសង្ខេប និងបង្ហាញនៅក្នុង **រូបភាពទី ១**។ ក្រសួងដែលទើបបង្កើតថ្មីនេះបានប្រមូលធនធានមនុស្សនៅក្នុងវិស័យ **វ.ប.ន.** ដើម្បីបណ្តុះបណ្តាល និងបំពាក់បំប៉នឱ្យមានការអភិវឌ្ឍប្រកបដោយបរិយាបន្ន តាមរយៈការសម្របសម្រួលល្អក្នុងចំណោមតួអង្គរាជរដ្ឋាភិបាល ស្ថាប័នអប់រំ វិទ្យាស្ថានស្រាវជ្រាវ វិស័យឯកជន និងដៃគូអភិវឌ្ឍន៍។ ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (**ក.ជ.វ.ប.ន.**) ត្រូវបានបង្កើតតាមរយៈព្រះរាជក្រឹត្យ ទស/រកត/១០២០/១០៧៣ ចុះថ្ងៃទី ១០ ខែតុលា ឆ្នាំ ២០២០ ដែលមានតួនាទីជាអ្នកសម្របសម្រួលសម្រាប់វិស័យ **វ.ប.ន.** ។

## ១.២. គោលបំណង

របាយការណ៍នេះមានគោលបំណងបង្ហាញពី ការអភិវឌ្ឍថ្មីៗនៃប្រព័ន្ធអេកូឡូស៊ី **វ.ប.ន.** របស់ប្រទេសកម្ពុជាជាពិសេសទាក់ទងនឹងការអភិវឌ្ឍគោលនយោបាយ រចនាសម្ព័ន្ធនិងការអនុវត្ត។ ជាពិសេសឯកសារនេះនឹងពិភាក្សាលើប្រធានបទ **វ.ប.ន.** រួមមានការអនុវត្តជាក់ស្តែងរបស់ស្ថាប័នផ្សេងៗ ធនធានមនុស្ស ក្របខ័ណ្ឌច្បាប់ ព្រមទាំងសកម្មភាពនិងលទ្ធផលមួយចំនួនដែលសម្រេចបានដោយតួអង្គពាក់ព័ន្ធផ្សេងៗ។ ការឆ្លុះបញ្ចាំងដែលបានពីការពិភាក្សានៃប្រធានបទខាងលើ គឺជាធាតុចូលដ៏សំខាន់សម្រាប់ការបង្កើតនិងអនុវត្តគោលនយោបាយ **វ.ប.ន.**។ ការអភិវឌ្ឍឆ្ពោះទៅរកចក្ខុវិស័យជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ ២០៥០ ត្រូវមានជំហរយ៉ាងហ្មត់ចត់ក្នុងការធ្វើផែនការ និងការអភិវឌ្ឍលើវិស័យ **វ.ប.ន.**។ ព័ត៌មានដែលបានលើកឡើងមានសារៈប្រយោជន៍ក្នុងការបញ្ជ្រាបពីសារៈសំខាន់នៃ **វ.ប.ន.** ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេស។

## ១.៣. វិធីសាស្ត្រ

ក្រុមការងារ **វ.ប.ន.** ដែលមានប្រវត្តិសិក្សា និងបទពិសោធន៍ផ្សេងៗគ្នាត្រូវបានចាត់តាំងឱ្យផលិតរបាយការណ៍នេះដែលផ្អែកលើវិចារណនិពន្ធន៍ និងវិធីសាស្ត្រពណ៌នាដោយប្រើប្រាស់ទិន្នន័យទុតិយតាពីរបាយការណ៍ផ្លូវការនានារបស់រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍។ អត្ថបទកាលិកបត្រត្រួតពិនិត្យដោយសហវិនិច្ឆយករ ត្រូវបានប្រើប្រាស់ដើម្បីពង្រីក និងផ្ទៀងផ្ទាត់ការពិភាក្សាខាងលើ។ ការពិភាក្សាក្នុងចំណោមសមាជិកក្រុម និងការពិភាក្សាជាមួយក្រុមគោលដៅត្រូវបានធ្វើឡើងជាបន្តបន្ទាប់ដើម្បីជានាការវិភាគមានភាពគ្រប់គ្រាន់ និងមានតុល្យភាពប្រកបដោយគុណភាពផ្អែកលើតថភាព និងភ័ស្តុតាង (សូមមើលឧបសម្ព័ន្ធ ១)។ ការវិភាគអំពីប្រព័ន្ធអេកូឡូស៊ីអភិវឌ្ឍន៍ **វ.ប.ន.** ទាក់ទងនឹងវិស័យកម្មន្តសាល នៅកម្ពុជាត្រូវបានធ្វើឡើងជាលើកដំបូងបន្ទាប់ពីមានការអនុម័តឱ្យបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៅថ្ងៃទី ២៦ ខែមីនា ឆ្នាំ ២០២០។

ចាប់ផ្តើម

**២ មីនា ២០២០**

កិច្ចប្រជុំក្រៅផ្លូវការជាមួយមន្ត្រីដែលត្រូវបានជ្រើសរើសចំនួន ១៦ នាក់ដឹកនាំដោយ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

**១៣ មីនា ២០២០**

រដ្ឋសភាបានអនុម័តច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៅក្នុងសម័យប្រជុំវិសាមញ្ញរបស់រដ្ឋសភានីតិកាលទី៦

**២៣ មីនា ២០២០**

ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជាបានពិនិត្យឡើងធម្មនុញ្ញភាព និងច្បាប់នៅឯសម័យប្រជុំវិសាមញ្ញក្នុងអាណត្តិទី៤

**២៥ មីនា ២០២០**

ក្រុមប្រឹក្សាធម្មនុញ្ញនៃប្រទេសកម្ពុជាបានប្រកាសអនុលោមតាមរដ្ឋធម្មនុញ្ញជាតិនៅក្នុងសេចក្តីប្រកាស ២០១/០០១/២០២០ កបធ.ច

**២៦ មីនា ២០២០**

ព្រះករុណាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាបានឡាយព្រះហស្ថលេខាលើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងព្រះរាជក្រម នស/រកម/០៣២០/០០៩

**៦ មេសា ២០២០**

រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ក្នុងអនុក្រឹត្យលេខ ៤៨ អ.ន.ក្រ.ក.ប

**១០ មេសា**

កិច្ចប្រជុំក្រៅផ្លូវការសម្រាប់រចនាសម្ព័ន្ធនៃអគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងវិទ្យាស្ថានជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ក្រោមការជ្រើសរើសមន្ត្រីចំនួន ១៦ នាក់ដឹកនាំដោយ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

**១៦ តុលា ២០២០**

**ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានជួបមន្ត្រីទើបជ្រើសរើសថ្មី ចំនួន ៤៥ នាក់ ដែលមានជំនាញ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

**រូបភាពទី ១៖ ព្រឹត្តិការណ៍ជាសារវតារ នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

## ២. ប្រព័ន្ធអេកូឡូស៊ី វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

### ២.១. មូលនិធិ និងហិរញ្ញវត្ថុ

### មូលនិធិស្រាវជ្រាវនិងអភិវឌ្ឍន៍

**តើអ្វីទៅជាការស្រាវជ្រាវ និងអភិវឌ្ឍន៍ ?**

យោងតាមអង្គការសម្រាប់កិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច(OECD, ២០១៦) ការស្រាវជ្រាវ និងអភិវឌ្ឍន៍ (R&D) ត្រូវបានបែងចែកជាបីប្រភេទ៖ (១) ការស្រាវជ្រាវមូលដ្ឋានគ្រឹះ (២) ការស្រាវជ្រាវអនុវត្ត (៣)ការអភិវឌ្ឍបែបពិសោធន៍។ ការស្រាវជ្រាវមូលដ្ឋានគ្រឹះ មានគោលបំណងបង្កើតនូវពុទ្ធិថ្មីៗ ដោយមិនរាប់បញ្ចូលពីការអនុវត្តជាក់ស្តែងនោះទេ។ ដោយឡែកការស្រាវជ្រាវអនុវត្ត រាប់បញ្ចូលទាំងការបង្កើតនូវពុទ្ធិថ្មីៗ និងការអនុវត្តជាក់ស្តែងផងដែរ។ លើសពីនេះ ការអភិវឌ្ឍបែបពិសោធន៍ផ្តោតលើការអភិវឌ្ឍផលិតផល (ទាំងទំនិញ និងសេវាកម្ម) ឬដំណើរការថ្មីៗ។

**តើហេតុអ្វី បានជាមូលនិធិស្រាវជ្រាវនិងអភិវឌ្ឍន៍មានសារៈសំខាន់សម្រាប់កម្ពុជា ?**

ប្រទេសកម្ពុជាបានឆ្លងកាត់ការផ្លាស់ប្តូរស្ថានភាពចំណូល ក្នុងរយៈពេលច្រើនជាង២០ឆ្នាំមកហើយ និងបានឈានដល់ស្ថានភាពដែលមានចំណូលមធ្យមកម្រិតទាបនៅឆ្នាំ២០១៥ (APO, ២០១៨)។ ដោយមានការគិតគូរលើការផ្លាស់ប្តូរស្ថានភាពចំណូលនេះ ប្រទេសកម្ពុជាមានទស្សនវិស័យបន្តបន្ទាប់គ្នាចំនួន២ ដើម្បីប្រែក្លាយខ្លួនទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ ទស្សនវិស័យទាំងនេះត្រូវតែតម្រូវឱ្យប្រទេសកម្ពុជាបំប្លែងខ្លួនទៅជាសង្គមដែលមានពុទ្ធិជាមូលដ្ឋានគ្រឹះដោយមិនអាចខ្វះបានសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច។ សេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិ អាស្រ័យលើ នវានុវត្តន៍ (Savrul & Incekara, ២០១៥)។ នវានុវត្តន៍ កើតមានទៅបាន អាស្រ័យលើការបង្កើតចំណេះដឹង និងការប្រើប្រាស់សមិទ្ធផលនៃការស្រាវជ្រាវនិងអភិវឌ្ឍន៍ (Nair et al., ២០២០; Olaoye et al., ២០២០; Sokolov-Mladenović et al., ២០១៦)។ ការសិក្សាមួយបានបញ្ជាក់ថា ការស្រាវជ្រាវនិងអភិឌ្ឍន៍បានបង្កើតឱ្យមាននវានុវត្តន៍ក្នុងទម្រង់ជាផលិតផលនិងដំណើរការថ្មីៗជាច្រើន (Whitehouse, ១៩៩៥)។ ផលិតផលថ្មីៗនឹងជួយធ្វើឱ្យជីវភាពកាន់តែប្រសើរឡើង ដោយឡែកដំណើរការថ្មីៗនឹងអាចជួយក្រុមហ៊ុន សហគ្រាស  កាត់បន្ថយថ្លៃផលិតកម្ម និងកាន់តែមានភាពប្រកួតប្រជែង។ ជាការពិតណាស់ ការបង្កើននូវផលិតភាព គឺជាកត្តាចម្បងសម្រាប់ធ្វើឱ្យកម្រិតជីវភាពកាន់តែខ្ពស់ និងការរីកចម្រើនសេដ្ឋកិច្ចកាន់តែមានភាពថ្កុំថ្កើង ដែលស្របទៅនឹងទស្សនវិស័យកម្ពុជាឆ្នាំ២០៣០ និងឆ្នាំ២០៥០។ ហេតុដូចនេះ មូលនិធិស្រាវជ្រាវនិងអភិវឌ្ឍន៍ នឹងជំរុញឱ្យកើតមាននូវនវានុវត្តន៍ និងរួមចំណែកយ៉ាងសំខាន់ សម្រាប់ដំណើររបស់ប្រទេសកម្ពុជាឆ្ពោះទៅកាន់ទស្សនវិស័យ ឆ្នាំ២០៣០ និងឆ្នាំ២០៥០។

**តើមូលនិធិស្រាវជ្រាវនិងអភិវឌ្ឍន៍ នៅប្រទេសកម្ពុជាមានកម្រិតណា ?**

សារៈសំខាន់នៃ **វ.ប.ន.** ក្នុងការកំណត់ភាពជោគជ័យនៃទស្សនវិស័យឆ្នាំ២០៣០ និងឆ្នាំ២០៥០ តែងតែត្រូវបានលើកឡើងឥតឈប់ឈរ នៅក្នុងឯកសារសំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចជា៖ គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ (RGC, ២០១៥) យុទ្ធសាស្ត្រចតុកោណដំណាក់កាល

ទី៤ ឆ្នាំ២០១៨-២០២៣ (RGC, ២០១៨) និងគោលនយោបាយជាតិ ស្តីពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឆ្នាំ២០២០-២០៣០ (RGC, ២០១៩)។ ទោះបីជាមានការយកចិត្តទុកដាក់យ៉ាងខ្លាំង លើសារៈសំខាន់នៃ **វ.ប.ន.** បែបនេះក៏ដោយ ការបែងចែកចំណាយមូលនិធិជាតិសម្រាប់សកម្មភាពការស្រាវជ្រាវនិងអភិវឌ្ឍន៍មិនទាន់បានរំលេចឡើងនៅក្នុងឯកសាររាជរដ្ឋាភិបាលទាំងអស់នោះនៅឡើយទេ។ ផ្ទុយទៅវិញ ប្រភពឯកសារផ្សេងៗជាច្រើនបានរាយការណ៍ពីព័ត៌មាន និងទិន្នន័យមួយចំនួនស្តីពីការចំណាយលើការស្រាវជ្រាវនិងអភិវឌ្ឍន៍នៅប្រទេសកម្ពុជា។ លិខិតលេខ ៨០ ស.ជ.ណ.ជ.ស ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ចេញដោយទីស្តីការគណៈរដ្ឋមន្ត្រី បានសម្រេចឱ្យប្រើប្រាស់មូលធិនិ នៃផលិតផលក្នុងស្រុកសរុប (GDP) ចំនួន ០,១ភាគរយនៅឆ្នាំ២០២០ និង ០,៤ភាគរយ នៅឆ្នាំ២០២៥ សម្រាប់ការចំណាយលើការស្រាវជ្រាវនិងអភិវឌ្ឍន៍នៅប្រទេសកម្ពុជា (OCM, ២០១៧)។ យោងតាមវិទ្យាស្ថានស្ថិតិនៃអង្គការយូណេស្កូ ការចំណាយសរុបលើការស្រាវជ្រាវនិងអភិវឌ្ឍន៍នៅប្រទេសកម្ពុជា គឺត្រឹមតែ ០,១២ភាគរយ នៅឆ្នាំ២០១៥ តែប៉ុណ្ណោះ (UNESCO, ២០១៥)។ លើសពីនេះទៅទៀត តាមប្រភពព័ត៌មានរបស់ភ្នំពេញប៉ុស្តិ៍នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ ២០១៨ (Spiess, ២០១៨)បានបង្ហាញថា **សម្តេចតេជោ នាយករដ្ឋមន្ត្រី** បានសន្យា និងប្តេជ្ញាចិត្តថាប្រទេសកម្ពុជានឹងបង្កើនកម្រិតមូលនិធិសម្រាប់វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាឱ្យបាន ០,២០ភាគរយ នៃផលិតផលក្នុងស្រុកសរុបនៅឆ្នាំ២០២០ ១,០ភាគរយ នៅឆ្នាំ២០២៥ និង១,៥០ភាគរយនៅឆ្នាំ២០៣០។ ទោះបីជាយ៉ាងណាក៏ដោយការវិភាជថវិកាលើការស្រាវជ្រាវនិងអភិវឌ្ឍន៍ នៅមិនទាន់បានអនុវត្តជាក់ស្តែងដែលអាចវាស់វែងបានទេ។

### តើមូលនិធិស្រាវជ្រាវនិងអភិវឌ្ឍន៍នៅប្រទេសកម្ពុជាមានកម្រិតណាប្រសិនជាប្រៀបធៀបជាមួយប្រទេសដទៃ?

កម្រិតនៃមូលនិធិស្រាវជ្រាវនិងអភិវឌ្ឍន៍នៅប្រទេសកម្ពុជា និងប្រទេសសមាជិកអាស៊ាន នៅឆ្នាំ២០១៥ មានបង្ហាញនៅ **រូបភាពទី ២** ដោយយោងតាមទិន្នន័យពីវិទ្យាស្ថានស្ថិតិ នៃអង្គការយូណេស្កូ (UNESCO, ២០២០)។ គួរបញ្ជាក់ផងដែរថា មិនមានទិន្នន័យពីប្រទេសព្រុយណេ ឥណ្ឌូណេស៊ី ឡាវ និងមីយ៉ាន់ម៉ាទេ។ ហើយ **រូបភាពទី ២** ក៏បានរំលេចឱ្យឃើញថា ប្រទេសកម្ពុជាមានការចំណាយទាបជាងគេលើការស្រាវជ្រាវនិងអភិវឌ្ឍន៍ ក្នុងចំណោមប្រទេសសមាជិកអាស៊ានទាំងនោះ។ ដោយឡែកនៅក្នុងតំបន់អាស៊ាន ប្រទេសសិង្ហបុរី និងម៉ាឡេស៊ី គឺជាប្រទេសដែលមានការចំណាយខ្ពស់ជាងគេបំផុតលើការស្រាវជ្រាវនិងអភិវឌ្ឍន៍។ ហើយកម្រិតនៃការចំណាយលើការស្រាវជ្រាវនិងអភិវឌ្ឍន៍របស់ប្រទេសកម្ពុជា(០,១២ ភាគរយ) គឺទាបជាង បីដង នៃមធ្យមភាគរបស់ក្រុមប្រទេសដែលមានចំណូលមធ្យមកម្រិតទាប (០,៤៣ ភាគរយ) និងទាបជាងប្រាំមួយដងនៃមធ្យមភាគរបស់ប្រទេសជាសមាជិកអាស៊ានទាំងអស់ នៅឆ្នាំ២០១៥ (ឧបសម្ព័ន្ធ ២)។ ក្នុងន័យនេះបានបញ្ជាក់យ៉ាងច្បាស់លាស់ថាប្រទេសកម្ពុជាត្រូវតែចំណាយបន្ថែមនូវមូលនិធិស្រាវជ្រាវនិងអភិវឌ្ឍន៍ឱ្យបានកាន់តែលឿនកាន់តែប្រសើរ ប្រសិនបើប្រទេសកម្ពុជាមានគោលបំណងពង្រីកវិសាលភាពលើវិស័យ **វ.ប.ន.** ដែលជាមធ្យោបាយចាំបាច់សម្រាប់ការលូតលាស់ និងការអភិវឌ្ឍសេដ្ឋកិច្ច។




**រូបភាពទី ២៖ ការចំណាយលើការស្រាវជ្រាវនិងអភិវឌ្ឍន៍របស់ប្រទេសជាសមាជិកអាស៊ាននៅឆ្នាំ២០១៥។ ពុំមានទិន្នន័យទទួលបានពីប្រទេសព្រុយណេ ឥណ្ឌូណេស៊ី ឡាវ និងមីយ៉ាន់ម៉ានោះទេ។ (ប្រភព៖ វិទ្យាស្ថានស្ថិតិនៃអង្គការយូណេស្កូ)**

**ធនធានមនុស្ស**

ប្រទេសកម្ពុជាត្រូវបានមើលឃើញថាសម្បូរឱកាសការងារ ក៏ប៉ុន្តែកម្លាំងពលកម្មក្នុងប្រទេសភាគច្រើនជាបុគ្គលិកកម្មករ ដែលគ្មានជំនាញ ឬមានជំនាញតិចតួច ក្នុងវិស័យកសិឧស្សាហកម្ម និងឧស្សាហកម្មសំណង់ជាអាទិ៍។ ក្នុងបរិបទបរិវត្តកម្មបច្ចេកវិទ្យា និងវានុវត្តន៍ អ្វីដែលគួរតែយកចិត្តទុកដាក់បំផុត គឺការពង្រឹងកម្លាំងពលកម្មឱ្យមានសមត្ថភាពលើផ្នែកកិរិយាសម្បទា។ ដើម្បីដោះស្រាយបញ្ហាទាំងនេះ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតគោលនយោបាយជាតិ ស្ដីពីការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ(ធីវេត) ឆ្នាំ២០១៧-២០២៥ ដោយមានគោលដៅដើម្បីជំរុញឱ្យមានភាពជាដៃគូរវាងវិស័យសាធារណៈនិងឯកជន និងដើម្បីកៀរគរធនធានឱ្យបានច្រើនថែមទៀតពីតួអង្គពាក់ព័ន្ធសម្រាប់ជួយគាំទ្រធីវេត (ADB, ២០១៧)។

ជាការពិតណាស់ កម្លាំងពលកម្មដែលមានកម្រិតអប់រំខ្ពស់ នឹងអាចអភិវឌ្ឍសេដ្ឋកិច្ចជាតិឱ្យកាន់តែរីកចម្រើនប្រកបដោយភាពថ្កុំថ្កើង។ កម្រិតអប់រំរបស់ប្រជាជនក្នុងប្រទេសនីមួយៗ មានសារៈសំខាន់ខ្លាំងណាស់សម្រាប់វិស័យសាធារណៈ និងវិស័យឯកជន ជាពិសេសកម្លាំងពលកម្មនៅក្នុងផ្នែក **វ.ប.ន.** បុគ្គលិកជំនាញមានសារៈសំខាន់សម្រាប់ប្រទេសក្នុងការសម្របខ្លួនបានលឿនស្របទៅនឹងបរិវត្តកម្មនៃតម្រូវការវិទ្យាសាស្ត្រ និងបច្ចេកទេសនៅក្នុងទីផ្សារការងារ។ **រូបភាពទី ៣** បង្ហាញពីលទ្ធផលស្ទង់មតិ ស្ដីពីការទទួលបានការអប់រំនៃកម្លាំងពលកម្មដែលមានអាយុចាប់ពី ១៥ ដល់ ៦៤ឆ្នាំ នៅឆ្នាំ២០១៥។ ៥,៤ ភាគរយ នៃកម្លាំងពលកម្មទាំងពីរភេទបានទទួលវគ្គបណ្ដុះបណ្ដាលបច្ចេកទេសកម្រិតខ្ពស់ ឬការអប់រំកម្រិតវិទ្យាល័យ។ ប្រសិនជាប្រៀបធៀបកម្លាំងពលកម្មដែលទទួលបានការអប់រំកម្រិតអនុវិទ្យាល័យគឺមានចំនួន ១,៤ ភាគរយ ច្រើនជាងកម្រិតវិទ្យាល័យ (MoP, ២០១៦)។ កម្លាំងពលកម្មដែលអាចបញ្ចប់ការសិក្សានៅមានកម្រិត ដោយសារខ្វះការយល់

ដឹងពីសារៈសំខាន់នៃ **វ.ប.ន.** ហើយការខ្វះខាតនេះគឺជាបញ្ហាប្រឈមចំពោះបុគ្គលម្នាក់ៗ អាណាព្យាបាល និងសហគមន៍។




**រូបភាពទី ៣៖ ការបញ្ចប់ការសិក្សាគិតជាភាគរយនៃកម្លាំងពលកម្មដែលមានអាយុចាប់ពី១៥ ដល់៦៤ឆ្នាំ នៅឆ្នាំ២០១៥**

ជីវេត ទទួលបានមូលនិធិចម្បង ពីជំនួយរបស់រាជរដ្ឋាភិបាល ម្ចាស់ជំនួយបរទេស និងវិស័យឯកជន។ យោងតាមទីភ្នាក់ងារអភិវឌ្ឍន៍បារាំង (AFD) ជីវេតនៅកម្ពុជាពុំទទួលបានមូលនិធិគ្រប់គ្រាន់ទេ ប្រសិនបើប្រៀបធៀបជាមួយប្រទេសជិតខាង (Christine, ២០១៩)។ ថ្មីៗនេះ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានផ្តល់ប្រាក់កម្ចីប្រហែល ១០០ លានដុល្លារអាមេរិក ដើម្បីចាប់ផ្តើមគម្រោង ស្តីពី «គម្រោងប្រកួតប្រជែងជំនាញ» ដើម្បីធ្វើឱ្យជីវេតមានភាពប្រសើរឡើងតាមរយៈក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ វិសិដ្ឋកម្មជំនាញសម្រាប់មហាវិទ្យាល័យ និងសាកលវិទ្យាល័យតាមរយៈការធ្វើឱ្យប្រសើរឡើងនូវមន្ទីរពិសោធន៍វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នៅតាមបណ្តាគ្រឹះស្ថានឧត្តមសិក្សា និងសាលាជីវេត បានបង្កើតឡើងដើម្បីបំពេញតម្រូវការក្នុងវិស័យកម្មន្តសាលនាពេលអនាគត (ADB, ២០១៨)។ លើសពីនេះ ធនាគារអភិវឌ្ឍន៍អាស៊ីដើរតួនាទីសំខាន់ក្នុងការជំរុញកម្លាំការងារឱ្យកាន់តែប្រសើរឡើងថែមទៀត ស្របពេលដែលគម្រោងកែលម្អការអប់រំឧត្តមសិក្សា (HEIP) ដែលមានមូលនិធិ ៩២,៥ លានដុល្លារអាមេរិក ត្រូវបានអនុវត្តដោយក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ការអភិវឌ្ឍស្នែមនៅក្នុងវិស័យឧត្តមសិក្សា។ គម្រោងនេះទទួលបានកម្ចីពីធនាគារពិភពលោក ហើយមានគោលបំណងដោះស្រាយនូវធនធានមនុស្សដែលមានជំនាញខ្ពស់ តាមរយៈការស្រាវជ្រាវនិងអភិវឌ្ឍន៍ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។ ក្រៅពីនេះ ការស្រាវជ្រាវនិងអភិវឌ្ឍន៍សម្រាប់បច្ចេកវិទ្យាទូរគមនាគមន៍ និងបច្ចេកវិទ្យាទំនាក់ទំនងនិងព័ត៌មាន ត្រូវបានអនុវត្តដោយមូលនិធិកសាងសមត្ថភាពស្រាវជ្រាវនិងអភិវឌ្ឍន៍(CBRDF) តាមរយៈក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដោយមានសកម្មភាពផ្តួចផ្តើមតាំងពីឆ្នាំ២០១៧។ ថវិកាច្រើនលានដុល្លារអាមេរិក ត្រូវបានផ្តល់ជារៀងរាល់ឆ្នាំសម្រាប់ប្រើប្រាស់លើសកម្មភាពមួយចំនួនដែលបានអនុម័តដោយក្រុមប្រឹក្សាមូលនិធិ។

លើសពីនេះទៅទៀត ដើម្បីប្រើប្រាស់ធនធានពីតួអង្គពាក់ព័ន្ធ រាជរដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រេចបង្កើតផែនការមួយចំនួន ដើម្បីគាំទ្រសកម្មភាពពាក់ព័ន្ធនឹងវិស័យ **វ.ប.ន.**

ដូចជាធនាគារសហគ្រាសធុនតូចនិងមធ្យម មជ្ឈមណ្ឌលធុរកិច្ចថ្មី "តេជោ" សហគ្រិនខ្មែរ និងមូលនិធិអភិវឌ្ឍន៍ជំនាញ (SDF) (ADB, ២០១៨)។ ឧទាហរណ៍ មូលនិធិអភិវឌ្ឍន៍ជំនាញត្រូវបានបង្កើតឡើងជាប្រេកសម្រាប់ទទួលមូលនិធិពីបរទេស ឬពីប្រភពផ្សេងៗដែលពុំមែនជាមូលនិធិរបស់រាជរដ្ឋាភិបាល ដើម្បីការអភិវឌ្ឍជំនាញផលិតភាព។ ការបង្កើតផែនការនេះមានគោលបំណងបង្កើននូវបរិមាណនៃផលិតភាព ការប្រកួតប្រជែង និងចំណូលរបស់សហគ្រាស និងបុគ្គលដែលស្ថិតក្នុងវិស័យ **វ.ប.ន.** ព្រមទាំងវិស័យផ្សេងៗទៀត ដោយការបង្រៀនហ្វឹកហាត់និងផ្តល់ជំនាញដែលជាតម្រូវការចាំបាច់ (Christine, ២០១៩)។ មូលនិធិអភិវឌ្ឍន៍ជំនាញជាសហមូលនិធិគម្រោង ដែលបានមកពីរាជរដ្ឋាភិបាលជាប្រចាំឆ្នាំ ចំនួន ៥ លានដុល្លារអាមេរិក និង ៩,៦ លានដុល្លារអាមេរិកបានមកពីធនាគារអភិវឌ្ឍន៍អាស៊ី (Kruy, ២០២០)។

ការវាយតម្លៃរួមលើការវិនិយោគមូលនិធិ និងហិរញ្ញវត្ថុសម្រាប់វិស័យ **វ.ប.ន.** នៅមានកម្រិត ប្រសិនជាធៀបនឹងប្រទេសជិតខាង ហើយស្ថិតនៅឆ្ងាយខ្លាំងពីប្រទេសរីកចម្រើនដទៃទៀតដូចជា ប្រទេសអ៊ីស្រាអែល សាធារណរដ្ឋកូរ៉េ ចិន និងជប៉ុន។ ការណ៍នេះក៏បានបញ្ជាក់ពីការធ្វើវិភាជ និងការគ្រប់គ្រងធនធាននៅមានភាពបាក់បែកគ្នាដោយផ្នែក។ ហេតុដូចនេះ ស្ថាប័នសម្របសម្រួលរឹងមាំមួយត្រូវបានផ្តល់អនុសាសន៍ឱ្យបង្កើតឡើងជាចាំបាច់ ដើម្បីធ្វើសមាហរណកម្មសកម្មភាពដែលមានក្របខ័ណ្ឌគ្រប់គ្រងច្បាស់លាស់សម្រាប់ការត្រួតពិនិត្យ និងវាយតម្លៃ និងបង្កើតឱ្យមានការទទួលខុសត្រូវលើការធ្វើវិភាជហិរញ្ញវត្ថុ។

## ២.២. ហេដ្ឋារចនាសម្ព័ន្ធ

ហេដ្ឋារចនាសម្ព័ន្ធ ជាទូទៅត្រូវបានកំណត់ជាសេវាកម្មសាធារណៈ ដូចជា ផ្លូវថ្នល់ ការផ្គត់ផ្គង់ថាមពលអគ្គិសនី ប្រព័ន្ធលូទឹកកខ្វក់ បរិក្ខារមន្ទីរពិសោធន៍ មជ្ឈមណ្ឌលស្រាវជ្រាវ បណ្តាញទូរស័ព្ទ និងបំពង់ទឹក បណ្តាញ ជាអាទិ៍។ នៅដើមសតវត្សរ៍ទី២០ និយមន័យទូទៅនៃហេដ្ឋារចនាសម្ព័ន្ធ សំដៅលើបណ្តាញទ្រព្យសកម្មដែលសមាសភាពរបស់វានឹងត្រូវថែទាំតាមរយៈការផ្លាស់ប្តូរ និងការជួសជុលឡើងវិញ។

ហេដ្ឋារចនាសម្ព័ន្ធ **វ.ប.ន.** គឺជាប្រព័ន្ធមូលដ្ឋានគ្រឹះដែលទ្រទ្រង់ និងដឹកនាំប្រព័ន្ធអេកូឡូស៊ី **វ.ប.ន.**។ ហេដ្ឋារចនាសម្ព័ន្ធ មានទម្រង់ជាបច្ចេកវិទ្យាហេដ្ឋារចនាសម្ព័ន្ធចម្រុះជាច្រើនប្រភេទដែលមានស្តង់ដារសំខាន់សម្រាប់ការស្រាវជ្រាវនិងអភិវឌ្ឍន៍ ការគ្រប់គ្រងដំណើរការផលិតកម្ម ដើម្បីធានាគុណភាពនិងផលិតផល ហើយចុងបញ្ចប់ធ្វើឱ្យមានចរន្តទីផ្សារ សម្រាប់ផលតិផលសាំញ៉ាំ(Tassey, ២០០៨)។ វិស័យអប់រំ ជាវិស័យដែលមានការយកចិត្តទុកដាក់ខ្ពស់នាអំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ឧទាហរណ៍ គម្រោងកែលម្អការអប់រំឧត្តមសិក្សា និងការធ្វើឱ្យប្រសើរឡើងនូវជីវេត ត្រូវបានអនុវត្ត។ គ្រឹះស្ថានឧត្តមសិក្សាដែលមានសក្តានុពលមួយចំនួន និងមានបង្រៀនមុខវិជ្ជាស្ទែមត្រូវបានជ្រើសរើសសម្រាប់ការអនុវត្តគម្រោងកែលម្អការអប់រំឧត្តមសិក្សា ដូចជាសាកលវិទ្យាល័យភូមិន្ទភ្នំពេញ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា សាកលវិទ្យាល័យភូមិន្ទកសិកម្ម សាកលវិទ្យាល័យជាតិបាត់ដំបង និងសាកលវិទ្យាល័យស្វាយរៀង ខណៈពេលដែលគម្រោងជីវេត ត្រូវបានអនុវត្តជាចម្បងដោយបណ្តាសាលាជីវេត ដែលស្ថិតក្រោមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ គម្រោងកែលម្អការអប់រំឧត្តមសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា ផ្តោតការយកចិត្តទុកដាក់លើចលករសំខាន់ៗមួយចំនួន ដូចជា ការបង្កើនចំណាប់អារម្មណ៍របស់ សិស្ស-និស្សិត ទៅលើមុខវិជ្ជាស្ទែមចាប់តាំងពីអនុវិទ្យាល័យរហូតដល់សាកលវិទ្យាល័យ ការលើកទឹកចិត្តដល់អ្នកស្រាវជ្រាវនៅសាកលវិទ្យាល័យ និងការបង្កើតមជ្ឈមណ្ឌលឧត្តមភាព។

ស្ថាប័ន និងក្របខ័ណ្ឌសមស្របត្រូវតែបង្កើតឡើងដើម្បីគាំទ្រដល់សេដ្ឋកិច្ចថ្មីដែលពឹងផ្អែកលើបច្ចេកវិទ្យា។ ក្នុងគោលបំណងដើម្បីធ្វើបរិវត្តកម្មសេដ្ឋកិច្ចនេះ រាជរដ្ឋាភិបាលបានយល់ច្បាស់សារៈសំខាន់នៃតួនាទី **វ.ប.ន.** ក្នុងការធ្វើឱ្យសេដ្ឋកិច្ចជាតិមានភាពរីកចម្រើន។ ការផ្តួចផ្តើមឱ្យមានហេដ្ឋារចនាសម្ព័ន្ធត្រូវបានបង្កើតឡើងដោយមានតួនាទីនិងភារកិច្ចច្បាស់លាស់។ ជាការពិតណាស់ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ទើបតែត្រូវបានប្តូរពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងពេលនៃការរីកដាលជំងឺកូវីដ ១៩ ដោយសារតម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមនៅប្រទេសកម្ពុជា។ លើសពីនេះទៅទៀត ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក៏ទើបបានក្លាយជាស្ថាប័នជាតិដែលទទួលខុសត្រូវលើដំណើរការ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (**ក.ជ.វ.ប.ន.**) ដែលបានបង្កើតឡើងនៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០ ផងដែរ។

**ក.ជ.វ.ប.ន.** មានតួនាទីសំខាន់ក្នុងការសម្របសម្រួលក្រសួង-ស្ថាប័នពាក់ព័ន្ធដើម្បីធ្វើការងាររួមគ្នាសម្រាប់គោលដៅរួមលើវិស័យ **វ.ប.ន.** ដែលជាឆ្អឹងខ្នងនៃការរីកចម្រើនសេដ្ឋកិច្ច សង្គមនិងបរិស្ថានរបស់ប្រទេសកម្ពុជា។ លើសពីនេះ ការគាំទ្រឱ្យមានហេដ្ឋារចនាសម្ព័ន្ធគឺមានសារៈសំខាន់ណាស់ដើម្បីរៀបចំយន្តការដែលធ្វើឱ្យមានអន្តរកម្មល្អ ការចូលរួមរវាងរដ្ឋាភិបាល វិស័យឯកជន និងស្ថាប័នសិក្សាស្រាវជ្រាវ។

តួនាទីសមាសធាតុហេដ្ឋារចនាសម្ព័ន្ធ **វ.ប.ន.** ដែលមានស្រាប់ និងទើបបង្កើតថ្មី ត្រូវបានបង្ហាញនៅក្នុង **តារាងទី ១**។ តារាងនេះ នឹងពិពណ៌នាខ្លីពីស្ថាប័នដែលដើរតួនាទីសំខាន់សម្រាប់សកម្មភាពនីមួយៗ នៃប្រព័ន្ធអេកូឡូស៊ី **វ.ប.ន.**។

**តារាងទី ១៖ ហេដ្ឋារចនាសម្ព័ន្ធវិស័យ វ.ប.ន. នៅក្នុងប្រទេសកម្ពុជា**

| វិស័យ វ.ប.ន. | ស្ថាប័នពិនិត្យ & អនុម័ត | ស្ថាប័នចូលរួម ឬ ពាក់ព័ន្ធ | ស្ថាប័នសម្របសម្រួល | ស្ថាប័នអនុវត្តន៍ |
|---|---|---|---|---|
| **វិទ្យាសាស្ត្រ និងការអប់រំវិស័យវ.ប.ន.** | | | | |
| ទិដ្ឋភាពវិទ្យាសាស្ត្រនិងការទទួលបានអត្ថបទបោះពុម្ពផ្សាយ | **ក.ជ.វ.ប.ន.** | MoEYS, MoLVT, MoH, MAFF, MISTI, CDRI, AVI | MoEYS, MISTI | MoEYS, CDRI |
| គាំទ្រដល់អ្នកវិទ្យាសាស្ត្រ ឬ សកម្មភាពស្រាវជ្រាវនិងអភិវឌ្ឍន៍ | **ក.ជ.វ.ប.ន.** | MoEYS, MISTI, MAFF, MEF, MoH | **ក.ជ.វ.ប.ន.**, MEF | MoEYS, MISTI, MAFF, MoH, មជ្ឈមណ្ឌលស្រាវជ្រាវនិងក្រុមហ៊ុនឯកជន |

| | | | | |
|---|---|---|---|---|
| ការអប់រំស្វែម និងជីវិត | **ក.ជ.វ.ប.ន.** | MoEYS, MoLVT, MAFF, MoH, MISTI, MPTC | MoEYS, MoLVT | MoEYS, MoLVT, MAFF, MoH, MPTC, ស្ថាប័នឯកជន |
| **បច្ចេកវិទ្យា** | | | | |
| ហេដ្ឋារចនាសម្ព័ន្ធដែលពឹងផ្អែកលើបច្ចេកវិទ្យា | **ក.ជ.វ.ប.ន.** | MISTI, MoEYS, MAFF, MPTC | **ក.ជ.វ.ប.ន.**, MEF | MISTI, MoEYS, MAFF, MPTC, ក្រសួង ឬក្រុមហ៊ុនពាក់ព័ន្ធ |
| បច្ចេកវិទ្យា សម្រាប់ខ្នាតឧស្សាហកម្ម | **ក.ជ.វ.ប.ន.** | MISTI, CDC | MISTI | MoEYS, ឧស្សាហកម្មផ្សេងៗ |
| បច្ចេកវិទ្យាខ្នាតតូច | **ក.ជ.វ.ប.ន.** | MISTI | MISTI | MoEYS, ក្រុមហ៊ុនពាក់ព័ន្ធ |
| រដ្ឋាភិបាលអេឡិចត្រូនិក និងបច្ចេកវិទ្យាទំនាក់ទំនងនិងព័ត៌មាន ក្នុងវិស័យរដ្ឋបាលសាធារណៈ | **ក.ជ.វ.ប.ន.** | MEF, MPTC, MISTI, MEF | **ក.ជ.វ.ប.ន.**, MEF, MPTC | MPTC, MISTI, MEF |
| **នវានុវត្តន៍** | | | | |
| គោលនយោបាយនវានុវត្តន៍ និងប្រព័ន្ធអេកូឡូស៊ី | **ក.ជ.វ.ប.ន.** | MISTI | **ក.ជ.វ.ប.ន.**, MISTI | MISTI, MoEYS, MAFF, MPTC |
| ប្រព័ន្ធគាំទ្រនវានុវត្តន៍ ជាក់លាក់ | **ក.ជ.វ.ប.ន.** | MISTI, MoEYS, MAFF, MPTC | **ក.ជ.វ.ប.ន.**, MISTI | MISTI, MoEYS, MAFF, MPTC |
| នវានុវត្តន៍សង្គម ឬបរិយាបន្ន | **ក.ជ.វ.ប.ន.** | MISTI | MISTI | MISTI |

ប្រភព៖ ដកស្រង់ចេញពីឯកសារផ្សេងៗរបស់រាជរដ្ឋាភិបាលកម្ពុជា

## ២.៣. ក្របខ័ណ្ឌច្បាប់

ក្របខ័ណ្ឌបទប្បញ្ញត្តិ ដូចជាគោលនយោបាយ និងដំណើរការច្បាប់ស្តីពីវិស័យ **វ.ប.ន.** ក្នុងប្រទេសកម្ពុជាមានលក្ខណៈដាច់ដោយឡែកតាមក្រសួងនិងស្ថាប័នផ្សេងៗគ្នា និងមានការសម្របសម្រួលតិចតួច។ ទោះយ៉ាងណា ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលទើបនឹងបង្កើតថ្មីនៅចុងខែមីនាឆ្នាំ ២០២០ នឹងក្លាយជាសេនាធិការរបស់រាជរដ្ឋាភិបាលតែមួយគត់ ដែលត្រូវបានផ្តល់សមត្ថកិច្ចពេញ

លេញដោយរាជរដ្ឋាភិបាលកម្ពុជាដើម្បីសម្របសម្រួល ដឹកនាំ និងគ្រប់គ្រងរាល់ការងារពាក់ព័ន្ធនឹងវិស័យ **វ.ប.ន.** គោលនយោបាយ បទប្បញ្ញត្តិ និងក្របខ័ណ្ឌច្បាប់ (OCM, ២០២០a)។ ក្រោយមកទៀតអនុក្រឹត្យលេខ ៤៨ អនក្រ.បក. ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលបានផ្តល់នូវសិទ្ធិអំណាចដល់ក្រសួងនេះ ដើម្បីបំពេញបេសកកម្មរបស់ខ្លួនក្នុងនាមជាសេនាធិការឱ្យរាជរដ្ឋាភិបាលកម្ពុជា (RGC, ២០២០b)។ អនុក្រឹត្យនេះបានបង្កើតស្ថាប័នសំខាន់ចំនួនពីរ គឺអគ្គនាយកដ្ឋាន វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងវិទ្យាស្ថានជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ស្ថាប័នទាំងពីរនេះគឺជាស្ថាប័នជំនាញ ចាត់ចែង និងរៀបចំគោលនយោបាយ **វ.ប.ន.** បង្កើតផែនទីបង្ហាញផ្លូវ ធ្វើសេចក្តីព្រាងច្បាប់ និងបទប្បញ្ញត្តិទាក់ទងនឹងវិស័យ **វ.ប.ន.**។ អគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ មានបេសកកម្មរៀបចំ និងគ្រប់គ្រងរបកគំហើញបច្ចេកវិទ្យាដើម្បីបម្រើដល់ការអភិវឌ្ឍបច្ចេកវិទ្យាក្នុងវិស័យឧស្សាហកម្ម ក្នុងការលើកកម្ពស់ បញ្ញាសិប្បនិម្មិត មនុស្សយន្តនិងស្វ័យប្រវត្តិកម្ម និងជំរុញកិច្ចការបច្ចេកវិទ្យា ដូចជាបច្ចេកវិទ្យាឆ្លាតវៃបញ្ញាសិប្បនិម្មិត បច្ចេកវិទ្យាអវកាសនិងព័ត៌មានអំពីលំហអាកាស និងអេកូនវានុវត្តន៍(RGC, ២០២០b)។

ទន្ទឹមនឹងនេះវិទ្យាស្ថានជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ គឺជាវិទ្យាស្ថានដែលមានការទទួលខុសត្រូវជាចម្បងសម្រាប់ការស្រាវជ្រាវនិងអភិវឌ្ឍន៍វិស័យ **វ.ប.ន.** បន្ថែមលើការអភិវឌ្ឍសមត្ថភាពលើបច្ចេកវិទ្យា និងនវានុវត្តន៍ ដើម្បីបម្រើដល់ផ្នែកផ្សេងៗដូចជាបដិវត្តឧស្សាហកម្មជំនាន់ទី៤ និងឧស្សាហកម្មជំនាន់ក្រោយៗទៀត និងជំរុញលើកទឹកចិត្តការស្រាវជ្រាវលើបញ្ញាសិប្បនិម្មិត មនុស្សយន្ត និងស្វ័យប្រវត្តិកម្ម។ វិទ្យាស្ថានជាតិ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សហការស្រាវជ្រាវលើបច្ចេកវិទ្យាឧស្សាហកម្ម (កសិ-ឧស្សាហកម្ម ចំណីអាហារ និងជីវៈវេជ្ជសាស្ត្រ) និងឧស្សាហកម្មអេឡិចត្រូនិក (ផ្នែករឹង និងផ្នែកទន់) រៀបចំនិងដំណើរការមន្ទីរពិសោធន៍ ស្រាវជ្រាវវិទ្យាសាស្ត្រ និងការអភិវឌ្ឍបច្ចេកវិទ្យា (RGC, ២០២០b)។

អតីតក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (NSTC) ត្រូវបានបង្កើតនៅថ្ងៃទី ៨ ខែសីហា ឆ្នាំ ២០១៤ មុនពេលបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (OCM, ២០១៤)។ អតីតក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា មានលេខាធិការដ្ឋានរបស់ខ្លួនក្រោមការគ្រប់គ្រងរបស់ក្រសួងផែនការ ហើយអតីតក្រុមប្រឹក្សាជាតិនេះដឹកនាំដោយ**សម្តេចតេជោ នាយករដ្ឋមន្ត្រី** ជាប្រធាន។ អតីតក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ជាសេនាធិការរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការធ្វើសេចក្តីព្រាង និងការអនុម័តគោលនយោបាយវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ជំរុញការអនុវត្តគោលនយោបាយ បង្កើតផែនការយុទ្ធសាស្ត្រ ផែនការមេ ផែនការសកម្មភាព ការអភិវឌ្ឍកម្មវិធីសម្រាប់វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងផ្សេងៗទៀតជាអាទិ៍។ អតីតក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា បានអនុម័តផែនការសកម្មភាពជាតិវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ១០ ឆ្នាំ សម្រាប់ឆ្នាំ ២០២០-២០៣០ (RGC, ២០១៩)។

ដោយសារតែ អតីតក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ផ្តោតសំខាន់តែលើវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដូចនេះនៅថ្ងៃទី ១០ ខែតុលាឆ្នាំ ២០២០ អតីតក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ត្រូវបានប្តូរទៅជា **ក.ជ.វ.ប.ន.** តាមរយៈព្រះរាជក្រឹត្យលេខ នស/រកត/១០២០/១០៧៣ ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល ដើម្បីអភិវឌ្ឍវិស័យ **វ.ប.ន.** លើការពិនិត្យ ការអនុម័ត និងការជំរុញការអនុវត្តគោលនយោបាយ ការបង្កើតផែនការយុទ្ធសាស្ត្រ ផែនការមេ ផែនការសកម្មភាព និងកម្មវិធីអភិវឌ្ឍន៍វិស័យ **វ.ប.ន.**។ ដូចគ្នានេះផងដែរ **ក.ជ.វ.ប.ន.** មានភារកិច្ច៖ ដឹកនាំសម្របសម្រួលកិច្ចការក្នុងវិស័យ **វ.ប.ន.** នៃអន្តរក្រសួងនិងស្ថាប័ន កៀរគរថវិកា

ហិរញ្ញវត្ថុ បច្ចេកទេសនិងធនធានមនុស្សដើម្បីគាំទ្រស្ថាប័នដែលធ្វើការលើការអភិវឌ្ឍវិស័យ វ.ប.ន. និងកំណត់គោលការណ៍សម្រាប់ការអភិវឌ្ឍធនធានមនុស្សនៅក្នុងវិស័យ វ.ប.ន.។ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** គឺជាប្រធានកិត្តិយសនៃ **ក.ជ.វ.ប.ន.** និងរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍ គឺជាប្រធាន **ក.ជ.វ.ប.ន.**។ **ក.ជ.វ.ប.ន.** មានស្ថាប័នរដ្ឋាភិបាលចំនួន៣០ រួមបញ្ចូលមានក្រសួងសំខាន់ៗដូចជា ក្រសួងផែនការ ក្រសួងសុខាភិបាល ក្រសួងរ៉ែនិងថាមពល ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងស្ថាប័នផ្សេងៗទៀត។ **ក.ជ.វ.ប.ន.** មានលេខាធិការដ្ឋានផ្ទាល់របស់ខ្លួនដើម្បីជួយ និងគាំទ្រក្រុមប្រឹក្សាជាតិ ក្នុងការប្រមូលព័ត៌មាន ទិន្នន័យ និងរៀបចំព្រឹត្តិការណ៍ផ្សេងៗ (RGC, ២០២០c)។

**គោលនយោបាយជាតិស្តីពី វ.ប.ន.**៖ អតីតក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា បានអនុម័តគោលនយោបាយជាតិស្តីពី **វ.ប.ន.** ឆ្នាំ ២០២០-២០៣០ ដែលផ្តោតលើការអភិវឌ្ឍ និងពង្រឹងធនធានមនុស្ស **វ.ប.ន.** ឱ្យបានគ្រប់គ្រាន់ដោយមានតុល្យភាពយេនឌ័រ និងអភិសមាចារវិជ្ជាជីវៈ។ លើសពីនេះទៀត គោលនយោបាយនេះផ្តោតលើការធ្វើឱ្យធនធានមនុស្ស **វ.ប.ន.** មានភាពលេចធ្លោដើម្បីដឹកនាំបំពេញភារកិច្ច និងបង្កើតយន្តការចម្រាញ់ និងជំរុញក្នុងការបង្កើតបរិយាកាសអំណោយផលសម្រាប់ធនធានមនុស្ស **វ.ប.ន.** ជាតិដើម្បីប្រើប្រាស់សក្តានុពលរបស់ពួកគេឱ្យអស់ពីលទ្ធភាព(RGC, ២០១៩)។ អតីតក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាបង្កឱ្យមានការស្រាវជ្រាវនិងអភិវឌ្ឍន៍ជាតិ ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ដោយផ្តោតលើការបន្សាំបច្ចេកវិទ្យាដែលទទួលបានស្របទៅនឹងបរិបទក្នុងស្រុក និងបង្កើនសមត្ថភាពស្រូបយកបច្ចេកវិទ្យាពីបរទេស។

តាមរយៈគោលនយោបាយនេះ រាជរដ្ឋាភិបាលនឹងធ្វើសេចក្តីព្រាង និងអនុម័តច្បាប់ដែលទាក់ទងនឹងវិស័យ **វ.ប.ន.** ដូចជាច្បាប់ទាក់ទងនឹងក្របខ័ណ្ឌមូលដ្ឋាននៃការអភិវឌ្ឍវិស័យ **វ.ប.ន.** និងច្បាប់សំខាន់ៗដទៃទៀត ដើម្បីពង្រឹងអភិបាលកិច្ច ជំរុញ និងផ្សព្វផ្សាយការអភិវឌ្ឍវិស័យ **វ.ប.ន.**។ ឆន្ទៈរបស់រាជរដ្ឋាភិបាលបានកំពុងឆ្ពោះទៅមុខ ជាក់ស្តែងគេបានកត់សម្គាល់ថានៅក្នុងឆ្នាំ ២០១៤ អតីតក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាបានបង្កើតផែនការមេថ្នាក់ជាតិរបស់ខ្លួនសម្រាប់ឆ្នាំ ២០១៤-២០២០ ដោយមានគោលបំណងធ្វើសេចក្តីព្រាង និងអនុម័តច្បាប់យ៉ាងហោចណាស់ចំនួនប្រាំពីរ ដូចជា៖ ច្បាប់ស្តីពីសមាសភាពនៃគណៈកម្មាធិការ និងប្រតិបត្តិការរបស់ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ច្បាប់ស្តីពីការបណ្តុះបណ្តាល ការប្រើប្រាស់និងការថែទាំកម្លាំងពលកម្មវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ច្បាប់ស្តីពីការតម្លើង និងប្រតិបត្តិការមូលនិធិរបស់រាជរដ្ឋាភិបាលសម្រាប់ការលើកកម្ពស់វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ច្បាប់ស្តីពីការបង្កើតនិងប្រតិបត្តិការវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ ច្បាប់ស្តីពីការអនុវត្តនិងការគ្រប់គ្រងគម្រោងស្រាវជ្រាវនិងអភិវឌ្ឍន៍ជាតិ ច្បាប់ស្តីពីការអភិវឌ្ឍន៍សហប្រតិបត្តិការរវាងឧស្សាហកម្ម ស្ថាប័នអប់រំ និងវិទ្យាស្ថានស្រាវជ្រាវ និងច្បាប់ស្តីពីការបង្កើតនិងប្រតិបត្តិការមជ្ឈមណ្ឌលព័ត៌មានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ជាអាទិ៍(NSTC, ២០១៤)។ ក្នុងឆ្នាំ ២០២០ ច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ត្រូវបានអនុម័ត។ ក្រៅពីនោះ ពុំមានបង្ហាញពីបទប្បញ្ញត្តិ និងច្បាប់ដែលពាក់ព័ន្ធផ្សេងៗទេ។

**គោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍-បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន ឆ្នាំ២០២០** គឺជាឯកសាររបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដែលផ្តោតលើការបង្កើតក្របខ័ណ្ឌគោលនយោបាយ ក្របខ័ណ្ឌសម្របសម្រួល និងការរៀបចំស្ថាប័នសម្រាប់ទូរគមនាគមន៍ និងការអភិវឌ្ឍបច្ចេកវិទ្យាទំនាក់ទំនង និងព័ត៌មាន។ ការណ៍នេះក៏ជំរុញធុរកិច្ច បរិយាកាសនៃការវិនិយោគ ការផ្តល់វិធានការអន្តរកម្ម និងការបង្កើតថ្មី

ជាក់លាក់ដែលជាតម្រូវការក្នុងវិស័យទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាទំនាក់ទំនងនិងព័ត៌មាន។ នៅក្រោមគោលនយោបាយនេះ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក៏កំណត់គោលដៅដើម្បីធ្វើឱ្យប្រព័ន្ធបច្ចេកវិទ្យាទំនាក់ទំនងនិងព័ត៌មាន មានសុវត្ថិភាពផងដែរចៀសវាងក្រុមហេគឃ័រ ដែលបង្កបញ្ហាដល់ប្រព័ន្ធធនាគារក្នុងវិស័យឯកជន និងប្រព័ន្ធប្រតិបត្តិការរបស់រាជរដ្ឋាភិបាល។ លើសពីនេះទៀត ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ នឹងជំរុញឱ្យរៀបចំនិងអនុម័តគោលនយោបាយអ៊ីនធឺណិតល្បឿនលឿន គោលនយោបាយវិទ្យុគមនាគមន៍ គោលនយោបាយកាតព្វកិច្ចសេវាសកល និងគោលនយោបាយផ្សេងទៀតដែលទាក់ទងនឹងបច្ចេកវិទ្យាទំនាក់ទំនងនិងព័ត៌មានតាមតម្រូវការ។ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍បានសហការជាមួយក្រសួងពាណិជ្ជកម្ម ដើម្បីធ្វើសេចក្តីព្រាងច្បាប់ពាណិជ្ជកម្មតាមអេឡិចត្រូនិក និងអនុក្រឹត្យពាក់ព័ន្ធ។ បទប្បញ្ញត្តិទាំងនោះត្រូវបានអនុម័តដោយរដ្ឋសភា និងរាជរដ្ឋាភិបាល (MPTC, ២០២០)។

ក្រោមការឧបត្ថម្ភរបស់ទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) គម្រោងផែនការមេបច្ចេកវិទ្យាទំនាក់ទំនងនិងព័ត៌មានកម្ពុជាឆ្នាំ ២០១៤-២០២០ ត្រូវបានបង្កើតឡើង។ គម្រោងនេះផ្តោតលើការផ្តល់អំណាចដល់ប្រជាជន ជានាការតភ្ជាប់បណ្តាញ ពង្រឹងសមត្ថភាពបង្កើនសេវាកម្មអេឡិចត្រូនិក។ ការកសាងធនធានមនុស្ស និងការផ្សព្វផ្សាយឱ្យយល់ដឹងពីអេឡិចត្រូនិក គឺជាផ្នែកមួយដ៏សំខាន់ដែលត្រូវបានចែងនៅក្នុងផែនការមេ ពីព្រោះវាជាកាតាលីករសម្រាប់កំណើនឧស្សាហកម្មនៅក្នុងប្រទេស។ ការជំរុញឧស្សាហកម្មទូរគមនាគមន៍តាមរយៈការបើកទីផ្សារ និងពង្រឹងមូលដ្ឋានសេវាកម្មអ៊ីនធឺណិត ហើយមានផែនការដើម្បីបង្កើតផ្កាយរណបជាតិ និងកសាងខ្សែកាបអុបទិកក្រោមបាតសមុទ្រ គឺជាចំណុចសំខាន់ (KOICA, ២០១៤)។ ការពង្រឹងសមត្ថភាពផ្តោតលើឧស្សាហកម្ម បច្ចេកវិទ្យាទំនាក់ទំនងនិងព័ត៌មាន ស្តង់ដារបច្ចេកវិទ្យាទំនាក់ទំនងនិងព័ត៌មាន និងការស្រាវជ្រាវនិងអភិវឌ្ឍន៍ដែលផ្តោតសំខាន់លើភាពជាម្ចាស់ និងត្រូវចុះឈ្មោះចូលក្នុងប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាទំនាក់ទំនងនិងព័ត៌មានសកល គឺដើម្បីកសាងសមត្ថភាពធនធានមនុស្ស និងការប្រកួតប្រជែងតាមរយៈការស្រាវជ្រាវនិងអភិវឌ្ឍន៍។ ផែនការមេនេះក៏ផ្តោតសំខាន់លើការបង្កើនសេវាអេឡិចត្រូនិកដែលសំដៅលើសេវាកម្មរាជរដ្ឋាភិបាល សេវាសាធារណៈ និងសេវាសេដ្ឋកិច្ចតាមប្រព័ន្ធអេឡិចត្រូនិក។ សេវាអេឡិចត្រូនិក ត្រូវបានអនុវត្តដោយរាជរដ្ឋាភិបាល និងផ្នែកឯកជន ដូចជាទិដ្ឋាការអេឡិចត្រូនិក សេវាធនាគារអេឡិចត្រូនិក ការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិកជាដើម។ ដើម្បីឱ្យផែនការមេនេះឈានដល់គោលដៅ គេមិនត្រូវភ្លេចរៀបចំក្របខ័ណ្ឌបទប្បញ្ញត្តិដើម្បីធានាបាននូវដំណើរឆ្ពោះទៅមុខ។ ច្បាប់ខាងក្រោមត្រូវបានលើកឡើងនៅក្នុងផែនការមេក្នុងឆ្នាំ ២០១៤៖ គោលនយោបាយជាតិបច្ចេកវិទ្យាទំនាក់ទំនងនិងព័ត៌មាន ដោយអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍បច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា(NiDA) ច្បាប់ទូរគមនាគមន៍នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ច្បាប់ស្តីពីពាណិជ្ជកម្មអេឡិចត្រូនិកនៃក្រសួងពាណិជ្ជកម្ម ច្បាប់ស្តីពីវិទ្យុគមនាគមន៍នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ច្បាប់ស្តីពីការរក្សាសិទ្ធិនិងសិទ្ធិពាក់ព័ន្ធនៃក្រសួងពាណិជ្ជកម្ម ក្រសួងមហាផ្ទៃ និងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណិតដោយអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍បច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា។ គេសង្កេតឃើញថាច្បាប់ទាំងនោះត្រូវបានអនុម័ត លើកលែងតែច្បាប់ស្តីពីវិទ្យុគមនាគមន៍ និងច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណិត ដែលសេចក្តីព្រាងច្បាប់នេះត្រូវបានរង់ចាំពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

**ច្បាប់ស្តីពីពាណិជ្ជកម្មអេឡិចត្រូនិកនៅប្រទេសកម្ពុជា** នៅចុងខែវិច្ឆិកាឆ្នាំ២០១៩ ច្បាប់ស្តីពីពាណិជ្ជកម្មអេឡិចត្រូនិក ត្រូវបានប្រកាសឱ្យប្រើដោយព្រះមហាក្សត្រ (OCM, ២០១៩) ។ ច្បាប់នេះមានគោលបំណង៖

គ្រប់គ្រងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងព្រះរាជាណាចក្រកម្ពុជា និងជាមួយអន្តរជាតិ បង្កើតភាពប្រាកដប្រជាផ្នែកគតិយុត្តក្នុងប្រតិបត្តិការពាណិជ្ជកម្មនិងរដ្ឋប្បវេណីតាមប្រព័ន្ធអេឡិចត្រូនិក ផ្តល់ទំនុកចិត្តដល់សាធារណជនក្នុងការប្រើប្រាស់និងទំនាក់ទំនងអេឡិចត្រូនិក។ ច្បាប់ស្តីពីពាណិជ្ជកម្មអេឡិចត្រូនិក តម្រូវទាមទារបច្ចេកវិទ្យាទំនើប ដើម្បីតាមដានថាតើប្រតិបត្តិការ ធុរកិច្ច ឬកិច្ចសន្យាត្រូវបានបង្កើតឡើងដែរឬទេ។ ដើម្បីធានាបាននូវសុវត្ថិភាពប្រតិបត្តិការអេឡិចត្រូនិក ច្បាប់នេះផ្តល់ឱ្យក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍នូវសិទ្ធិអំណាចក្នុងការគ្រប់គ្រងនិងត្រួតពិនិត្យដំណើរការនៃការជូនដំណឹងតាមប្រព័ន្ធអេឡិចត្រូនិក និងហត្ថលេខាអេឡិចត្រូនិក។ ច្បាប់នេះក៏ទទួលស្គាល់ហត្ថលេខាអេឡិចត្រូនិកសម្រាប់ការបង្កើតកិច្ចសន្យារបស់ភាគីដែលវាស្រដៀងនឹងហត្ថលេខាឌីជីថល។ ទោះយ៉ាងណាក៏ដោយហត្ថលេខាឌីជីថលតម្រូវឱ្យចុះឈ្មោះនៅក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។ រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យលេខ ២៤៦ ស្តីពីហត្ថលេខាឌីជីថលក្នុងឆ្នាំ ២០១៧ ដែលជាសារអេឡិចត្រូនិក ដែលបញ្ជាក់ពីហត្ថលេខាឌីជីថល និងផ្ទៀងផ្ទាត់យថាភូតកម្មនៃសារអេឡិចត្រូនិកដែលចុះហត្ថលេខាដោយហត្ថលេខីឌីជីថល។

**ច្បាប់ស្តីពីទូរគមនាគមន៍** ត្រូវបានប្រកាសឱ្យប្រើនៅក្នុងខែធ្នូឆ្នាំ ២០១៥ ហើយច្បាប់នេះបានចែងក្នុងការធានាការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធនិងបណ្តាញ និងការផ្តល់សេវាកម្មទូរគមនាគមន៍ប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព គុណភាព និងភាពអាចជឿទុកចិត្តបាន និងថ្លៃសមរម្យដែលឆ្លើយតបនឹងសេចក្តីត្រូវការនៃការអភិវឌ្ឍ សេដ្ឋកិច្ច-សង្គម ធានាការចូលរួមនិងលើកទឹកចិត្តដល់វិស័យឯកជនក្នុងការអភិវឌ្ឍវិស័យទូរគមនាគមន៍ និងការប្រកួតប្រជែងស្របច្បាប់និងប្រកបដោយប្រសិទ្ធភាព និងធានាការការពារអ្នកប្រើប្រាស់និងជំរុញការកៀរគរចំណូលថវិកាជាតិ។ ច្បាប់នេះផ្តល់សមត្ថកិច្ចដល់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ដើម្បីគ្រប់គ្រង និងត្រួតពិនិត្យបណ្តាញទាំងអស់នៃសេវាកម្មទូរគមនាគមន៍ និងអ៊ីនធឺណិត។ ច្បាប់នេះក៏បានបង្កើតមុខងារ និងភារកិច្ចរបស់និយតករទូរគមនាគមន៍កម្ពុជា ចំណាត់ថ្នាក់និងប្រភេទនៃលិខិតអនុញ្ញាតវិញ្ញាបនប័ត្រ និងអាជ្ញាប័ណ្ណ គ្រប់គ្រងនិងការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធនិងបណ្តាញ និងផ្តល់ការកសាងសមត្ថភាព និងការស្រាវជ្រាវនិងអភិវឌ្ឍន៍ (OCM, ២០១៥)។

**ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម** ត្រូវបានប្រកាសឱ្យប្រើប្រាស់នៅខែមករាឆ្នាំ២០០៣ ដែលច្បាប់នេះ មានគោលដៅការពារតក្កកម្ម ដែលបានទទួលប្រកាសនីយបត្រតក្កកម្ម ម៉ូដែលមានអត្ថប្រយោជន៍ដែលបានទទួលវិញ្ញាបនបត្រ និងការពារគំនូរឧស្សាហកម្មដែលបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា ស្របតាមច្បាប់នេះ និងសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម។ ច្បាប់នេះមានគោលបំណងលើកទឹកចិត្តចំពោះនវានុវត្តន៍ និងការស្រាវជ្រាវនិងអភិវឌ្ឍន៍វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដើម្បីជំរុញធុរកិច្ច និងការវិនិយោគក្នុងនិងក្រៅប្រទេស ជំរុញការផ្ទេរបច្ចេកវិទ្យាមកក្នុងប្រទេសដើម្បីជួយសម្រួលដល់សកម្មភាពឧស្សាហកម្ម និងការអភិវឌ្ឍសេដ្ឋកិច្ច និងផ្តល់ការការពារសិទ្ធិនៃភាពជាម្ចាស់ឧស្សាហកម្ម និងដើម្បីប្រយុទ្ធប្រឆាំងចំពោះការរំលោភសិទ្ធិក៏ដូចជាប្រឆាំងនឹងការធ្វើធុរកិច្ចមិនស្របច្បាប់។ ពាក្យ "ប្រកាសនីយបត្រតក្កកម្ម" មានន័យថាជាវិញ្ញាបនបត្រដែលបានផ្តល់ដើម្បីការពារតក្កកម្ម។ ហើយពាក្យថា "តក្កកម្ម" មានន័យថាជាគំនិតរបស់តក្កករដែលអាចយកទៅអនុវត្តបាននៅក្នុងដំណោះស្រាយបញ្ហាជាក់លាក់ណាមួយក្នុងវិស័យបច្ចេកវិទ្យា។ ច្បាប់នេះមានសារៈសំខាន់ខ្លាំងណាស់ក្នុងការការពារម៉ូដែលមានអត្ថប្រយោជន៍លើតក្កកម្មថ្មី និងអាចប្រើប្រាស់បានសម្រាប់ឧស្សាហកម្ម ហើយអាច ឬទាក់ទងនឹងផលិតផល ឬដំណើរការ។ អ្នកភ្ញាស់បច្ចេកវិទ្យាដែលបានបង្កើតគំនូរម៉ូដែល បច្ចេកវិទ្យាថ្មីសម្រាប់ឧស្សាហកម្ម

ត្រូវបានការពារដោយច្បាប់នេះ (OCM, ២០០៣)។ ច្បាប់នេះក៏ទាក់ទងទៅនឹងច្បាប់ស្តីពីពាណិជ្ជសញ្ញា និងច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលផងដែរ។ ច្បាប់ស្តីពីពាណិជ្ជសញ្ញាគ្របដណ្តប់លើការការពារពាណិជ្ជសញ្ញា និងសេវាសញ្ញា។ ម៉ាកដែលមិនអាចចុះឈ្មោះបាន សំដៅលើម៉ាកដែលដូច ឬស្ទើរតែដូចគ្នាទាំងស្រុងទៅនឹងម៉ាកដែលជាកម្មសិទ្ធិរបស់ម្ចាស់ផ្សេង ដែលបានចុះបញ្ជីរួចហើយ ឬបានដាក់ពាក្យស្នើសុំចុះបញ្ជីមុន ឬបានទទួលអាទិភាពចុះបញ្ជីមុន នៅឯបរទេស ចំពោះទំនិញឬសេវាដូចគ្នាឬទំនិញឬសេវាដែលពាក់ព័ន្ធគ្នាយ៉ាងជិតស្និទ្ធ។ ម្ចាស់ពាណិជ្ជសញ្ញាត្រូវបានការពារដោយច្បាប់ ក៏ដូចជាសិទ្ធិរបស់ពួកគេក្នុងការចាត់ចែងផ្ទេរ និងផ្តល់អាជ្ញាប័ណ្ណពាណិជ្ជសញ្ញារបស់ពួកគេដល់មនុស្សទីបី។ ម្ចាស់ពាណិជ្ជសញ្ញាអាចរកដំណោះស្រាយស៊ីវិល និងផ្នែករដ្ឋបាល។ ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលមានគោលបំណងធានាការគោរពសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល និងការពារផលិតផលវប្បធម៌ជាស្នាដៃអ្នកនិពន្ធ អ្នកសម្តែង ផលិតករ ហ្វូណូក្រាមនិងអង្គភាពទូរផ្សាយសំដៅធានាការធ្វើអាជីវកម្មមួយត្រឹមត្រូវស្របច្បាប់លើផលិតផលវប្បធម៌ទាំងនោះ ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍវិស័យវប្បធម៌ (OCM, ២០០៣)។

ដោយពិចារណាលើការផ្លាស់ប្តូរយ៉ាងលឿននៃបច្ចេកវិទ្យានៅក្នុងបរិបទនៃបដិវត្តឧស្សាហកម្មជំនាន់ទី ៤ ជាការពិតដែលថាក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ គឺជាស្ថាប័នសម្របសម្រួលការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ី **វ.ប.ន.** នៅក្នុងប្រទេស។ លើសពីនេះទៀត **ក.ជ.វ.ប.ន.** គឺជាស្ថាប័នជាតិមួយដែលមានសិទ្ធិអំណាចពេញលេញក្នុងការសម្របសម្រួល និងធ្វើនិយ័តកម្មក្របខ័ណ្ឌ។ គួរកត់សំគាល់ថាឯកសារគតិយុត្តមួយចំនួននឹងត្រូវផលិតនាពេលអនាគត នឹងធ្វើគណនេយ្យភាពជូនក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និង **ក.ជ.វ.ប.ន.**។ ជាឧទាហរណ៍ វិស័យអាទិភាពជាច្រើនត្រូវបានអនុម័តនៅកម្រិតជាតិដោយមានប្រព័ន្ធគាំទ្រនៃក្របខ័ណ្ឌច្បាប់រឹងមាំ។ ជាមួយគ្នានេះ ប្រព័ន្ធគាំទ្រផ្នែកច្បាប់ត្រូវតែធ្វើបច្ចុប្បន្នភាពស្របទៅនឹងការផ្លាស់ប្តូរ យ៉ាងលឿននៃបច្ចេកវិទ្យា ដែលកំពុងត្រូវបានប្រើប្រាស់នៅលើទីផ្សារ ជាមួយនឹងភាពមិនច្បាស់លាស់នៃផលវិបាកទាំងគុណសម្បត្តិ និងគុណវិបត្តិ។ ដូច្នេះក្របខ័ណ្ឌច្បាប់អំណោយផលត្រូវមានដូចជា ការផ្ទេរបច្ចេកវិទ្យា ក្រមសីលធម៌សម្រាប់បញ្ញាសិប្បនិម្មិត ច្បាប់ស្តីពីបច្ចេកវិទ្យាហិរញ្ញវត្ថុ បច្ចេកវិទ្យាឌីជីថលនិងគោលការណ៍ណែនាំអំពីការអនុវត្ត និងគោលការណ៍ផ្សេងៗទៀត។

## ២.៤. គុណសម្បទា និងបំណិន

ប្រទេសកម្ពុជាកំពុងធ្វើបរិវត្តកម្ម និងទំនើបកម្មរចនាសម្ព័ន្ធឧស្សាហកម្មពីកម្លាំងពលកម្មដែលគ្មានជំនាញទៅជាកម្លាំងពលកម្មដែលមានជំនាញ។ យោងតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ (២០១៨-២០២៣) និងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម (ឆ្នាំ២០១៥-២០២៥) រាជរដ្ឋាភិបាលកម្ពុជាបានសង្កត់ធ្ងន់ថា កំណើនការងារប្រកបដោយសមធម៌ និងប្រសិទ្ធផល គឺជាគោលដៅមួយក្នុងចំណោមគោលដៅនានាក្នុងផែនការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមរបស់កម្ពុជា។ ផែនការយុទ្ធសាស្ត្រនេះក៏តភ្ជាប់រវាងឧស្សាហកម្ម និងសេដ្ឋកិច្ចកម្ពុជាជាមួយខ្សែច្រវាក់តម្លៃពិភពលោកដែលត្រូវបានបញ្ចូលក្នុងបណ្តាញផលិតកម្មក្នុងតំបន់។ បច្ចុប្បន្ន ប្រទេសកម្ពុជាពឹងផ្អែកលើផលិតកម្មដែលដំណើរការដោយកម្លាំងពលកម្ម និងវិស័យសេវាកម្មដែលមានជំនាញទាប ដើម្បីគាំទ្រដល់កំណើនសេដ្ឋកិច្ចរបស់ខ្លួន។ ខណៈពេលដែលប្រទេសអភិវឌ្ឍន៍ឆ្ពោះទៅរកសេដ្ឋកិច្ចទីផ្សារឧស្សាហកម្ម ដំណើរការផលិតកម្មកាន់តែទំនើប និងកម្លាំងពលកម្មដែលមានជំនាញខ្ពស់ គឺជាតម្រូវការចាំបាច់ដើម្បីរក្សាកំណើនយ៉ាងឆាប់រហ័សរបស់ខ្លួន និងប្រកួតប្រជែងនៅក្នុងទីផ្សារពិភពលោក។

ទោះយ៉ាងណាទំនាក់ទំនងរវាងការអប់រំនិងការបណ្តុះបណ្តាលវិជ្ជាជីវៈ និងគោលនយោបាយឧស្សាហកម្មនៅតែមានកម្រិត។ រាជរដ្ឋាភិបាលបានចាប់ផ្តើមដាក់ឱ្យដំណើរការគោលនយោបាយគន្លឹះទាក់ទងនឹងការអភិវឌ្ឍធនធានមនុស្ស និងការងារ មានដូចជា គោលនយោបាយជាតិស្តីពីការងារ (២០១៥-២០២៥) និងគោលនយោបាយជាតិស្តីពីជីវេត (២០១៧-២០២៥) ដើម្បីលើកកម្ពស់ជំនាញ និងការអភិវឌ្ឍធនធានមនុស្សក្នុងការឆ្លើយតបនឹងតម្រូវការអភិវឌ្ឍរបស់ប្រទេស។ ដូច្នេះ ប្រសិនបើកម្ពុជាប្តេជ្ញាធ្វើបរិវត្តកម្មលើសេដ្ឋកិច្ចដែលផ្តល់តម្លៃបន្ថែមខ្ពស់ ការកសាងមូលធនមនុស្សដែលមានជំនាញនិងបច្ចេកវិទ្យាថ្មី នោះគឺជាកត្តាគន្លឹះជោគជ័យមួយ។ ការកំណត់អត្តសញ្ញាណនៃវិស័យដែលផ្តល់តម្លៃបន្ថែមខ្ពស់មានសារៈសំខាន់ ជាពិសេសឆ្លើយតបនឹងតម្រូវការនៃបដិវត្តឧស្សាហកម្មជំនាន់ទី៤ នៅកម្ពុជា។ លើសពីនេះទៀតកំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាត្រូវបានជំរុញដោយវិស័យសំខាន់ៗចំនួនបួនរួមមាន ផលិតកម្មកាត់ដេរ ទេសចរណ៍ សំណង់ និងកសិកម្ម។ ទោះយ៉ាងណាដើម្បីរក្សានិរន្តរភាពនៃកំណើនសេដ្ឋកិច្ចជាតិរយៈពេលវែង គឺអាស្រ័យលើសមត្ថភាពក្នុងការធ្វើឱ្យបានលើសពីវិស័យទាំងនេះ និងត្រូវការកម្លាំងពលកម្មដែលមានជំនាញ។ ការណ៍នេះ ធ្វើឱ្យមានស្ថិរភាពមូលដ្ឋានបន្ថែមទៀតសម្រាប់ការអភិវឌ្ឍ និងការធ្វើពិពិធកម្មឧស្សាហកម្ម។ យោងតាមការស្ទង់មតិរបស់ទីភ្នាក់ងារការងារជាតិក្នុងឆ្នាំ ២០១៧បច្ចេកវិទ្យាទំនាក់ទំនងនិងព័ត៌មាន ហិរញ្ញវត្ថុនិងធានារ៉ាប់រងសុខភាព និងវិស័យអប់រំ មានតម្រូវការខ្ពស់ក្នុងឆ្នាំ ២០១៧ បើប្រៀបធៀបទៅនឹងតម្រូវការនៅឆ្នាំ ២០១៦។ គេរំពឹងថានឹងមានតម្រូវការខ្ពស់ជាបន្តទៀតសម្រាប់ឆ្នាំ ២០១៨ និង ២០១៩។ លើសពីនេះទៀតលទ្ធផលនៃការស្ទង់មតិបង្ហាញពីចំណែកខ្ពស់បំផុតនៃសហគ្រាសដែលមានគម្រោងផ្តល់សេវាកម្ម ផលិតផល ឬបច្ចេកវិទ្យាថ្មីៗ ដើម្បីទទួលបានទីផ្សារថ្មីនាពេលអនាគត គឺសហគ្រាសដែលស្ថិតនៅក្នុងវិស័យអប់រំ ហិរញ្ញវត្ថុ និងធានារ៉ាប់រង។

ទោះបីមានការកែលម្អប្រព័ន្ធអប់រំ រួមបញ្ចូលទាំងផ្នែករឹង និងផ្នែកទន់ ក្នុងរយៈពេលជាងពីរទសវត្សរ៍ចុងក្រោយនេះក៏ដោយ ឧបសគ្គជាច្រើនលើបរិយាកាសសិក្សា និងគុណភាពនៃការបង្រៀនចាំបាច់ត្រូវគិតគូរពិចារណា។ ជាការពិតប្រទេសកម្ពុជាកំពុងប្រឈមមុខនឹងការខ្វះខាតធនធានមនុស្សដែលមានជំនាញ សូម្បីតែឧស្សាហកម្មដែលមានជំនាញទាប និងមធ្យម។ ការស្រាវជ្រាវលើការវាស់វែងមូលធនមនុស្ស នៅចន្លោះឆ្នាំ ១៩៩០ ដល់ឆ្នាំ ២០១៦ បានបង្ហាញថាការអប់រំនៅកម្ពុជាមានសន្ទុះយឺតជាងប្រទេសមួយចំនួននៅលើពិភពលោក និងប្រទេសមួយចំនួនទៀតនៅក្នុងតំបន់អាស៊ាន (Lim et al., ២០១៨)។ គម្លាតរវាងការផ្គត់ផ្គង់ និងតម្រូវការជំនាញមានការកើនឡើង ដោយសារមានតម្រូវការពីឧស្សាហកម្ម និងធុរកិច្ច។ ការព្រួយបារម្ភអំពីគម្លាតជំនាញ និងអសង្គតិភាពជំនាញ គឺនៅតែជាបញ្ហាប្រឈមរបស់រាជរដ្ឋាភិបាលកម្ពុជា (Madhur, ២០១៤)។ យោងតាមធនាគារពិភពលោក (២០១២) ៧៣ ភាគរយ នៃនិយោជកបានរាយការណ៍ថានិស្សិតបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យមិនមានជំនាញត្រឹមត្រូវលើការងារដែលពួកគេកំពុងដាក់ពាក្យស្នើសុំ។ មានក្រុមហ៊ុនបរទេសប្រមាណ ២២ ភាគរយ នៅក្នុងប្រទេសកម្ពុជាដែលបានទទួលស្គាល់ថាបញ្ហាជំនាញ គឺជាឧបសគ្គដ៏ធ្ងន់ធ្ងរចំពោះធុរកិច្ចរបស់ពួកគេ។ ដូច្នេះដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃយុទ្ធសាស្ត្រ និងគោលនយោបាយអប់រំ វិធានការបំពេញបន្ថែមមួយចំនួនដែលធានាថាសិស្សានុសិស្សត្រូវបានរៀបចំលក្ខណៈសម្បត្តិតាំងពីថ្នាក់បឋមសិក្សា មានដូចជា៖ ការបន្តពិនិត្យនិងធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សា ការកែលម្អគរុកោសល្យជាប្រចាំ ការបង្កើនជំនាញឌីជីថលក៏ដូចជាគុណសម្បទានិងបំណិនសម្រាប់សតវត្សរ៍ទី ២១។ ជាពិសេសអាទិភាពមួយក្នុងចំណោមអាទិភាពដទៃទៀត គឺត្រូវពង្រឹងបន្ថែមលើជំនាញនាពេលបច្ចុប្បន្ន ក៏ដូចជាការរៀបចំលក្ខណៈសម្បត្តិសម្រាប់តម្រូវការជំនាញនាពេលអនាគត ស្របតាមល្បឿននៃការផ្លាស់ប្តូរប្រជាសាស្ត្រ

របស់ប្រទេស។ ជាការពិត គុណសម្បទាបំណិនសម្រាប់សតវត្សរ៍ទី ២១ ដែលនិស្សិតសព្វថ្ងៃនេះត្រូវការដើម្បីទទួលបានជោគជ័យក្នុងអាជីពនាពេលអនាគតរបស់ខ្លួននៅក្នុងបរិបទបដិវត្តឧស្សាហកម្មជំនាន់ទី ៤ រួមមានៈ (១) ការត្រិះរិះពិចារណា (២) ការច្នៃប្រឌិត (៣) កិច្ចសហការ (៤) ទំនាក់ទំនង (៥) អក្ខរកម្មផ្នែកព័ត៌មាន (៦) អក្ខរកម្មផ្នែកប្រព័ន្ធផ្សព្វផ្សាយ (៧) អក្ខរកម្មផ្នែកបច្ចេកវិទ្យា (៨) ភាពបត់បែន (៩) ភាពជាអ្នកដឹកនាំ (១០) គំនិតផ្តួចផ្តើម (១១) ផលិតភាព (១២) ជំនាញសង្គម (Chu, S. et al., ២០១៦)។ គុណសម្បទាទាំងនេះនឹងជួយនិស្សិតឱ្យបន្តដើរតាមជវភាពនៃទីផ្សារទំនើបនាពេលបច្ចុប្បន្ននេះ។ ជាពិសេស ជំនាញទាំងនេះមានភាពចាំបាច់ណាស់នៅក្នុងយុគអ៊ីនធឺណិតនៃវត្ថុ (IoT)។ **រូបភាពទី ៤** បង្ហាញពីគុណសម្បទានៅសតវត្សរ៍ទី ២១ ។

បន្ថែមលើនេះ គុណសម្បទាសតវត្សរ៍ទី ២១ ត្រូវបានបែងចែកជាបីប្រភេទ រួមមានៈ (១) គុណសម្បទារៀន (២) គុណសម្បទាអក្ខរកម្ម និង(៣) បំណិនជីវិត។ គុណសម្បទារៀន ពន្យល់និស្សិតអំពីដំណើរការផ្លូវចិត្តដែលជាតម្រូវការធ្វើឱ្យប្រសើរឡើងនៅក្នុងបរិយាកាសការងារទំនើប។ គុណសម្បទាអក្ខរកម្ម សង្កត់ធ្ងន់លើវិធីដែលនិស្សិតអាចកំណត់ការពិត និងបច្ចេកវិទ្យា។ បំណិនជីវិត គឺជាការសង្កេតមើលធាតុអរូបីនៃជីវិតប្រចាំថ្ងៃរបស់និស្សិត រួមទាំងលក្ខណៈវិជ្ជាជីវៈ និងលក្ខណៈផ្ទាល់ខ្លួនរបស់ពួកគេ។

ការត្រិះរិះពិចារណា គឺជាគុណសម្បត្តិសំខាន់បំផុតមួយសម្រាប់និស្សិត ចំណែកឯការច្នៃប្រឌិតអាចជួយឱ្យនិស្សិតយល់ពីទស្សនទានតាមបែបផ្សេងៗគ្នាក្នុងការជំរុញឱ្យមាននវានុវត្តន៍។ សម្រាប់កិច្ចសហការ និស្សិតអាចធ្វើការជាមួយគ្នានិងទទួលបានលទ្ធផលដែលល្អបំផុតពីការដោះស្រាយបញ្ហាមួយ ចំណែកឯទំនាក់ទំនងមានសារៈសំខាន់សម្រាប់និស្សិតក្នុងការរៀនពីរបៀបបញ្ចេញគំនិតក្នុងចំណោមបុគ្គលិកដែលមានចរិតលក្ខណៈផ្សេងៗគ្នា។ **រូបភាពទី ៥** បង្ហាញពីគុណសម្បទានៅសតវត្សរ៍ទី ២១ ទាក់ទងនឹងការរៀន។




**រូបភាពទី ៤៖ គុណសម្បទានៅសតវត្សរ៍ទី ២១** (Chu, S. et al., ២០១៦)




**រូបភាពទី  ៥៖ គុណសម្បទារៀនសម្រាប់សតវត្សរ៍ទី ២១**

គុណសម្បទាអក្ខរកម្ម គឺជាផ្នែកមួយនៃគុណសម្បទាក្នុងសតវត្សរ៍ទី ២១ ដែលទាក់ទងទៅនឹងធាតុខុសគ្នានៃការយល់ដឹងអំពីឌីជីថល។ អក្ខរកម្មផ្នែកព័ត៌មាន គឺជាគុណសម្បទាមូលដ្ឋានដែលជួយឱ្យនិស្សិតយល់ពីការពិតដែលបង្រៀនពួកគេអំពីរបៀបវែកញែករវាងការពិតនិងការប្រឌិត ចំណែកឯអក្ខរកម្មផ្នែកប្រព័ន្ធផ្សព្វផ្សាយ មានប្រយោជន៍សម្រាប់កំណត់ការពិតនៅក្នុងពិភពឌីជីថល។ ចំពោះអក្ខរកម្មផ្នែកបច្ចេកវិទ្យា

ពន្យល់និស្សិតអំពីម៉ាស៊ីនដែលពាក់ព័ន្ធនឹងយុគឌីជីថល។ **រូបភាពទី៦** បង្ហាញពីគុណសម្បទានៅសតវត្សរ៍ទី ២១ ទាក់ទងនឹងអក្ខរកម្ម។




**រូបភាពទី ៦៖ គុណសម្បទាអក្ខរកម្មសម្រាប់សតវត្សរ៍ទី ២១**

បំណិនជីវិត ជាពិសេសនៅក្នុងការអប់រំស្វែម គឺជាផ្នែកមួយនៃគុណសម្បទាក្នុងសតវត្សទី២១ ដែលបំប្លែងទៅជាវិជ្ជាជីវៈអាជីព។ ចំពោះភាពបត់បែន វាជួយឱ្យនិស្សិតបត់បែនតាមផែនការក្នុងករណីចាំបាច់ ខណៈដែលភាពជាអ្នកដឹកនាំជំរុញនិស្សិតឱ្យដឹកនាំ ឬសម្រេចគោលដៅអ្វីមួយ។ រីឯគំនិតផ្តួចផ្តើមវិញអាច ជួយនិស្សិតឱ្យទទួលបានគំនិតថ្មីៗដើម្បីរៀបចំផែនការគម្រោងរបស់ពួកគេ ខណៈដែលផលិតភាពជួយនិស្សិតឱ្យរក្សាបាននូវប្រសិទ្ធផល។ ជាចុងក្រោយ ការអភិវឌ្ឍជំនាញសង្គម និងការកែលម្អអាកប្បកិរិយាវិជ្ជាជីវៈនៅតាមសាលារៀន និងការបណ្តុះបណ្តាលពហុជំនាញនៅកន្លែងធ្វើការ ទាមទារឱ្យមានភាពសមស្របទៅនឹងជំនាញផ្នែករឹង ដើម្បីឆ្លើយតបទៅនឹងការផ្គូផ្គងគ្នារវាងការផ្គត់ផ្គង់ និងតម្រូវការសម្រាប់កម្លាំងពលកម្មនាពេលអនាគត ដើម្បីទទួលបានកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពសម្រាប់ប្រទេស។ ការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យដែលត្រូវបានកំណត់ជាវិស័យអាទិភាពចម្បងៗគួរតែត្រូវបានត្រៀមខ្លួនដើម្បីឆ្លើយតបទៅនឹងជវភាពនៃបច្ចេកវិទ្យាក្នុងបរិបទឧស្សាហកម្មជំនាន់ទី៤។ **រូបភាពទី ៧** បង្ហាញពីគុណសម្បទានៅសតវត្សរ៍ទី ២១ ទាក់ទងនឹងបំណិនជីវិត។




**រូបភាពទី ៧៖ គុណសម្បទាបំណិនជីវិតសម្រាប់សតវត្សរ៍ទី ២១**

## ២.៥. បច្ចេកវិទ្យា

បច្ចេកវិទ្យា គឺអ្វីដែលយើងអនុវត្តវិទ្យាសាស្ត្រដើម្បីបង្កើតឧបករណ៍ ឬសេវាកម្មដែលអាចដោះស្រាយបញ្ហានិងតម្រូវការប្រចាំថ្ងៃរបស់យើង។ បច្ចេកវិទ្យាត្រូវបានពន្យល់យ៉ាងសាមញ្ញថា គឺជាការអនុវត្តវិទ្យាសាស្ត្រ។ គោលគំនិតនៃវិទ្យាសាស្ត្រត្រូវបានបង្កើតឡើងដើម្បីបង្កើតបច្ចេកវិទ្យា។ ទោះជាយ៉ាងនេះក្តី បច្ចេកវិទ្យាក៏បានត្រូវប្រើប្រាស់ឧបករណ៍ជាមូលដ្ឋានដើម្បីពន្យល់អំពីវិទ្យាសាស្ត្រផងដែរ។ អ្នកវិទ្យាសាស្ត្រ អាចមានភាពងាយស្រួលក្នុងការពន្យល់ពីហេតុការណ៍ ឬបាតុភូតធម្មជាតិតាមរយៈបច្ចេកវិទ្យាទំនាក់ទំនងនិងព័ត៌មាននៅក្នុងយុគឌីជីថលនេះ។ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតគំនិតផ្តួចផ្តើមគោលនយោបាយឌីជីថលសំខាន់ៗចាប់តាំងពីដើមទសវត្សរ៍ ឆ្នាំ២០០០ ដែលរួមមាន៖ ផែនការមេនៃបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានកម្ពុជា២០២០ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ គោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឆ្នាំ២០២០ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ២០១៩ និងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥។ បច្ចុប្បន្ននេះ ប្រទេសកម្ពុជាកំពុងរៀបចំយុទ្ធសាស្ត្រ រយៈពេលវែងសម្រាប់សេដ្ឋកិច្ចឌីជីថល ២០២០-២០៣៥ ដែលរួមមានធនធានមនុស្សមានជំនាញបច្ចេកទេសក្នុងវិស័យឌីជីថល ហេដ្ឋារចនាសម្ព័ន្ធឌីជីថល បំណិនគិតនិងជំនាញទន់ ធុរកិច្ចអេកូឡូស៊ី និងរដ្ឋាភិបាលអេឡិចត្រូនិក។ លើសពីនេះទៀត ផែនការមេនៃបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានកម្ពុជា២០២០ ត្រូវបានអនុម័តឱ្យប្រើប្រាស់នៅក្នុងឆ្នាំ២០១៤។ ផែនការនេះស្របនឹងផែនការមេបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានអាស៊ាន២០១៥ ផ្តោតលើការបណ្តុះបណ្តាលអក្ខរកម្មឌីជីថលធនធានមនុស្ស ការប្រើកុំព្យូទ័រដល់មន្ត្រីរដ្ឋាភិបាល ការពង្រីកហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាទំនាក់ទំនងនិងព័ត៌មាន និងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត។ គោលដៅជាក់លាក់មួយ គឺប្រជាជនកម្ពុជាប្រមាណ ៧០ ភាគរយ អាចប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតបាននៅឆ្នាំ ២០២០។ ជាការពិត បរិវត្តកម្មឌីជីថលរបស់ប្រទេសកម្ពុជាកំពុងប្រមូលផ្តុំ និងមានទស្សនវិស័យអភិវឌ្ឍន៍គួរឱ្យចាប់អារម្មណ៍។ ប្រទេសកម្ពុជាបាននិងកំពុងផ្លាស់ប្តូរយ៉ាងឆាប់រហ័ស ពីគំរូម៉ូដែលកំណើនដែលពឹងផ្អែកលើកម្លាំងពលកម្មដែលខ្វះជំនាញ ទៅជាគំរូម៉ូដែលកំណើននៃការអភិវឌ្ឍដោយពឹងផ្អែកទៅលើកម្លាំងពលកម្មដែលមានជំនាញ។ រាជរដ្ឋាភិបាល ក៏បានផ្តល់អាទិភាពលើឧស្សាហកម្មជំនាន់ទី៤ និងធ្វើពិពិធកម្មកម្លាំងពលកម្មរបស់ខ្លួន។ ដូច្នេះ ការដោះស្រាយជាមួយផលប៉ះពាល់ផ្សេងៗនៃឌីជីថលភាវូបនីយកម្មនឹងមានសារៈសំខាន់ក្នុងការរក្សាការរួមបញ្ចូលគ្នានៅលើផ្លូវបរិវត្តកម្មឌីជីថល។ ការជំរុញការអភិវឌ្ឍរាល់គ្នាគួរតែជាសមាសធាតុស្នូលនៃក្របខ័ណ្ឌសេដ្ឋកិច្ចឌីជីថលថ្មី ដែលរដ្ឋាភិបាលរំពឹងថានឹងចាប់ផ្តើមអនុវត្តនៅឆ្នាំ ២០២០។ ប្រទេសកម្ពុជាគួរតែពិចារណាលើវិធានការនានា ដើម្បីជំរុញបរិវត្តកម្មឌីជីថលប្រកបដោយបរិយាបន្ននាពេលអនាគត ដែលរួមមាន៖ (១)បរិវត្តកម្មនវានុវត្តន៍នៅក្នុងវិស័យកម្មន្តសាល (២)ការផ្តល់នូវជំនាញឌីជីថលដែលមានគុណភាពល្អសម្រាប់អនាគត (៣) ទំនុកបម្រុងធុរកិច្ចថ្មីនៃសេដ្ឋកិច្ចឌីជីថល (៤) បង្កបរិយាកាសងាយស្រួលដល់ក្រុមងាយរងគ្រោះបំផុតអាចចូលរួមក្នុងសេដ្ឋកិច្ចឌីជីថល (៥)ធានាថាវិស័យសាធារណៈនាំមុខជាគំរូ (៦)ការផ្តល់មុខវិជ្ជាសិក្សាសរសេរកូដចាប់ពីថ្នាក់បឋមសិក្សា (៧)ការអភិវឌ្ឍជំនាញទន់ក្នុងបច្ចេកវិទ្យាឌីជីថល (៨)ការកសាងចរិតបុគ្គលទៅរកបច្ចេកវិទ្យាឌីជីថល និង (៩) ការកសាងអភិសមាចារវិជ្ជាជីវៈឆ្ពោះទៅរកបច្ចេកវិទ្យាឌីជីថល (CDRI, ២០១៩)។ **រូបភាពទី ៨** បង្ហាញពីការវាស់វែងបរិវត្តកម្មឌីជីថលប្រកបដោយបរិយាបន្ន។




**រូបភាពទី ៨៖ ការវាស់វែងបរិវត្តកម្មឌីជីថលប្រកបដោយបរិយាបន្ន**

បច្ចេកវិទ្យាឌីជីថលក្នុងវិស័យបច្ចេកវិទ្យាទំនាក់ទំនងនិងព័ត៌មាន បច្ចេកវិទ្យាក្នុងវិស័យផ្សេងៗទៀត ដូចជា៖ ថាមពល វិទ្យាសាស្ត្រអាហារ កម្មន្តសាល ជីវៈបច្ចេកវិទ្យា និងបច្ចេកវិទ្យាផ្សេងៗទៀតដែលមានសារៈសំខាន់សម្រាប់ឧស្សាហកម្ម និងសហគ្រាសធុនតូចនិងមធ្យម។ ការស្វែងយល់ពីនិន្នាការ និងការស្វែងរកបច្ចេកវិទ្យាជួយឱ្យនិយោជិតរក្សាបាននិរន្តរភាព និងចាប់យកកំណើនថ្មីនៅក្នុងធុរកិច្ចរបស់ពួកគេ។ ដូច្នេះហើយ ប្រព័ន្ធគាំទ្រដែលផ្តល់នូវបរិស្ថានល្អសម្រាប់បច្ចេកវិទ្យាដែលជាឧបករណ៍បម្រើឱ្យការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម គឺជាជម្រើសដ៏ល្អបំផុតសម្រាប់ប្រទេសកម្ពុជា។

## ៣. កាលានុវត្តភាព និងបញ្ហាប្រឈមរបស់វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

### ៣.១. កាលានុវត្តភាព

ប្រទេសកម្ពុជាស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ និងជាប្រទេសកំពុងអភិវឌ្ឍន៍ដែលផ្អែកលើវិស័យសំខាន់ៗចំនួនបួន រួមមាន៖ កសិកម្ម ផលិតកម្មកាត់ដេរ ទេសចរណ៍ និងសំណង់។ ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា គឺត្រូវខិតខំប្រឹងប្រែងឱ្យក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០។ ការធ្វើពិពិធកម្មលើវិស័យផ្សេងៗទៀត មានសារៈសំខាន់ណាស់ដើម្បីចូលរួមចំណែកគាំទ្រចក្ខុវិស័យរបស់រាជរដ្ឋាភិបាល។ ប្រទេសកម្ពុជានៅតែបន្តមានបរិយាកាសអំណោយផលក្នុងការទាក់ទាញការវិនិយោគដោយផ្ទាល់ពីបរទេស

ដោយសារប្រទេសកម្ពុជាមានកម្លាំងពលកម្មភាគច្រើនជាយុវជន និងតម្លៃពលកម្មទាបនៅក្នុងរយៈពេលខ្លី និងមធ្យម។ តាមលក្ខណៈភូមិសាស្ត្រនយោបាយ ប្រទេសកម្ពុជាអាចមានអំណោយផលនិងជាបេះដូងនៃមជ្ឈមណ្ឌលសេដ្ឋកិច្ចក្នុងតំបន់អាស៊ានដែលមានប្រជាជនជាង ៦៤៧,៧៤ លាននាក់។

វិស័យទេសចរណ៍នៅតែបន្តជាមជ្ឈមណ្ឌលដែលមានសក្តានុពលសម្រាប់ការកំសាន្តបែបវប្បធម៌ និងប្រវត្តិសាស្ត្រ។ ការទាក់ទាញទេសចរណ៍ដែលមានគុណភាពខ្ពស់ទៅកាន់គោលដៅទេសចរណ៍នានា ព្រមទាំងសេវាកម្មល្អ គឺជាកិច្ចការដែលត្រូវដោះស្រាយបន្ទាន់។

អរិយធម៌របស់ប្រជាជាតិនានាក្នុងប្រវត្តិសាស្ត្រ បានប្រើប្រាស់វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាជាមធ្យោបាយមួយក្នុងការអភិវឌ្ឍប្រទេស។ រាជរដ្ឋាភិបាលកម្ពុជាបានយល់ពីតម្រូវការ ដើម្បីធ្វើឱ្យប្រសើរឡើងនៅក្នុងវិស័យនានា។ ឧទាហរណ៍ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ត្រូវបានបង្កើតឡើងក្នុងទិសដៅច្បាស់លាស់ដោយមានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដែលជាមធ្យោបាយសម្រាប់ការអភិវឌ្ឍ។ របៀបវារៈជាតិផ្សេងៗទៀតត្រូវបានដាក់ជាអាទិភាព នៅក្នុងក្រសួងផ្សេងៗ រួមមាន៖ គោលនយោបាយស្ទែមរបស់ក្រសួងអប់រំ យុវជន និងកីឡា គោលនយោបាយ **វ.ប.ន.** របស់ក្រសួងផែនការ គោលនយោបាយជីវេត របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនិងគំនិតផ្តួចផ្តើមពាក់ព័ន្ធដទៃទៀត ដូចដែលបានលើកឡើងនៅក្នុងផ្នែកខាងលើ។ ម៉្យាងវិញទៀត អាស៊ានមានរចនាសម្ព័ន្ធច្បាស់លាស់លើការលើកកម្ពស់ **វ.ប.ន.**។ ផែនការសកម្មភាពអាស៊ានលើវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (APASTI) ត្រូវបានបង្កើតឡើងដើម្បីចង្អុលបង្ហាញទិសដៅសកម្មភាពសម្រាប់ប្រទេសជាសមាជិកអាស៊ាន។ នៅក្នុងបរិការណ៍ជាក់ស្តែងមានកត្តាជំរុញជាច្រើនសម្រាប់ប្រព័ន្ធអេកូឡូស៊ី **វ.ប.ន.** នៅក្នុងប្រទេសកម្ពុជា។ កត្តាជំរុញទាំងនោះអាចត្រូវបានរំលេចជាទស្សនទានត្រីកោណ ដូចខាងក្រោម៖

- **រាជរដ្ឋាភិបាល**
    - កម្មវិធីនយោបាយសមស្របបានរំលេចពីយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ ស្តីពីសារៈសំខាន់នៃវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។ លើសពីនេះទៅទៀត ផែនការជាតិជាច្រើនត្រូវបានរៀបចំឡើង ដើម្បីគាំទ្រយុទ្ធសាស្ត្រនេះ រួមមាន ក្របខ័ណ្ឌផ្លូវការ និងច្បាប់ដូចជា៖ គោលនយោបាយ **វ.ប.ន.** គោលនយោបាយស្ទែម គោលនយោបាយជីវេត គំនិតផ្តួចផ្តើមរបស់រាជរដ្ឋាភិបាលលើផ្នែកឌីជីថល ការបង្កើត **គ.ជ.វ.ប.ន.** និងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងគណៈកម្មាធិការជាតិ **វ.ប.ន.** សម្រាប់អាស៊ាន និងក្របខ័ណ្ឌដទៃទៀត។
    - ស្ថាប័នផ្តល់មូលនិធិមួយគួរត្រូវបានបង្កើតឡើង ដោយមានក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ជាស្ថាប័នសម្របសម្រួលសម្រាប់វិស័យ **វ.ប.ន.**។ ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជនបានជួបប្រទះនឹងបញ្ហាប្រឈមក្នុងការព្យាយាមខិតខំលើកស្ទួយវិស័យ **វ.ប.ន.** ដោយមានអ្នកពាក់ព័ន្ធក្នុងស្រុកជាច្រើនបានធ្វើការលើវិស័យទាំងនោះ។ បច្ចុប្បន្នក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និង **គ.ជ.វ.ប.ន.** ដើរតួនាទីជាថ្នាលដើម្បីជំរុញកិច្ចសហការលើវិស័យ **វ.ប.ន.** សម្រាប់ផលប្រយោជន៍រួម។

- **ស្ថាប័នអប់រំ និងវិទ្យាស្ថានស្រាវជ្រាវ**
    - កាលពីពេលថ្មីៗនេះ ក្រសួងអប់រំ យុវជន និងកីឡាបានប្តេជ្ញាចិត្តក្នុងការជំរុញការអប់រំស្ទែម។ គ្រឹះស្ថានឧត្តមសិក្សាបានទទួលការគាំទ្រសម្រាប់ការអភិវឌ្ឍការអប់រំស្ទែម។ ឧទាហរណ៍ គម្រោងកែលម្អការអប់រំឧត្តមសិក្សា គឺជាគម្រោងមួយក្នុងចំណោមគម្រោងថ្មីៗនៅឧត្តមសិក្សា។ គំរូម៉ូដែលភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន (PPP) ជាទូទៅត្រូវបានលើកតម្កើង។ ការភ្ជាប់ទំនាក់ទំនងរវាងសាកលវិទ្យាល័យ និងសហគ្រាស មានដាក់នៅក្នុងរបៀបវារៈសម្រាប់សាកលវិទ្យាល័យឈានមុខមួយចំនួននៅក្នុងប្រទេស។ ការស្រាវជ្រាវ ត្រូវបានផ្តល់អាទិភាពសម្រាប់កិច្ចសហការជាមួយវិស័យឯកជន។ ឧទាហរណ៍ គម្រោងកែលម្អការអប់រំឧត្តមសិក្សាបានកំណត់ ៧០ ភាគរយ នៃថវិកាសមាសភាពស្រាវជ្រាវសម្រាប់ការស្រាវជ្រាវរួមគ្នាជាមួយវិស័យឯកជន ខណៈ ២០ ភាគរយ និង ១០ ភាគរយទៀត សម្រាប់ការស្រាវជ្រាវលើផ្នែកគោលនយោបាយ និងការស្រាវជ្រាវមូលដ្ឋាន។ ផែនការមេអភិវឌ្ឍន៍ធនធានមនុស្សកំពុងត្រូវបានបង្កើតឡើង ដើម្បីបង្កើនចំនួនបុគ្គលិកមហាវិទ្យាល័យដែលមានសញ្ញាបត្រក្រោយឧត្តមសិក្សាផ្នែកស្ទែម។ គោលនយោបាយ ក្លឹបសិក្សាកំពុងត្រូវបានបង្កើតឡើងដើម្បីធ្វើឱ្យប្រសើរឡើងនូវលទ្ធផលនៃការសិក្សារបស់សិស្សដោយផ្តោតជាពិសេសលើស្ទែម។ គោលនយោបាយនេះ ក៏ផ្តោតលើសមត្ថកិច្ចក្នុងការបង្កើតក្លឹបសិក្សានៅអនុវិទ្យាល័យ ដើម្បីអនុវត្តការអប់រំផ្អែកលើគម្រោងសម្រាប់មុខវិជ្ជាសំខាន់ៗមួយចំនួន។ គំនិតផ្តួចផ្តើមនេះ គឺជំរុញការសិក្សាស៊ីជម្រៅ និងសកម្មភាពក្រៅពីថ្នាក់រៀនផ្អែកលើស្ទែម។ គោលនយោបាយនេះស្របទៅនឹងកម្មវិធីភាពជាដៃគូការអប់រំស្ទែម និងជួយភ្ជាប់ទំនាក់ទំនងទៅវិញទៅមករវាង អនុវិទ្យាល័យ និងសាកលវិទ្យាល័យផងដែរ។
    - អ្នកស្រាវជ្រាវបានយកចិត្តទុកដាក់កាន់តែខ្លាំងចំពោះសេរីភាពក្នុងការងារ ទន្ទឹមនឹងនេះមាគ៌ាអាជីពរបស់ពួកគេក៏ត្រូវបានគិតគូរផងដែរ។ ឧទាហរណ៍ ព្រះរាជក្រឹត្យ ស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យត្រូវបានបង្កើតឡើងនៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៣។ បន្ទាប់មកក្រសួងអប់រំយុវជននិងកីឡាបានអនុវត្តនូវព្រះរាជក្រឹត្យនេះក្នុងគ្រឹះស្ថានឧត្តមសិក្សា ដែលមានរចនាសម្ព័ន្ធតួនាទីសាស្ត្រាចារ្យដែលមានប្រកាសនៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០។ ជាលទ្ធផល ប្រព័ន្ធអេកូឡូស៊ី **វ.ប.ន.** នឹងទទួលបានផ្លែផ្កាពីការបង្កើតចំណេះដឹងដោយវិស័យអប់រំ។
- **វិស័យឯកជន និងនិយោជក**
    - វិស័យឯកជនត្រូវការធនធានមនុស្សដែលមានគុណវុឌ្ឍិខ្ពស់ដែលជាកម្លាំង និងកត្តាជំរុញឱ្យមានប្រព័ន្ធគោលនយោបាយគាំទ្រ និងស្ថាប័នអប់រំក្នុងការផ្គត់ផ្គង់ធនធានមនុស្ស។
    - និយោជកជ្រើសរើស ឬធ្វើវិសិដ្ឋកម្មជំនាញសម្រាប់កម្មករនិយោជិតរបស់ពួកគេដើម្បីសម្របខ្លួនទៅនឹងការវិវឌ្ឍបច្ចេកវិទ្យា និងដើម្បីដើរឱ្យទាន់វដ្តលូតលាស់ថ្មីៗ។

### ៣.២. បញ្ហាប្រឈម

ដោយពិចារណាលើការវិវឌ្ឍយ៉ាងឆាប់រហ័សនៃការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា និងបញ្ហាប្រឈមដែលបណ្តាលមកពីជំងឺរាតត្បាតកូវីដ១៩ វិស័យអាទិភាពដែលផ្តោតលើ **វ.ប.ន.** ត្រូវតែយកចិត្តទុកដាក់ជាថ្មី។ បញ្ហាប្រឈមដ៏ធំបំផុតក្នុងការសម្រេចគោលដៅសំខាន់របស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានចែងនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ នីតិកាលទី៦នៃរដ្ឋសភា ឆ្នាំ២០១៩-២០២៣ គឺបញ្ហានៃមូលធនមនុស្ស។ គុណវុឌ្ឍិនៃធនធានមនុស្សដែលមានកម្រិតទាប ត្រូវបានរំលេចក្នុងគោលនយោបាយ និងផែនការនានាស្ទើរគ្រប់វិស័យ។ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (ឆ្នាំ២០១៩) បានសង្កត់ធ្ងន់ថាគុណវុឌ្ឍិនៃធនធានមនុស្សមានកម្រិតទាបនាពេលបច្ចុប្បន្ន នឹងមានផលប៉ះពាល់ខ្លាំងលើកំណើនសេដ្ឋកិច្ចកម្ពុជានាពេលអនាគត។ ការពិនិត្យវិនិច្ឆ័យលើការវាស់វែងធនធានមនុស្សនៃ១៩៥ ប្រទេស បានបង្ហាញថាសន្ទស្សន៍អភិវឌ្ឍន៍មនុស្សនៅកម្ពុជាកំពុងមានភាពប្រសើរឡើងដោយសន្សឹមៗចាប់ពីឆ្នាំ១៩៩៥ ដល់ឆ្នាំ២០១៦ (Lim et al., ២០១៨)។ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (ឆ្នាំ២០១៩) បានបង្ហាញថាការកសាងសមត្ថភាពស្ថាប័នសាធារណៈ គឺមានសារៈសំខាន់ណាស់ ដែលមានរំលេចក្នុងឯកសារកម្មវិធីរបស់ខ្លួនសម្រាប់ប្រទេសកម្ពុជា (ឆ្នាំ២០១៩-ឆ្នាំ២០២៣)។ ធនាគារអភិវឌ្ឍន៍អាស៊ី (ឆ្នាំ២០១៨) និងធនាគារពិភពលោក (ឆ្នាំ២០១៩) បានកំណត់កម្មវិធីអាទិភាពរបស់ពួកគេលើការវិនិយោគដើម្បីដោះស្រាយការខ្វះខាតជំនាញ។




**រូបភាពទី ៩៖ គោលនយោបាយឧស្សាហកម្ម និងអន្ទាក់នៃសេដ្ឋកិច្ចកម្រិតចំណូលមធ្យម** (Yülek, ២០១៨)

ធនធានមនុស្សប្រកបដោយគុណវុឌ្ឍិ គឺជាគន្លឹះក្នុងការបើកផ្លូវឱ្យមានការអភិវឌ្ឍប្រកបដោយចីរភាព និងកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន។ វាជាកត្តាជំរុញតែមួយគត់ក្នុងការប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ ២០៥០ (RGC, ២០១៩)។ ការអភិវឌ្ឍប្រកបដោយចីរភាព និងកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន គឺពឹងផ្អែក

ខ្លាំងលើសេដ្ឋកិច្ចបៃតង និងជំនាញ។ លើសពីនេះទៀត គោលនយោបាយម៉ឹងម៉ាត់សម្រាប់នវានុវត្តន៍ឧស្សាហកម្ម គឺត្រូវតែដោះស្រាយនៅក្នុងប្រទេសកម្ពុជា។ ការសិក្សាជាក់ស្តែងបានលើកឡើងថា គោលនយោបាយឧស្សាហកម្ម គឺជាកត្តាជំរុញដ៏សំខាន់ដើម្បីចៀសវាងនូវអន្ទាក់សេដ្ឋកិច្ចនៃកម្រិតចំណូលមធ្យម ដូចដែលបានបង្ហាញក្នុង រូបភាពទី៩ (Yülek, ២០១៨)។ ដូច្នេះមាគ៌ាឆ្ពោះទៅរកចក្ខុវិស័យ ឆ្នាំ២០៣០ និងឆ្នាំ ២០៥០ គឺត្រូវឆ្លងកាត់វិធីសាស្រ្តប្រកបដោយនវានុវត្តន៍ក្នុងការធ្វើឱ្យប្រសើរឡើងនូវសេដ្ឋកិច្ច ការធ្វើពិពិធកម្មសេដ្ឋកិច្ច ផលិតភាព ការធ្វើពាណិជ្ជកម្ម និងការប្រកួតប្រជែង។ មាគ៌ានេះចាំបាច់ត្រូវមានសមាហរណកម្ម **វ.ប.ន.** ក្នុងវិស័យឧស្សាហកម្មពីប្រព័ន្ធនវានុវត្តន៍ជាតិដែលផ្អែកលើភ័ស្តុតាងជាក់ស្តែង ដើម្បីជាមធ្យោបាយសម្រាប់ផលិតកម្ម ឬការប្រើប្រាស់ដែលមានប្រសិទ្ធភាពក្នុងប្រព័ន្ធអេកូឡូស៊ីខ្សែច្រវាក់ផ្គត់ផ្គង់។

- ខ្វះការធ្វើសមាហរណកម្ម **វ.ប.ន.** ក្នុងការធ្វើផែនការ និងការវិនិយោគ ដោយផ្អែកលើភ័ស្តុតាងដើម្បីគាំទ្រការលើកកម្ពស់សេដ្ឋកិច្ច ការធ្វើពិពិធកម្ម ផលិតភាព ពាណិជ្ជកម្មនិងការប្រកួតប្រជែង។
- បរិវត្តកម្មនៃហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលមានគុណភាពមិនគ្រប់គ្រាន់ ដូចជាវិស័យដឹកជញ្ជូន ធនធានទឹក ថាមពលអគ្គិសនី កសិកម្ម វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។
- ខ្វះការរចនាផែនការដែលគ្រប់ជ្រុងជ្រោយ និងការវិនិយោគលើការស្រាវជ្រាវដែលមានគុណភាពសម្រាប់វិស័យអាទិភាពដែលជាយុទ្ធសាស្ត្រ។
- ការស្រាវជ្រាវនិងអភិវឌ្ឍន៍ដែលមានគុណភាព និងប្រព័ន្ធអេកូឡូស៊ី នៅពុំទាន់ឆ្លើយតបទៅនឹងតម្រូវការសម្រាប់កំណើនសេដ្ឋកិច្ច ដែលត្រូវទាមទារឱ្យមានការកែសម្រួលលើផែនការដែលមានស្រាប់។
- បរិយាកាសមិនអំណោយផលដែលបណ្តាលមកពីការរចនាផែនការមិនគ្រប់ជ្រុងជ្រោយ និងគ្មានការវិនិយោគច្បាស់លាស់លើវិស័យ **វ.ប.ន.** អាចជាកត្តាដែលមិនអាចទាក់ទាញអ្នកស្រាវជ្រាវប្រកបដោយគុណវុឌ្ឍិខ្ពស់។

ទោះយ៉ាងណាក៏ដោយ ប្រព័ន្ធនវានុវត្តន៍ជាតិត្រូវតែបង្កើតឡើង ដើម្បីធ្វើសមាហរណកម្មសមាសភាគមូលធនមនុស្ស។ សមាសភាគមូលធនមនុស្សបែងចែកជាប្រាំ រួមមាន៖ (១) មូលធនមនុស្សប្រកបដោយគុណវុឌ្ឍិ ដើម្បីគាំទ្រដល់ការគ្រប់គ្រងមូលនិធិ និងហិរញ្ញប្បទានផ្នែក **វ.ប.ន.** (២) មូលធនមនុស្សក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ (៣) មូលធនមនុស្សក្នុងការអភិវឌ្ឍគោលនយោបាយ និងបទប្បញ្ញត្តិ (៤) មូលធនមនុស្សក្នុងការអភិវឌ្ឍជំនាញ (៥) មូលធនមនុស្សក្នុងការបង្កើតឧបករណ៍ **វ.ប.ន.** សម្រាប់ការអភិវឌ្ឍ និងនវានុត្តន៍។ គំរូប្រព័ន្ធនវានុវត្តន៍ជាតិត្រូវបានបង្ហាញលម្អិតនៅក្នុង **រូបភាពទី ១០**។



**រូបភាពទី ១០៖ គំរូម៉ូដែលប្រព័ន្ធនវានុវត្តន៍ជាតិ** (Kuhlmann and Arnold, ២០០១)

## ៤. ទិសដៅយុទ្ធសាស្ត្រ និងអនុសាសន៍

### ៤.១. ការវិនិយោគលើវិស័យ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

ការវិនិយោគលើវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា តាមរយៈការកែលម្អ សមត្ថភាពឧស្សាហកម្ម និងការគាំទ្រក្នុងវិស័យអប់រំ ត្រូវបានដាក់បញ្ចូលក្នុងរបៀបវារៈនៃបណ្ដាប្រទេសអភិវឌ្ឍន៍រីកចម្រើន និងជឿនលឿនបំផុតដូចជាប្រទេសជប៉ុនក្នុងឆ្នាំ១៩៦៨ សាធារណរដ្ឋកូរ៉េក្នុងឆ្នាំ ១៩៤៥ ប្រទេសចិនក្នុងឆ្នាំ ១៩៤៩ និងប្រទេសសិង្ហបុរី ក្នុងឆ្នាំ១៩៦៥ (UNDP, ២០១៩)។ ទោះបីជាប្រទេសកម្ពុជាមានវឌ្ឍនភាពគួរឱ្យកត់សំគាល់ទាំងផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ចក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះក៏ដោយ ក៏កម្លាំងពលកម្មដែលផ្អែកលើមូលដ្ឋានចំណេះដឹង **វ.ប.ន.** គួរតែត្រូវបានគិតគូរសម្រាប់ការរីកចម្រើនរយៈពេលវែងប្រកបដោយបរិយាបន្ន។ ដូច្នេះការប្ដេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់ជាមួយនឹងសកម្មភាពនៃការត្រៀមខ្លួនជាស្រេច លើការកែប្រែផែនការអភិវឌ្ឍដោយមានការត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំ គឺជាកត្តាចាំបាច់ដើម្បីឈានទៅសម្រេចបាននូវចក្ខុវិស័យនេះ។ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ត្រូវតែស្ថិតក្នុងជំហររឹងមាំដើម្បីសម្របសម្រួល និងធ្វើការយ៉ាងជិតស្និទ្ធជាមួយតួអង្គពាក់ព័ន្ធនានា រួមមានក្រសួងអប់រំយុវជននិងកីឡា ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ក្រសួងសុខាភិបាល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជាអាទិ៍ ដើម្បីលើកកម្ពស់ការអប់រំប្រកបដោយគុណភាពលើវិស័យ **វ.ប.ន.** នៅគ្រប់កម្រិត និងតួអង្គពាក់ព័ន្ធនឹងវិស័យ **វ.ប.ន.** ដើម្បីឱ្យមានប្រព័ន្ធអេកូឡូស៊ីអំណោយផលនៅក្នុងប្រទេស។ ជាយុទ្ធសាស្ត្រ គឺត្រូវវិនិយោគលើការអប់រំ និងការបណ្ដុះបណ្ដាលការងារជាក់ស្ដែងសម្រាប់វិស័យឯកជន និងសម្រួចមូលធនមនុស្សចាប់ពីកម្រិតបឋមសិក្សាដល់

សាកលវិទ្យាល័យ ដោយមានកម្មវិធីទាក់ទងនឹងការបង្រៀន ការរៀនសូត្រ និងរបៀបវារៈស្រាវជ្រាវ។ ការណ៍នេះនឹងផ្តល់ឱកាសឱ្យនិស្សិតផ្សារភ្ជាប់ក្នុងផ្នែកវិទ្យាសាស្ត្រ និងយល់ដឹងពីការអនុវត្តវិទ្យាសាស្ត្រ ជាជាងការសិក្សាតែទ្រឹស្តីវិទ្យាសាស្ត្រតែមួយមុខ។ ការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីអំណោយផលក្នុងសង្គមប្រកបដោយវប្បធម៌វិទ្យាសាស្ត្រ គឺជាគោលដៅចុងក្រោយរបស់រាជរដ្ឋាភិបាលដើម្បីបំពេញតាមចក្ខុវិស័យដែលបានកំណត់។ ការផ្សារភ្ជាប់ទៅនឹងគោលដៅនេះ សារមន្ទីរវិទ្យាសាស្ត្រ គឺជាផ្នែកសំខាន់មួយដើម្បីអភិវឌ្ឍឥរិយាបថវិជ្ជមានពិសេសទាក់ទងនឹងយុវជនឆ្ពោះទៅរកវប្បធម៌វិទ្យាសាស្ត្រ ដែលមានទំនាក់ទំនងនឹងប្រវត្តិសាស្ត្រ និងដើម្បីអប់រំសាធារណៈជនអំពីវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។ ប្រព័ន្ធអេកូឡូស៊ីនៅក្នុងសារមន្ទីរនឹងបង្កើតបរិយាកាសរៀនសូត្រប្រកបដោយភាពរីកចម្រើន ជាពិសេសសម្រាប់កុមារ។

ការជំរុញ ការស្រាវជ្រាវបែបអនុវត្តនៅតាមសាកលវិទ្យាល័យ ឬស្ថាប័នស្រាវជ្រាវនានា តាមរយៈការបង្កើតមជ្ឈមណ្ឌលភ្ញាស់ ឬមជ្ឈមណ្ឌលធុរកិច្ចថ្មី គឺមានភាពចាំបាច់ដើម្បីបម្រើដល់ឧស្សាហកម្ម។ ការបង្កើតបណ្តាញផ្សព្វផ្សាយវិស័យ **វ.ប.ន.** ដល់សាធារណៈជន នឹងធ្វើឱ្យវប្បធម៌ **វ.ប.ន.** មានការរីកដុះដាលបន្ថែមទៀតនៅក្នុងសង្គមកម្ពុជា។ ឧត្តមានុវត្តន៍ពីបណ្តាប្រទេសមានសេដ្ឋកិច្ចជឿនលឿនបានការបង្ហាញថា ការស្រាវជ្រាវ និងអភិវឌ្ឍន៍ដើរតួនាទីជាកត្តាសំខាន់នៅក្នុងការជំរុញផលិតផលក្នុងស្រុកសរុប។ ជាទូទៅកំណើនសេដ្ឋកិច្ចមានការកើនឡើងដោយស្វ័យប្រវត្តិ នៅពេលប្រទេសមួយជ្រោមជ្រែងអ្នកវិទ្យាសាស្ត្រក្នុងការស្រាវជ្រាវលើវិស័យអាទិភាពជាតិ និងសន្តិសុខ (Bush, ១៩៩៥)។ ដោយហេតុថាប្រទេសកម្ពុជាកំពុងស្ថិតក្នុងដំណាក់កាលអភិវឌ្ឍនៅឡើយ នោះការកសាងសមត្ថភាពជាយុទ្ធសាស្ត្រក្នុងវិស័យ **វ.ប.ន.** គឺចាំបាច់ត្រូវធ្វើឡើងតាមរយៈកិច្ចសហការរវាងតួអង្គពាក់ព័ន្ធជាតិ និងអន្តរជាតិ។ ការកសាងផែនការយុទ្ធសាស្ត្រដើម្បីទាក់ទាញអ្នកមានទេពកោសល្យវិទ្យាសាស្ត្រ ការផ្តល់ឱ្យពួកគេនូវឋានៈក្នុងសង្គមសមរម្យ និងការធានានូវប្រព័ន្ធគាំទ្រកម្លាំងពលកម្មដែលសមស្រប គឺមិនអាចខ្វះបានឡើយសម្រាប់ពន្លឿនការអភិវឌ្ឍវិស័យ **វ.ប.ន.**។ ម៉្យាងវិញទៀត គំរូម៉ូដែលសមស្របនៃភាពជាដៃគូរវាងសាធារណៈនិងឯកជនក្នុងវិស័យ **វ.ប.ន.** គឺមានសារៈសំខាន់ណាស់ក្នុងការជំរុញឱ្យមានមូលនិធិ ស្រាវជ្រាវនិងអភិវឌ្ឍន៍។

យោងតាមទិន្នន័យសន្ទស្សន៍នវានុវត្តន៍សកល ឆ្នាំ២០២០ បានបង្ហាញថាប្រទេសកម្ពុជាតម្រូវឱ្យមានការជំរុញលើការវិនិយោគក្នុងវិស័យ **វ.ប.ន.** ជាបន្ទាន់ (**តារាងទី ២**)។ ប្រទេសកម្ពុជាមានកម្រិតនវានុវត្តន៍ទាបបើប្រៀបធៀបនឹងប្រទេសជិតខាង ដែលស្ថិតក្នុងក្រុមប្រទេសដែលមានចំណូលមធ្យមកម្រិតទាប (Dutta et al., ២០២០)។

ដើម្បីធ្វើឱ្យប្រសើរឡើងសន្ទស្សន៍សមិទ្ធកម្មនវានុវត្តន៍កម្ពុជា ការគាំទ្រ ការជំរុញ និងការផ្តល់មូលនិធិបន្ថែម គឺជាកិច្ចការបន្ទាន់សម្រាប់រាជរដ្ឋាភិបាលកម្ពុជា។ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ កំពុងដើរតួជាអង្គភាពសំខាន់ក្នុងការរៀបចំរចនាសម្ព័ន្ធដឹកនាំក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ បច្ចុប្បន្ននេះ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ កំពុងខិតខំប្រឹងប្រែងក្នុងការធ្វើសេចក្តីព្រាងគោលនយោបាយថ្មីទាក់ទងនឹងវិស័យ **វ.ប.ន.** ក៏ដូចជាផ្សព្វផ្សាយពីអត្ថប្រយោជន៍វិស័យ **វ.ប.ន.** ដល់សាធារណៈជន និងអ្នកពាក់ព័ន្ធដទៃទៀត ដែលផ្តោតលើការអភិវឌ្ឍប្រព័ន្ធគាំទ្រសម្រាប់ ហិរញ្ញវត្ថុ មូលនិធិ ហេដ្ឋារចនាសម្ព័ន្ធ ក្របខ័ណ្ឌបទប្បញ្ញត្តិ ជំនាញ ឬទេពកោសល្យ និងបច្ចេកវិទ្យា។

ការបង្កបរិយាកាសល្អដល់កម្មវិធីដែលមានទីផ្សារសម្រាប់ការស្រាវជ្រាវនិងអភិវឌ្ឍន៍ ការអភិវឌ្ឍសហគ្រិនភាព ធុរកិច្ចថ្មីបច្ចេកវិទ្យាឈានមុខ និងការពង្រីកលើវិស័យចម្បងៗគួរត្រូវបានបង្កើតឡើងដោយ

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ចំណែកឯមធ្យោបាយផ្ទេរបច្ចេកវិទ្យាផ្អែកលើភ័ស្តុតាងត្រូវតែមានដើម្បីជានាបានថា ការវិនិយោគដោយផ្ទាល់ពីបរទេសមានអំណោយផលដល់ការផ្ទេរចំណេះដឹងសម្រាប់មូលដ្ឋាន។ សម្រាប់ហេតុផលទាំងនេះ ការវិនិយោគនៅក្នុងវិស័យ **វ.ប.ន.** ត្រូវតែធ្វើឡើងជាយុទ្ធសាស្ត្រ និងការប្តេជ្ញាចិត្តស្របតាមចក្ខុវិស័យរបស់ប្រទេស។ ស្ថិតក្នុងបរិបទនេះ គេសង្កេតឃើញថា ប្រព័ន្ធអេកូឡូស៊ីមានការចាប់អារម្មណ៍ពីសំណាក់រាជរដ្ឋាភិបាល វិស័យឯកជន និងដៃគូអភិវឌ្ឍន៍។ ទោះយ៉ាងណាក៏ដោយ ប្រសិនជាពិនិត្យតាមបែបគ្រប់គ្រងគម្រោង គេសង្កេតឃើញថាពុំមានប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃដែលមានព័ត៌មានគ្រប់គ្រាន់ ដើម្បីត្រួតពិនិត្យថាតើសកម្មភាពទាំងអស់ស្របតាមរបៀបវារៈអាទិភាពរបស់រាជរដ្ឋាភិបាលដែរឬទេ។ ដូច្នេះកត្តាដែលបានលើកឡើងខាងលើមានបង្កប់ **វ.ប.ន.** ដែលជាផ្នែកសំខាន់ និងជាមជ្ឈមណ្ឌលនៅក្នុងវដ្តនៃការអភិវឌ្ឍ និងត្រូវបានគេមើលឃើញថាជាក្បាលម៉ាស៊ីនថ្មីសម្រាប់កំណើនសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន។ ការអំពាវនាវឱ្យមានកិច្ចសហការអន្តរ និងឆ្លងក្រសួង និងតួអង្គពាក់ព័ន្ធនានា នឹងជួយសម្រួលដល់ប្រព័ន្ធអេកូឡូស៊ី **វ.ប.ន.** ដែលរួមចំណែកដល់អាទិភាពដែលបានរៀបរាប់ខាងលើជាក្បាលម៉ាស៊ីនថ្មីសម្រាប់កំណើនសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន។

**តារាងទី ២៖ សមិទ្ធកម្មនវានុវត្តន៍នៅកម្រិតចំណូលខុសៗគ្នា ឆ្នាំ ២០២០**

| | ក្រុមប្រទេសមានចំណូលខ្ពស់ | ក្រុមប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ | ក្រុមប្រទេសមានចំណូលមធ្យមកម្រិតទាប | ក្រុមប្រទេសមានចំណូលទាប |
|---|---|---|---|---|
| ស្ថិតលើសពីការរំពឹងទុកសម្រាប់កម្រិតអភិវឌ្ឍន៍ | - ស្វីស<br>- ស៊ុយអែត<br>- សហរដ្ឋអាមេរិក<br>- ចក្រភពអង់គ្លេស<br>- ហូឡង់<br>- ដាណឺម៉ាក<br>- ហ្វាំងឡង់<br>- សិង្ហបុរី<br>- អាឡឺម៉ង់<br>- សាធារណរដ្ឋកូរ៉េ<br>- ហុងកុង<br>- បារាំង<br>- អៀរឡង់<br>- ជប៉ុន<br>- កាណាដា | - ចិន<br>- អាមេនី<br>- អាហ្វ្រិកខាងត្បូង<br>- ហ្សកហ្ស៊ី<br>- ម៉ាសេដ្វានខាងជើង<br>- ថៃ<br>- ស៊ែប៊ី<br>- ហ្សាម៉ាអ៊ីក<br>- កូស្តារីកា<br>- ប៊ុលហ្គារី | - វៀតណាម<br>- អ៊ុយក្រែន<br>- ឥណ្ឌា<br>- ហ្វីលីពីន<br>- សាធារណរដ្ឋម៉ុលដាវី<br>- ម៉ុងហ្គោលី<br>- ទុយនីស៊ី<br>- កេនយ៉ា<br>- ម៉ារ៉ុក | - ម៉ាឡាវី<br>- រវ៉ាន់ដា<br>- តង់សានី<br>- នីហ្សេរ<br>- ម៉ាដាហ្គាស្កា<br>- ម៉ូសំប៊ិក |
| ស្ថិតត្រឹមកម្រិតអភិវឌ្ឍន៍ | - លុចសំបួ<br>- អូទ្រីស<br>- ន័រវែស | - ម៉ុងតេណេហ្គ្រោ<br>- ប្រេស៊ីល<br>- កូឡុំប៊ី | - កៀស៊្សីស៊ីស្ថាន<br>- សេណេហ្គាល់<br>- ឥណ្ឌូណេស៊ី | - នេប៉ាល់<br>- បួគីណាហ្វាសូ<br>- តាហ្ស៊ីគីស្ថាន |

| | | | | |
|---|---|---|---|---|
| | - អ៊ីស្លង់<br>- បែលហ្ស៊ិក<br>- អូស្ត្រាលី<br>- សាធារណរដ្ឋឆែក<br>- អេស្តូនី<br>- នូវែលសេឡង់<br>- ព័រទុយហ្គាល់<br>- អ៊ីតាលី<br>- ស៊ីប<br>- អេស្ប៉ាញ<br>- ម៉ាល់ត៍<br>- ឡេតូនី<br>- ហុងគ្រី<br>- ស្លូវេនី<br>- ក្រូអាស៊ី<br>- ប៉ូឡូញ<br>- ក្រិក | - ម៉ាឡេស៊ី<br>- ហ្ស៊កដានី<br>- ម៉ិកស៊ិក<br>- បូស្នី<br>- អ៊ីរ៉ាក់<br>- ប៉េរូ<br>- អាល់បានី<br>- បេឡារុស<br>- ម៉ូរីស<br>- លីបង់ | - អែលសាល់វ៉ាឌ័រ<br>- ស៊ីមបាវ៉េ<br>- អ៊ូសបេគីស្ថាន<br>- ហុងឌូរ៉ាស<br>- កាប់វែរ | - អ៊ូហ្គង់ដា<br>- តូហ្គោ<br>- ម៉ាលី |
| សេដ្ឋកិច្ចផ្សេងៗ | - ស៊ីលី<br>- ស្លូវ៉ាគី<br>- លីទុយអានី<br>- អ៊ុយរូហ្គាយ<br>- អេមីរ៉ាតអារ៉ាប់រួម<br>- ប៉ាណាម៉ា<br>- អារ៉ាប៊ីសាអូឌីត<br>- កាតា<br>- ព្រុយណេ<br>- បារ៉ែន<br>- កូវ៉ែត<br>- អូម៉ង់ | - អេក្វាទ័រ<br>- អាស៊ែបៃហ្សង់<br>- តួកគី<br>- អាហ្សង់ទីន<br>- ប៉ារ៉ាហ្គាយ<br>- រុស្ស៊ី<br>- ស្រីលង្កា<br>- ក្វាតេម៉ាឡា<br>- ណាមីប៊ី<br>- បុតស្វាណា<br>- សាធារណរដ្ឋដូមីនីក<br>- អាល់ហ្សេរី<br>- កាហ្សាក់ស្ថាន | - **កម្ពុជា**<br>- កូតឌីវ័រ<br>- ប៉ាគីស្ថាន<br>- ហ្គាណា<br>- អេស៊ីប<br>- កាមេរូន<br>- បូលីវី<br>- បង់ក្លាដែស<br>- សំប៊ី<br>- នីហ្សេរីយ៉ា<br>- សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ<br>- មីយ៉ាន់ម៉ា | - អេត្យូពី<br>- ហ្គីណេ<br>- បេណាំង<br>- យេម៉ែន |

ប្រភព៖ ក្រសួងផែនការ នៃព្រះរាជាណាចក្រកម្ពុជា(២០១០, ២០១៦)

## ៤.២. អភិបាលកិច្ចស្ថាប័ន

ផ្នែកនេះមានគោលបំណងផ្តល់នូវអនុសាសន៍ ទិសដៅ ចង្កោមគោលនយោបាយ និងការរៀបចំស្ថាប័ន ដែលជួយសម្រួលដល់ការវិនិយោគ និងការអភិវឌ្ឍលើវិស័យ **វ.ប.ន.**។ ទិន្នន័យ និងព័ត៌មានថ្មីៗដែលទទួលបាន តាមរយៈការប្រឹក្សាយោបល់យ៉ាងទូលំទូលាយជាមួយអន្តរក្រសួង វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ គួរតែត្រូវបាន យកមកពិចារណាក្នុងការកំណត់អាទិភាពថ្មីៗដើម្បីឆ្លើយតបនឹងគន្លងប្រក្រតីថ្មីរបស់ប្រទេសកម្ពុជា ក៏ដូចជាក្នុង និងក្រៅតំបន់។

### ក. រាជរដ្ឋាភិបាល

- ធ្វើការពិចារណាឡើងវិញលើទិសដៅ និងកំណត់ទិសដៅដែលផ្អែកលើភស្តុតាងជាក់លាក់ សម្រាប់កំណើនសេដ្ឋកិច្ចជាតិប្រកបដោយមហិច្ឆតា ហើយមានចក្ខុវិស័យ ផែនការយុទ្ធសាស្ត្រ និងសកម្មភាពសម្រាប់រយៈពេលខ្លី មធ្យម និងវែង ដែលអាចសម្រេចបាន
- ពិនិត្យ និងធ្វើវិសោធនកម្មសមត្ថកិច្ច បទប្បញ្ញត្តិ និងច្បាប់របស់ស្ថាប័នពាក់ព័ន្ធនានាដែល មានវិសាលភាព-យុត្តាធិការដែលបានកំណត់យ៉ាងច្បាស់ទុកជាមុន និងទំនួលខុសត្រូវរបស់ ស្ថាប័ន ជាពិសេសរវាងក្រសួងនិងក្រសួង ដើម្បីចៀសវាងកិច្ចប្រឹងប្រែងឥតប្រយោជន៍ និងការ ខ្វះខាយថវិកាជាតិ
- ពង្រឹងសមត្ថភាពមន្ត្រីរាជការក្នុងស្ថាប័នពាក់ព័ន្ធដោយមានប្រព័ន្ធបទប្បញ្ញត្តិតឹងរឹង
- កាត់បន្ថយនូវនីតិវិធីការិយាធិបតេយ្យណាដែលអាចរារាំងដល់នវានុវត្តន៍ ដូចជានីតិវិធីមួយចំនួន ដែលពាក់ព័ន្ធនឹងការចុះបញ្ជី និងការស្នើសុំបើកអាជីវកម្ម ហើយជួយសម្រួលដល់ការ វិនិយោគ និងបរិយាកាសធុរកិច្ចឱ្យកាន់តែមានមេត្រីភាព
- អភិវឌ្ឍស្តង់ដារ លំនាំគំរូ និងក្របខ័ណ្ឌទូលំទូលាយមួយ សម្រាប់ធានាឱ្យបាននូវឯកសណ្ឋាន ភាព អន្តរប្រតិបត្តិការ និងសន្តិសុខសម្រាប់ពាក្យស្នើសុំនានា នៅក្នុងប្រទេសកម្ពុជាដោយមិន គិតថាជាភារកិច្ចរបស់ក្រសួង ឬទីភ្នាក់ងារណាមួយនោះទេ
- អភិវឌ្ឍគេហទំព័រច្រកចេញចូលតែមួយរបស់រាជរដ្ឋាភិបាល និងក្របខ័ណ្ឌណែនាំដើម្បីសុវត្ថិភាព និងឯកសណ្ឋានភាព ដែលភ្ជាប់ទៅនឹងគេហទំព័រសាធារណៈ
- ផ្តល់រង្វាន់លើកទឹកចិត្តដល់ធុរកិច្ចដែលវិនិយោគលើវគ្គបណ្តុះបណ្តាលការងារជាក់ស្តែង និង វគ្គបណ្តុះបណ្តាលតាមរយៈការចុះកម្មសិក្សា (ដូចជា លទ្ធភាពក្នុងការជួយកាត់បន្ថយពន្ធ ឬ ការរួមចំណែកវិយោគលើថ្លៃដើម) ដែលពិតជាអាចបង្កើតជាសហគមន៍កម្មសិក្សា
- ជំរុញការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍន៍ ដែលចាំបាច់ផ្តើមចេញ និងដឹកនាំឱ្យមានការ ប្តេជ្ញាចិត្តថ្នាក់ជាតិ ដោយរាជរដ្ឋាភិបាលឈានទៅរកការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍន៍ ពីវិស័យសាធារណៈ និងឯកជន
- កំណត់ និងផ្តល់អាទិភាពឱ្យច្បាស់លាស់លើវិស័យឧស្សាហកម្មផ្តើម ដើម្បីលើកកម្ពស់ការ វិនិយោគដោយផ្ទាល់ទាំងក្នុងនិងពីក្រៅប្រទេសឱ្យមានប្រសិទ្ធភាព

- ពង្រឹងបន្ថែមលើប្រព័ន្ធអប់រំស្វែម និងគំរូម៉ូដែល **រ.ប.ន.** និងបង្កើនហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចឱ្យកាន់តែប្រសើរឡើង ដើម្បីរក្សាបន្តចលករ និងកំណើនសេដ្ឋកិច្ចវង្វង់៧ភាគរយ ឬខ្ពស់ជាងនេះនៃផលិតផលក្នុងស្រុកសរុប និងដើម្បីចៀសផុតពីអន្ទាក់នៃប្រទេសមានចំណូលមធ្យម។ លើសពីនេះទៀត ត្រូវយកចិត្តដាក់លើការកៀរគរពីវិស័យកម្មន្តសាល ដែលប្រើប្រាស់កម្លាំងពលកម្ម ទៅជាវិស័យកម្មន្តសាល ដែលប្រើប្រាស់មូលដ្ឋានចំណេះដឹង និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៃការស្រាវជ្រាវនិងអភិវឌ្ឍន៍ឱ្យកាន់តែប្រសើរឡើង
- ជំរុញការវិនិយោគរបស់ក្រុមហ៊ុនពហុជាតិលើវិស័យឧស្សាហកម្មធុនធ្ងន់ ដូចជាគ្រឿងអេឡិចត្រូនិកនិងឧបករណ៍អគ្គិសនី ឧស្សាហកម្មសីមីខនដាក់ទ័រ ឧស្សាហកម្មពាក់ព័ន្ធបច្ចេកវិទ្យាជីវៈ និងសេនេទិក និងឧស្សាហកម្មគីមី
- កៀរគរធនធានមនុស្សដែលមានចំណេះធ្វើ ជំនាញទំនើប និងខ្ពស់ជាងមុនពីក្រៅប្រទេសដើម្បីធ្វើវិសិដ្ឋកម្មសហគ្រាសកម្មន្តសាល និងធ្វើពិពិធកម្មផលិតផលនាំចេញដែលមានតម្លៃបន្ថែមខ្ពស់
- នាំចូលគ្រឿងចក្រ និងខ្សែផលិតកម្មមានបច្ចេកវិទ្យាទំនើបៗតាមរយៈការវិនិយោគដោយផ្ទាល់ពីបរទេស ដៃគូអភិវឌ្ឍន៍ ឬក្រុមហ៊ុនបច្ចេកវិទ្យា
- លើកកម្ពស់កិច្ចសហប្រតិបត្តិការ និងកម្មវិធីចែករំលែកបទពិសោធពីបណ្ដាក្រុមហ៊ុនលំដាប់ពិភពលោកដើម្បីចម្លងឧត្តមភាពពីធុរកិច្ចដែលជោគជ័យទាំងអស់នោះ
- ផ្ដល់ការគាំទ្រផ្នែកបច្ចេកទេសពីបណ្ដាប្រទេសអភិវឌ្ឍន៍ដែលមានបច្ចេកវិទ្យាឈានមុខ សម្រាប់វិសិដ្ឋកម្មវិស័យកម្មន្តសាលដើម្បីបង្កើនផលិតភាព និងប្រសិទ្ធភាព
- បង្កើតមូលទិន្នន័យដែលអាចប្រៀបធៀបបានទាំងជាតិ និងអន្តរជាតិលើទំនាក់ទំនងរវាងឧស្សាហកម្ម បច្ចេកវិទ្យា ភាពប្រកួតប្រជែង និងសកលភាវូបនីយកម្ម ដើម្បីផ្ដល់ព័ត៌មានដល់ការស្រាវជ្រាវ ការជជែកវែកញែក និងការបង្កើតគោលនយោបាយ
- អភិវឌ្ឍ និងពង្រឹងក្របខ័ណ្ឌត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីវាស់វែងដំណើរការ និងកែតម្រូវការអនុវត្តគោលនយោបាយ **រ.ប.ន.**
- រៀបចំស្ថាប័នទទួលបន្ទុកត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ **រ.ប.ន.** ដូចជា **ក.ជ.រ.ប.ន.** និងស្ថាប័នដែលទើបតែត្រូវបានបង្កើតឡើងថ្មីផ្សេងៗទៀត។

**ខ. ការអប់រំ**

- អនុម័តយន្តការដើម្បីត្រួតពិនិត្យលើតម្រូវការជំនាញដែលមានភាពផ្លាស់ប្ដូរ។ យន្តការនេះអាចជាទម្រង់ស្ទង់មតិពីឧស្សាហកម្ម ឬការសន្ទនាជាប្រចាំ (ឧទាហរណ៍ រៀងរាល់ត្រីមាសម្ដង) រវាង រាជរដ្ឋាភិបាល ផ្នែកអប់រំស្រាវជ្រាវ និងឧស្សាហកម្ម។
- កសាងប្រព័ន្ធអប់រំឧត្តមសិក្សាឡើងវិញ ដើម្បីរៀបចំខ្លួនសម្រាប់បដិវត្តឧស្សាហកម្មជំនាន់ទី ៤
- កែទម្រង់មុខវិជ្ជាសិក្សាកម្រិតបឋមសិក្សា និងអនុវិទ្យាល័យ សម្រាប់អ្នកជំនាន់ក្រោយដើម្បីត្រៀមខ្លួនក្នុងបរិបទបដិវត្តឧស្សាហកម្មជំនាន់ទី ៤ តាមរយៈការអនុវត្តបច្ចេកវិទ្យាព័ត៌មានបច្ចេកវិទ្យាទំនាក់ទំនងនិងព័ត៌មាន ការសរសេរកូដ និងការសរសេរកម្មវិធីក្នុងមុខវិជ្ជាសិក្សា
- ពង្រឹង និងធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពគ្រូបង្រៀន ដើម្បីធានាថាគ្រូបង្រៀនមានគុណវុឌ្ឍិ និងគុណសម្បទា ជាពិសេសពាក់ព័ន្ធនឹងឧស្សាហកម្មជំនាន់ទី ៤

- ជំរុញ និងទាក់ទាញសិស្សានុសិស្សនៅសាលាបឋមសិក្សា និងអនុវិទ្យាល័យ ឱ្យជ្រើសរើសមុខវិជ្ជាស្ទែមដោយមានការបំពាក់នូវឧបករណ៍ពិសោធន៍ច្រើនមុខនៅក្នុងផ្នែកវិទ្យាសាស្ត្រ
- ផ្តល់ ឬស្វែងរកអាហារូបករណ៍ពាក់ព័ន្ធមុខវិជ្ជាវិទ្យាសាស្ត្រ ដូចជា រូបវិទ្យា គណិតវិទ្យា វិស្វកម្ម វិស្វកម្មបញ្ញាស កម្មន្តសាល វិស្វកម្មមេកានិក វិស្វកម្មអេឡិចត្រូនិកនិងអគ្គិសនី ជីវៈបច្ចេកវិទ្យានិងវិស្វកម្មសេនេទិក វិស្វកម្មណាណូដាក់លាក់ និងវិស្វកម្មរូបជាតុ ជាដើម
- លើកកម្ពស់ និងទាក់ទាញអ្នកមានទេពកោសល្យ **វ.ប.ន.** ជាជនជាតិខ្មែរដែលរស់នៅក្រៅប្រទេស និងជនបរទេស ឱ្យមកធ្វើការក្នុងស្រុក
- ធ្វើទំនើបកម្មវិធីសាស្ត្របង្រៀន និងរៀន ដោយប្រើប្រាស់ឧបករណ៍និងសម្ភារៈបច្ចេកវិទ្យាទំនើបៗ ដូចជា បច្ចេកវិទ្យាបន្ថែមទិន្នន័យលើរូបភាព (AR) បច្ចេកវិទ្យារូបភាពប្រត្យក្សនិម្មិត (VR) និងការបោះពុម្ព3D ជាដើម
- ផ្តល់វគ្គបណ្តុះបណ្តាលការងារជាក់ស្តែង ដើម្បីធ្វើវិសិដ្ឋកម្មសមត្ថភាព ជាពិសេសនៅក្នុងវិស័យកម្មន្តសាល
- ពង្រឹងទំនាក់ទំនងរវាងសាកលវិទ្យាល័យ និងសហគ្រាស ដើម្បីផ្លាស់ប្តូរពីសាកលវិទ្យាល័យធម្មតាទៅជាសាកលវិទ្យាល័យមានលក្ខណៈបែបសហគ្រិនភាពតាមរយៈការប្រកាសនីយបត្រតក្កកម្មនៃសមិទ្ធផលស្រាវជ្រាវ និងជំរុញការប្រើប្រាស់សមិទ្ធផលស្រាវជ្រាវក្នុងវិស័យឯកជនដើម្បីធ្វើវិសិដ្ឋកម្មសមត្ថភាពកម្មន្តសាល និងបង្កើនផលិតភាពដែលផ្តល់តម្លៃបន្ថែមខ្ពស់។

**គ. ការគាំទ្រហេដ្ឋារចនាសម្ព័ន្ធ**

- ធ្វើឱ្យប្រសើរឡើង និងពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ដូចជាបណ្តាញគ្របដណ្តប់ប្រព័ន្ធអ៊ីនធឺណិត ព័ស្តុភារកម្ម ថាមពលអគ្គិសនីដែលអាចទុកចិត្តបាន និង ទឹកស្អាត
- ធ្វើឱ្យប្រសើរឡើងនូវស្តង់ដារ និងច្បាប់កម្មសិទ្ធិបញ្ញា ដើម្បីលើកកម្ពស់នវានុវត្តន៍ និងរក្សាភាពប្រកួតប្រជែងនៅលើទីផ្សារក្នុងស្រុក តំបន់ និងអន្តរជាតិ
- ផ្តល់មូលនិធិសន្ទនីយភាពដល់វិស័យឯកជនអាទិភាព ដែលនៅក្នុងអន្តរកាលនៃធុរកិច្ចថ្មី ការពង្រីកខ្លួន ការរីកលូតលាស់ និងការប្រែក្លាយជាក្រុមហ៊ុនបណ្តុំ និងក្រុមហ៊ុនពហុជាតិ
- បង្កើតយន្តការហិរញ្ញប្បទានដើម្បីគាំទ្រសហគ្រាសធុនតូចនិងមធ្យម ជាពិសេសក្នុងវិស័យអាទិភាព ដោយផ្តល់ប្រាក់កម្ចីដែលមានការប្រាក់តិចតួច ឬគ្មានការប្រាក់
- យកចិត្តទុកដាក់លើការធ្វើឱ្យប្រសើរឡើងនូវសេវាកម្មប្រឹក្សាយោបល់ធុរកិច្ច ដែលរួមមាន៖ ការគាំទ្រឱ្យមានអនុលោមភាពស្តង់ដារ ភាពឈ្លាសវៃលើទីផ្សារ ព័ត៌មានបច្ចេកវិទ្យាដែលទទួលយកបាន និងប័ណ្ណទូទាត់បច្ចេកវិទ្យា ដើម្បីជួយសហគ្រាសធុនតូច និងមធ្យមក្នុងការចាប់យកបច្ចេកវិទ្យាថ្មី
- ជួយពង្រីកទំហំ និងបង្កើនល្បឿនចលករ សម្រាប់ធុរកិច្ចថ្មីដែលមានសក្តានុពល និងជួយពន្លឿនបរិវត្តកម្មពីធុរកិច្ចថ្មីទៅជាក្រុមហ៊ុនធំ
- ការធ្វើឱ្យប្រសើរឡើងនូវភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន ពីព្រោះវិស័យឯកជនអាចមានដំណោះស្រាយនវានុវត្តន៍ចំពោះបញ្ហាមួយចំនួន ដូចជាការកែលម្អហេដ្ឋារចនាសម្ព័ន្ធជាដើម

- ជំរុញការអភិវឌ្ឍសួន **វ.ប.ន.** បណ្តុំសហគ្រាសធុនតូចនិងមធ្យម មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី និងមជ្ឈមណ្ឌលពន្លឿនធុរកិច្ច។

## ៤.៣. ការត្រួតពិនិត្យ និងវាយតម្លៃវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

ការត្រួតពិនិត្យ និងវាយតម្លៃ គឺជាគន្លឹះសំខាន់សម្រាប់ការអនុវត្តគោលនយោបាយ **វ.ប.ន.** ឱ្យបានជោគជ័យ ទូលំទូលាយ និងប្រសិទ្ធភាព។ ការត្រួតពិនិត្យ និងវាយតម្លៃ គឺជាកញ្ចក់សម្រាប់ឆ្លុះបញ្ចាំងទូទៅសម្រាប់អ្នកអនុវត្តន៍គោលនយោបាយ និងជាពិសេសសម្រាប់អ្នកអភិវឌ្ឍន៍គោលនយោបាយ (**រូបភាពទី ១១**)។ ដូច្នេះ ការត្រួតពិនិត្យ និងវាយតម្លៃ បម្រើរាជរដ្ឋាភិបាលក្នុងការវាយតម្លៃវឌ្ឍនភាព និងសមិទ្ធកម្មនៃការអនុវត្តគោលនយោបាយ ដោយផ្អែកលើដំណោះស្រាយបញ្ហាប្រឈម និងឈរលើមូលដ្ឋាន ភស្តុតាងជាក់លាក់ ។

- ទទួលស្គាល់ពីតួនាទីដ៏សំខាន់នៃការត្រួតពិនិត្យ និងវាយតម្លៃ ក្នុងការអនុវត្តគោលនយោបាយ **វ.ប.ន.**
- អភិវឌ្ឍប្រព័ន្ធ និងក្របខ័ណ្ឌត្រួតពិនិត្យនិងវាយតម្លៃដ៏រឹងមាំដោយផ្អែកលើលទ្ធផល ក្នុងគោលដៅផ្តល់ធាតុចូលកែលម្អលើសមិទ្ធកម្ម និងការអនុវត្តគោលនយោបាយ
- បង្កើតមូលដ្ឋានហេដ្ឋារចនាសម្ព័ន្ធទិន្នន័យ និងសមត្ថលទ្ធភាពត្រួតពិនិត្យ និងវាយតម្លៃ
- ដាក់បញ្ចូលការរចនាកម្មវិធីក្នុងប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ ព្រោះថាកម្មវិធីដែលបានរចនាត្រឹមត្រូវ បង្កភាពងាយស្រួល និងចំណាយតិច
- បង្កើតយន្តការ ឬប្រព័ន្ធរាយការណ៍ដែលមានប្រសិទ្ធភាពខ្ពស់ សម្រាប់ត្រួតពិនិត្យ និងវាយតម្លៃពីវឌ្ឍនភាព និងសមិទ្ធផលនៃការសម្រេចវត្ថុបំណង និងសូចនាករ។ ឧទាហរណ៍៖ ថ្នាលរាយការណ៍ទាន់ហេតុការណ៍ គួរតែត្រូវបានបង្កើតឡើង និងដាក់ឱ្យអនុវត្ត
- វាយតម្លៃកម្មវិធីនិងស្ថាប័នជាទៀងទាត់ លើហេដ្ឋារចនាសម្ព័ន្ធនៃការស្រាវជ្រាវ ក៏ដូចជាគុណភាពបង្រៀននៅឧត្តមសិក្សាដោយធានាឱ្យមានការវាយតម្លៃមួយ ដែលមានតម្លាភាពពេញលេញតាមរយៈវេទិកាដែលអនុញ្ញាតឱ្យមានការផ្លោះប្តូរវិធីសាស្ត្រវាយតម្លៃផ្សេងៗ
- អនុញ្ញាតឱ្យអង្គភាពត្រួតពិនិត្យ និងវាយតម្លៃអាចទទួលបាននូវទិន្នន័យ និងព័ត៌មានជាក់លាក់ពីពហុតួអង្គពាក់ព័ន្ធ សម្រាប់ធ្វើជាសូចនាករដោយផ្អែកលើមូលដ្ឋានទិន្នន័យ
- ជំរុញវប្បធម៌នៃការរៀនសូត្រ ការត្រួតពិនិត្យ និងការវាយតម្លៃ ដល់មន្ត្រីរាជការ ដោយបង្កើនសមត្ថភាពតាមរយៈលំហាត់ការងារជាទៀងទាត់ក្រោមកិច្ចសហការជាមួយតួអង្គពាក់ព័ន្ធ
- ធ្វើឱ្យប្រសើរឡើងគណនេយ្យភាព និងផ្តល់ភាពស្របច្បាប់ដល់ការប្រើប្រាស់មូលនិធិសាធារណៈ និងធនធានផ្សេងៗ
- ការប្រមូលសូចនាករ **វ.ប.ន.** ពាក់ព័ន្ធនឹងការបង្កើតមូលដ្ឋានទិន្នន័យត្រួតពិនិត្យជាគន្លឹះដើម្បីភាពប្រសើរឡើងនៃការអនុវត្តគោលនយោបាយ **វ.ប.ន.**។ ឧទាហរណ៍៖ សូចនាករទាំងឡាយជាមូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់គណនេយ្យភាព និងការសិក្សា
- ជំរុញការប្រើប្រាស់លទ្ធផល និងជាភស្តុតាង ដែលបានពីការត្រួតពិនិត្យ និងវាយតម្លៃ

- គួរបង្កើតឱ្យមានការសិក្សាពីផលជះ ដើម្បីវាយតម្លៃភាពប្រែប្រួលក្រោយពីការអនុវត្តគម្រោង ឬកម្មវិធីណាមួយ។ ឧទាហរណ៍៖ ការងារដែលល្អ និងមានគុណភាព និងបៀវត្សរ៍សមរម្យ ដែលអនុលោមតាមសិទ្ធការងារ ជាផលជះនៃការអនុវត្តន៍យុទ្ធសាស្ត្របានជោគជ័យ
- គួរអនុវត្តយន្តការផ្តល់ជារង្វាន់ ឬការលើកទឹកចិត្តផ្សេងៗ ចំពោះការងារ **វ.ប.ន.** ឆ្នើម។ ឧទាហរណ៍៖ ចំនួនក្រុមហ៊ុន ឬបុគ្គលដែលទទួលរង្វាន់លើកទឹកចិត្តថ្នាក់ជាតិ ឬអន្តរជាតិ
- ត្រៀមមូលនិធិជាពិសេសសម្រាប់សកម្មភាពត្រួតពិនិត្យ និងវាយតម្លៃ ប្រមាណពី មួយ ទៅបី ភាគរយនៃមូលនិធិគម្រោងសរុប
- គាំទ្រការត្រួតពិនិត្យ និងវាយតម្លៃ តាមរយៈជំនួយបច្ចេកទេស ការកសាងសមត្ថភាព និង ហិរញ្ញប្បទាន ដើម្បីធ្វើការវាយតម្លៃឱ្យបានទូលំទូលាយ ដោយមានការសិក្សាត្រឹមត្រូវ និង ហ្មត់ចត់លើផលជះ
- អនុម័តជាយុទ្ធសាស្ត្ររួមរបស់រាជរដ្ឋាភិបាល ដើម្បីលើកទឹកចិត្តឱ្យទាំងអស់គ្នារំដោះខ្លួនពីដែន សុំាក្នុងការងារ (comfort zone)។

ទោះយ៉ាងណាក៏ដោយ ភាពជោគជ័យ និងនិរន្តរភាពនៃការត្រួតពិនិត្យ និងវាយតម្លៃក៏នៅតែរងផលប៉ះពាល់ពីកត្តាសត្យានុម័តចាំបាច់ជាច្រើនផងដែរ។ ដូច្នេះ ការស្ទង់មតិជាប្រចាំ គឺជាអនុសាសន៍ដ៏ចាំបាច់មួយ។ ជាឧទាហរណ៍ ការស្ទង់មតិលើការស្រាវជ្រាវនិងអភិវឌ្ឍន៍នៅក្នុងសហគ្រាស និងការស្ទង់មតិលើនវានុវត្តន៍ (UNESCO, ២០១៤) ត្រូវតែធ្វើឡើងជារៀងរាល់បី ឬបួនឆ្នាំម្តង ដើម្បីវាយតម្លៃវឌ្ឍនភាព និងផលជះនៅក្នុងប្រទេសកម្ពុជា។

**រូបភាពទី ១១** បង្ហាញពីប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃដោយផ្អែកលើលទ្ធផល ដែលបានកំណត់ដោយ Kusek & Rist (២០០៤) និងYülek (២០១៨)។ ការវាស់វែងភាពជោគជ័យនៃគោលនយោបាយដែលបានរចនា ត្រូវមានក្របខ័ណ្ឌត្រួតពិនិត្យ និងវាយតម្លៃដ៏រឹងមាំដោយផ្អែកលើលទ្ធផលដែលទទួលបាន។ ធនធានដែលប្រើប្រាស់សម្រាប់ការសម្រេចចិត្តក្នុងការអនុវត្ត គឺជាកត្តាកំណត់លើប្រសិទ្ធភាពនៃដំណើរការ និងសមត្ថភាពស្ថាប័នរបស់ប្រទេស។ ប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃដោយផ្អែកលើលទ្ធផលនេះមាន ១០ជំហាន ដូចបានពណ៌នាខាងក្រោម។ ក្របខ័ណ្ឌនេះអាចជួយបន្ថែមទៀតលើការរៀបចំគោលនយោបាយ និងការសម្រេចចិត្តក្នុងការអនុវត្ត។

១. ធ្វើការវាយតម្លៃដែលត្រៀមលក្ខណៈទុកជាមុន៖ ការកសាងមូលដ្ឋានគ្រឹះសម្រាប់ប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ

២. កំណត់លទ្ធផលដែលត្រូវត្រួតពិនិត្យ និងវាយតម្លៃ៖ ការជ្រើសរើសលទ្ធផលដើម្បីធ្វើការត្រួតពិនិត្យ និងវាយតម្លៃ ព្រោះថាលទ្ធផលបង្ហាញពីផ្លូវដើរទៅមុខ

៣. ជ្រើសរើសសូចនាករគន្លឹះដើម្បីត្រួតពិនិត្យលើលទ្ធផល៖ ធ្វើការត្រួតពិនិត្យវឌ្ឍនភាពនៃសូចនាករគន្លឹះ ដោយអាស្រ័យទៅនឹងធាតុចូល សកម្មភាព លទ្ធផលរបស់សកម្មភាព លទ្ធផល និងផលជះ

៤. ទិន្នន័យមូលដ្ឋានសម្រាប់ធ្វើជាសូចនាករ - តើយើងនៅត្រង់ណាសព្វថ្ងៃនេះ?៖ ការកសាងមូលដ្ឋានសមិទ្ធកម្ម (បរិមាណវិស័យ ឬគុណវិស័យ) ដែលជាចំណុចចាប់ផ្តើមនៃការត្រួតពិនិត្យ

៥. ផែនការសម្រាប់ការកែលម្អ - ការជ្រើសរើស គោលដៅលទ្ធផលៈ ការជ្រើសរើសគោលដៅលទ្ធផល ដោយផ្អែកលើកម្រិតសូចនាករមូលដ្ឋាន និងកម្រិតនៃការកែលម្អតាមចេតនា

៦. ការត្រួតពិនិត្យលទ្ធផលៈ ការប្រមូលទិន្នន័យគុណផលដែលមានគុណភាព

៧. តួនាទីនៃការវាយតម្លៃៈ ថ្លឹងថ្លែងលើការប្រើប្រាស់ ប្រភេទ និងការកំណត់ពេលវេលានៃការវាយតម្លៃ

៨. ធ្វើរបាយការណ៍អំពីលទ្ធផលរកឃើញៈ ការធ្វើរបាយការណ៍លើការវិភាគទិន្នន័យ ដែលអាចជួយដល់អ្នកសម្រេចចិត្តដើម្បីធ្វើឱ្យគម្រោង គោលនយោបាយ និងកម្មវិធីមានភាពប្រសើរឡើង

៩. ប្រើប្រាស់លទ្ធផលរកឃើញៈ ការចែករំលែកចំណេះដឹងដែលបានពីលទ្ធផលរកឃើញដល់រាជរដ្ឋាភិបាល និងស្ថាប័ននានា

១០. ធ្វើនិរន្តរភាពប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃនៅក្នុងស្ថាប័នៈ ស្វែងរក និងដោះស្រាយបញ្ហាប្រឈមក្នុងប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃដោយផ្អែកលើលទ្ធផល ដែលរួមមានតម្រូវការ តួនាទីនិងការទទួលខុសត្រូវច្បាស់លាស់ ទំនុកចិត្ត និងព័ត៌មានដែលគួរឱ្យទុកចិត្ត គណនេយ្យភាព សមត្ថភាព និងការលើកទឹកចិត្តដែលសមរម្យ។




រូបភាពទី ១១៖ និរន្តរភាពលើប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃដែលផ្អែកលើលទ្ធផល (កែសម្រួលពី Zall & Rist (២០០៤) និង Yulek (២០១៨)

# ឯកសារយោង

ADB-Asian Development Bank. (2017). *Draft Small & Medium Enterprise (SME) Development Policy and Five-Year Implementation Plan 2017-2021*. Phnom Penh: ADB.

ADB-Asian Development Bank. (2018). *Toward Adopting A Skills Development Fund for Cambodia*. Phnom Penh: ADB.

APO-Asian Productivity Organization. (2018). *Cambodia National Productivity Master Plan 2020-2030*. Tokyo: APO.

Bush, V. (1995). *Science, the endless frontier*. Ayer Company Publishers.

CDRI-Cambodia Development Resource Institute. (2019). *Fostering an Inclusive Digital Transformation in Cambodia*. Forthcoming SET Report. Phnom Penh: CDRI.

Christine, U. (2019). Financing TVET: a comparative analysis in six Asian countries. Paris: AFD. https://issuu.com/objectifdeveloppement/docs/nt56_tvet_asian_countries_anahat_kaur

Chu, S., Reynolds, R., Notari, M., Taveres, N., & Lee, C. (2016): 21st Century Skills Development through Inquiry Based Learning from Theory to Practic, Springer Science, 1-15.

Dutta, S., Lanvin, B., & Wunsch-Vincent, S. (2020). The Global Innovation Index 2020: Who Will Finance Innovation. *World Intellectual Property Organization*. https://www.wipo.int/edocs/pubdocs/en/wipo_pub_gii_2020.pdf

Ehst, M., Sak, S., Sanchez Martin, M. E., & Van Nguyen, L. (2018). *Entrepreneurial Cambodia*. Phnom Penh: World Bank.

KOICA-Korean International Cooperation Agency. (2014). *Cambodian ICT Masterplan 2014-2020*. Phnom Penh: KOICA.

Kruy, N. (2020). Chapter 2: Economic Development Outlook. *CAMBODIA 2040*, p.13-30.

Kuhlmann, S., & Arnold, E. (2001). *RCN in the Norwegian Research and Innovation System: Background Report No. 12 in the Evaluation of the Research Council of Norway*. ISI, Fraunhofer-Inst. Systemtechnik und Innovationsforschung.

Lim, S. S., Updike, R. L., Kaldjian, A. S., Barber, R. M., Cowling, K., York, H., ... & Murray, C. J. (2018). Measuring human capital: a systematic analysis of 195 countries and territories, 1990–2016. *The Lancet*, *392*(10154), 1217-1234.

Madhur, S. (2014). *Cambodia's skill gap: An anatomy of issues and policy options*. Working Paper No. 98. Phnom Penh: CDRI.

MoEYS-Ministry of Education Youth and Sports. (2019). *Cambodia's Education 2030 Roadmap*. Phnom Penh: MoEYs.

MoP-Ministry of Planning. (2016). *Cambodia Socio-Economic Surveys 2010 and 2016*. Phnom Penh: MoP.

MPTC-Ministry of Post and Telecommunication. (2020). *National Policy on ICT in 2020*. Phnom Penh: MPTC.

Nair, M., Pradhan, R. P., & Arvin, M. B. (2020). Endogenous dynamics between R&D, ICT and economic growth: Empirical evidence from the OECD countries. *Technology in*

*Society*, *62*, 101315. https://doi.org/10.1016/j.techsoc.2020.101315

NSTC-National Council for Science and Technology. (2014). *National Master Plan for 2014-2020*. Phnom Penh: NCSTI.

OCM-Office of the Council of Ministers. (2017). *Summary Report and 3 key requests from the National Science and Technology Council (NSTC) on promoting the development of science and technology*. N$^0$ 80 SCHN.CHS. Phnom Penh: RGC.

OCM-Office of the Council of Ministers. (2020a). *Royal Kram on promulgating of law on Establishment of Ministry of Industry, Science, Technology, and Innovation.* No. NS/RKM/0320/009. Phnom Penh: RGC.

OCM-Office of the Council of Ministers. (2014). *Royal Kram* on Organizing and Functioning of National Council for Science and Technology. No. NS/RKT/0914/1136. Phnom Penh: RGC.

OCM-Office of the Council of Ministers. (2019). *Royal Kram on Promulgation of Law on Electronic Commerce.* No.NS/RKM/1119/017. Phnom Penh: RGC.

OCM-Office of the Council of Ministers. (2015). *Royal Kram on Promulgation of Law on Telecommunication.* No.NS/RKM/1215/017. Phnom Penh: RGC.

OCM-Office of the Council of Ministers. (2003). *Royal Kram on Promulgation of Law on* Copyright and Related Rights. NS/RKM/0303/008. Phnom Penh: RGC.

OECD- Organization for Economic Co-operation Development. (2016). Technology, and Innovation. https://doi.org/10.1596/978-0-8213-7380-4

Olaoye, I. J., Ayinde, O. E., Ajewole, O. O., & Adebisi, L. O. (2020). Olaoye, I. J., Ayinde, O.E., Ajewole, O. O., & Adebisi, L. O. (2020). The role of research and development (R&D) expenditure and governance on economic growth in selected African countries. *African Journal of Science, Technology, Innovation and Development*, 1-8. https://doi.org/10.1080/20421338.2020.1799300

RGC-Royal Government of Cambodia. (2018). *Rectangular Strategy-Phase IV, 2018-2023.* Phnom Penh: RGC.

RGC-Royal Government of Cambodia. (2019). *National Policy on Science Technology and Innovation 2020-2030.* Phnom Penh: RGC.

RGC-Royal Government of Cambodia. (2015). *Cambodia Industrial Development Policy 2015-2025*. Phnom Penh: RGC.

RGC-Royal Government of Cambodia. (2017). *National Technical and Vocational Education and Training Policy 2017-2025.* Phnom Penh: RGC.

RGC (Royal Government of Cambodia). (2019a). *National Policy on Science Technology and Innovation 2020-2030*. Phnom Penh: RGC.

RGC-Royal Government of Cambodia. (2019b). *Sub-Decree on SME Bank.* No: 17 ANKr.BK. Phnom Penh: RGC.

RGC-Royal Government of Cambodia. (2020a). *Sub-Decree on Techo Startup Center as a Public Administrative Institution.* No: 119 ANKr.BK. Phnom Penh: RGC.

RGC-Royal Government of Cambodia. (2020b). *Sub-decree on the Functions of the Ministry of Industry, Science, Technology & Innovation.* No: 48 ANKr.BK. Phnom Penh: RGC.

RGC-Royal Government of Cambodia. (2020c). *Royal Decree on Converting National,*

*Science and Technology Council to the National Council of Science, Technology & Innovation.* No: RS.RKT.1020/1073. Phnom Penh: RGC.

RGC-Royal Government of Cambodia. (2013). *Cambodia's national science and technology master plan (2014-2020). December 2013*. Phnom Penh: RGC. http://snt.gov.kh/wp-content/uploads/2016/03/Master-Plan-2014-2020.pdf

Savrul, M., & Incekara, A. (2015). The effect of R&D intensity on innovation performance: A country level evaluation. *Procedia-Social and Behavioral Sciences*, *210*, 388-396. https://doi.org/10.1016/j.sbspro.2015.11.386

Sokolov-Mladenović, S., Cvetanović, S., & Mladenović, I. (2016). R&D expenditure and economic growth: EU28 evidence for the period 2002–2012. *Economic research-Ekonomska istraživanja*, *29*(1), 1005-1020. https://doi.org/10.1080/1331677X.2016.1211948

Spiess, R. (2018). *Hun Sen promises more money for science research | Phnom Penh Post*. Phnom Penh Post. https://www.phnompenhpost.com/business/hun-sen-promises-more-money-science-research.

Tassey, G. (2008). The roles and economic impacts of technology infrastructure. https://www.researchgate.net/profile/Gregory-Tassey/publication/228792797_The_roles_and_economic_impacts_of_technology_infrastructure/links/5536b3620cf218056e953125/The-roles-and-economic-impacts-of-technology-infrastructure.pdf

UNDP-United Nations Development Pogramme. (2019). *Adaptation and Adoption of Industry 4.0 in CAMBODIA*. Phnom Penh: UNDP.

UNESCO-United Nations Educational, Scientific and Cultural Organization. (2014). Guide to conducting an R&D survey: For countries starting to measure research and experimental development. http://uis.unesco.org/sites/default/files/documents/guide-to-conducting-an-rd-survey-for-countries-starting-to-measure-research-and-experimental-development-2014-en.pdf

UNESCO-United Nations Educational, Scientific and Cultural Organization. (2015). Cambodia | UNESCO UIS, Science, Technology and Innovation. Phnom Penh: UNESCO http://uis.unesco.org/en/country/kh?theme=science-technology-and-innovation

UNESCO-United Nations Educational, Scientific and Cultural Organization. (2020). *Science, technology and innovation*. Phnom Penh: UNESCO http://data.uis.unesco.org/Index.aspx?DataSetCode=SCN_DS

Whitehouse. (1995). Supporting Research and Development to Promote Economic Growth : The Federal Government 's Role The United States leads. *Technology Transfer*, 31–44. https://doi.org/https://doi.org/10.1007/BF02280346.

World Bank. (2012). *Matching aspirations: skills for implementing Cambodia's growth strategy*. Phnom Penh: World Bank.

World Bank. (2019). *Evolution of STI Policies for Sustainable Development*. Phnom Penh: Word Bank.

Yülek, M. A. (2018). How Nations Succeed. Palgrave Macmillan US.

Zall Kusek, J., & Rist, R. (2004). Ten steps to a results-based monitoring and evaluation system: A handbook for development practitioners.

**ឧបសម្ព័ន្ធ ១៖** លំដាប់នៃកិច្ចប្រជុំក្រុមការងាររៀបចំរបាយការណ៍ **រ.ប.ន.**

| កិច្ចប្រជុំ | កាលបរិច្ឆេទ | ចំណុចគន្លឹះ |
|---|---|---|
| ១ | ២០ តុលា ២០២០ | - ទទួលអនុសាសន៍ពី**ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ឆែម គាតរិទ្ធី** លើសេចក្តីព្រាងគ្រោង<br>- កិច្ចពិភាក្សាក្នុងក្រុមការងារលើចំណុចគន្លឹះដែលត្រូវដាក់ចូលក្នុងរបាយការណ៍ |
| ២ | ២៨ តុលា ២០២០ | - ទទួលការណែនាំពី**ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ឆែម គាតរិទ្ធី** លើទម្រង់របាយការណ៍ និងចំណុចគន្លឹះដែលត្រូវសរសេរនៅក្នុងសេចក្តីផ្តើម តួសេចក្តី និងផ្នែកអនុសាសន៍នៃរបាយការណ៍<br>- ការចែករំលែកឯកសារផ្សេងៗដែលពាក់ព័ន្ធនឹងរបាយការណ៍ដោយក្រុមការងារ |
| ៣ | ០៤ វិច្ឆិកា ២០២០ | - ទទួលការតម្រង់ទិសបន្ថែមពី**ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ឆែម គាតរិទ្ធី**<br>- កិច្ចពិភាក្សាក្នុងក្រុមការងារលើសមត្ថលទ្ធភាពនៃចំណុចដែលត្រូវបញ្ចូលក្នុងរបាយការណ៍ |
| ៤ | ២៩ វិច្ឆិកា ២០២០ | - ការផ្តល់មតិកែតម្រូវលើកទី១ ដោយ**ឯកឧត្តមបណ្ឌិត គួច ហ៊ីដេវ៉ូ** |
| ៥ | ០៦ ធ្នូ ២០២០ | - កិច្ចពិភាក្សាក្នុងក្រុមការងារអំពីវឌ្ឍនភាពនៃមតិកែតម្រូវ<br>- កំណត់កាលបរិច្ឆេទចុងក្រោយសម្រាប់របាយការណ៍ដែលត្រូវកែសម្រួល និងត្រួតពិនិត្យបន្ថែមដោយ **ឯកឧត្តមបណ្ឌិត ហ៊ុល សៀងហេង** |
| ៦ | ២៣ ធ្នូ ២០២០ | - កិច្ចពិភាក្សាអំពីមតិកែតម្រូវដោយសមាជិកគណៈប្រឹក្សាយោបល់នៃ **ក.ជ.រ.ប.ន.** ដែលដឹកនាំដោយ **ឯកឧត្តមបណ្ឌិត ហ៊ុល សៀងហេង** |

**ឧបសម្ព័ន្ធ ២៖** ចំណាយសរុបលើការស្រាវជ្រាវនិងអភិវឌ្ឍន៍ គិតជាភាគរយនៃផលិតផលក្នុងស្រុកសរុប

| **សូចនាករ** | | ការស្រាវជ្រាវនិងអភិវឌ្ឍន៍ គិតជាភាគរយនៃផលិតផលក្នុងស្រុកសរុប | | | | | |
|---|---|---|---|---|---|---|---|
| **ឆ្នាំ** | | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
| **ប្រទេស** | | .. | .. | .. | .. | .. | .. |
| ព្រុយណេ | | .. | .. | .. | .. | .. | ០,២៨ |
| កម្ពុជា | | .. | .. | ០,១២ | .. | .. | .. |
| ឥណ្ឌូណេស៊ី | | ០,០៨ | .. | .. | ០,២៥ | ០,២៤ | ០,២៣ |
| សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ | | .. | .. | .. | .. | .. | .. |
| ម៉ាឡេស៊ី | | .. | ១,២៦ | ១,៣០ | ១,៤៤ | .. | .. |
| មីយ៉ាន់ម៉ា | | .. | .. | .. | .. | ០,០៣ | .. |
| ហ្វីលីពីន | | ០,១៤ | .. | ០,១៦ | .. | .. | .. |
| សឹង្ហបុរី | | ១,៩២ | ២,០៨ | ២,១៨ | ២,០៨ | ១,៩៤ | .. |
| ថៃ | | ០,៤៤ | ០,៤៨ | ០,៦២ | ០,៧៨ | ១,០០ | .. |
| វៀតណាម | | ០,៣៧ | .. | ០,៤៤ | .. | ០,៥៣ | .. |
| មជ្ឈមភាគនៃអាស៊ាន | | ០,៥៩ | ១,២៨ | ០,៨០ | ១,១៤ | ០,៧៥ | ០,២៥ |
| | | | | | | | |
| ក្រុមតាមចំណូលរបស់ធនាគារពិភពលោក | | .. | .. | .. | .. | .. | .. |
| ប្រទេសមានចំណូលទាប | | ០,៣១ | ០,៣០ | ០,៣០ | ០,៣០ | ០,២៩ | .. |
| ប្រទេសមានចំណូលមធ្យមកម្រិតទាប | | ០,៤៥ | ០,៤៤ | ០,៤៣ | ០,៤៤ | ០,៤៣ | .. |
| ប្រទេសមានចំណូលមធ្យម | | ១,០៤ | ១,០៧ | ១,១០ | ១,១៣ | ១,១៥ | .. |
| ប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ | | ១,៣១ | ១,៣៦ | ១,៤១ | ១,៤៥ | ១,៤៨ | .. |
| ប្រទេសមានចំណូលខ្ពស់ | | ២,៣៦ | ២,៣៨ | ២,៣៧ | ២,៣៧ | ២,៤២ | .. |

ប្រភព៖ http://data.uis.unesco.org/Index.aspx?DataSetCode=SCN_DS

វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

ISBN 978-9924-9556-4-1